ស្នូរទូរសព្ទរោទ៍ដាស់ឧកញ៉ា ប៉ែន ពេជ្រ ដ៏ទន់ខ្សោយឱ្យរលឹកពីដំណេកវិញទាំងដៃនៅជាប់ចំណងនៅឡើយ....
ចំណែក ហួត ស៊ីវ មិនបានលង់លក់មួយស្រទ្បេតណាទេ ព្រោះគាត់មានសុខភាពមាំទាំជាងស្រាប់ហើយ ឯចិត្តនៅតែសញ្ជប់សញ្ជឹងនឹកដល់កូនប្រុសទីពីរដែលត្រូវជាប់ក្នុង អន្ទាក់មនុស្សស៊ីបាយបោកឆ្នាំង។ អគ្គទេសាភិបាលមើលឃើញភាពភ្ញាក់ផ្អើលលេចឡើងលើផ្ទៃមុខលេខាប៉េងដែល ជ្រីវជ្រួញចាស់មុនអាយុព្រោះតែត្រូវរស់នៅគ្មានប្រពន្ធកូននិង ត្រាំត្រែងក្នុងគំនុំមិនដឹងមុខ។

គាត់គិតស្ងាត់ៗម្នាក់ឯង៖
«បើពេលនេះយើងចោទថាវាឡប់ យើងគួរតែឱនមកមើលខ្លួនឯងដែរ ច្រើនគ្រាមកនេះយើងបានបណ្តោយជីវិតតែលតោលក្នុងភ្នក់ភ្លើង លេងល្បិចចុះឡើង ចុងក្រោយសូម្បីតែកូនៗយើងដែលតែងតែដើរតាមយើងយ៉ាងទៀងត្រង់ក៏ ត្រូវយើងបោកបញ្ឆោតជាឧបករណ៍ជម្លោះពេលនេះទៀតកូនប្រុសម្នាក់បានធ្លាក់ក្នុងដៃសត្រូវទៅហើយ ជីវិតយើងមិនដឹងថៃបានគង់អត់ផងកុំថាឡើយមកគិតថាមានវិធីអ្វី ខ្លះអាចជួយវាបានទៀតនោះ! ក្តីសង្ឃឹមយើងពេលនេះគឺកុំឱ្យតែកូនប្រុសច្បងរបស់យើងព្រមយក ជីវិតមកលោអន្ទាក់ម្នាក់ទៀតបានហើយ!»

ប៉េងនិយាយព្ទៗទាំងគំហក៖
«អាឡូ?»
ហួត ស៊ីវ ងាកទៅសម្លឹងលេខាដ៏លាក់ពុតរបស់គាត់។អាកប្បកិរិយាគេបានសេចក្តីថាគេកំពុងសង្ស័យពីអ្វីមួយហើយគេស្គាល់លេខអ្នកដែលខលមក។

ពិតជាអញ្ចឹងមែន! ព្រោះនោះជាសំឡេងស្រីស្រួយស្រឹបហើយមានតែប៉េងទេដែលស្តាប់ព្ទពីពាក្យសារភាពរបស់នាង៖
«ពូ!!! យុត្តនាគេអត់មកជប៉ុនទេ! ពេលយន្តហោះជិតឡើងគេស្រាប់តែបាត់ខ្លួនហើយ! គេកុំហកខ្ញុំ....ខ្ញុំត្រូវមកជប៉ុនតែម្នាក់ឯងទេ!»
«គ្មានបានការ!»

ប៉េងនិយាយតិចៗទាំងខាំមាត់។
«សូមទោសដែលធ្វើឲ្យពូប៉េងខកចិត្ត!»សំឡេងឪមកនេះមិនមែនសំឡេងបន្ត របស់បុស្បាទេ តែជាសំឡេងរបស់អ្នកណាម្នាក់ដែល ហួត ស៊ីវ ឃើញហើយបើកភ្នែកធំៗ ហើយបុស្បាក៏ឮកាលណាភ្ញាក់របូតទូរសព្ទពីដៃ។
«ត្រូវហើយ! ក្មួយស្រីលោកទៅជប៉ុនតែម្នាក់ឯងទេលេខាប៉េង!! ព្រោះខ្ញុំជាប់រវល់នៅខាងណេះមិនអាចកំដរនាងបាន!»
លេខាប៉េង រំកិលទម្លាក់ទូរសព្ទចុះឃើតៗពីត្រចៀកព្រោះសៀតផ្កាគាត់ ត្រូវបានកាល់ជាមួយវត្ថុអ្វីមួយរឹងត្រជាក់ហើយគ្មានវិញ្ញាណ។
គាត់ដឹងថាជាកាំភ្លើងតូចខ្លីតែវាគ្រប់គ្រាន់អាចបញ្ចប់ជីវិត គាត់បាន បើគ្រាន់តែម្ចាស់វាខ្វះការអត់ធ្មត់បន្តិចហើយកេះកៃ......
គាត់រវេភ្នែកក្រឡឹតក្រឡាប់ចុះឡើង ចំពេលកែវភ្នែកភ្លឺមុតរបស់អ្នកប្រុសទីមួយសម្លឹងមកគាត់អមជាមួយ សំណើចកំដរបបូរមាត់គេ។
«ខ្ញុំទុកពេលឱ្យពូតែម្តងទេ! លុតជង្គង់សុំទោសប៉ាខ្ញុំ មុនពេលទៅដេកទ្រុង បើអត់ទេ គឺងាប់ដូចខ្មោចឆ្កែនៅទីនេះ!»
ប៉េងរវេភ្នែករកមើលកូនចៅវា ព្រោះមិននឹកស្មានថាអ្នកប្រុសទីមួយអាចគ្រប់គ្រងស្ថានការណ៍បាន ល្អហើយលឿនថ្នាក់នេះ។ យល់ចិត្តបុរសមានពុត យុត្តនាសើចកំដរគាត់មុនពេលនិយាយពន្យល់៖
«រកមើលគ្នាពូមែនអត់? នៅនុះ!»

គាត់ងាកទៅជណ្តើរក្នុងពេលកូនចៅកំពុងរត់បន្តកន្ទុយគ្នាចុះ ក្រោម។ ម្នាក់ផ្សេងទៀត កំពុងឱនទៅជួយស្រាយចំណងឱ្យ ហួត ស៊ីវ បន្ទាប់មកគឺ ប៉ែន ពេជ្រ ។
«ឯងធ្វើស្អីអាទី? ឯងស្រាយពួកវាធ្វើអី?»
កូនចៅម្នាក់នោះភ័យស្លេកស្លាំងឆ្លើយដោយមិនហ៊ានសម្លឹងគាត់ទេ៖
«សុំទោសអាទ្រា! ខ្ញុំមានឪពុកម្តាយនៅស្រុក!.....ខ្ញុំ ....ខ្ញុំមិនហ៊ានប្រឆាំងជាមួយអ្នកប្រុសធំទេ!»
កូនចៅនោះនិយាយចប់ក៏រត់ប្រូចទៅតាមអ្នកមុនៗអស់ ធ្វើឱ្យប៉េងធ្លាក់ថ្លើមក្តុកចំហមាត់សម្លឹងទៅប៉ែន ពេជ្រ និង ហួត ស៊ីវ ដែលរបូតពីចំណងអស់ គ្រាន់តែគ្មានកម្លាំងក្រោករួចឯ

ហួត ស៊ីវ នៅអង្គុយដោយទឹកមុខមាំ។
យុត្តនានិយាយបន្តៈ
«ជាងមួយខែមុនពូឱ្យគ្នាពូប៉ុន្មាននាក់ដេញស្ទាក់ចាប់ខ្ញុំក្នុង ក្រុង បន្ទាប់មកឱ្យពួកវាចូលឃ្លាំង រកដោះ Mr Johan! ពេលពួកខ្ញុំតាមទាន់ពូឱ្យវាឆ្លើយទម្លាក់លើអ្នកផ្ទះ ប៉ែន ពេជ្រ ពូឃើញខ្ញុំសំងំអត់ដេញដោលស្មានថា រឿងនេះចប់? ពួកវាស៊ីបាយប៉ាខ្ញុំគ្រាន់តែពូ ឯងជាអ្នកពាក់ប្រឡៅឱ្យហើយ បញ្ចុកបាយវា ពូឯងស្មានថាវាស្រលាញ់ពូឯងរហូតដល់សម្លាប់អ្នកឱ្យបាយវាកើត? ឪពុកម្ដាយពួកវាយាយតា បងប្អូន ពួកវាសុទ្ធ តែខ្ញុំស្គាល់ ពូឯងស្មានថាអាចធានាការពារឱ្យពួកវាបាន? ពូឯង ចាស់ពេកហើយពូប៉េង ! លុតជង្គង់ទៅ!»
វាងាកមករកយុត្តនា ហើយស្ដោះទឹកមាត់ឆ្វើយ....
«លុតជង្គង់? សុំទោស??? ឆ្វើយ! ឱ្យវាទៅសុំទោសបងប្រុសអញនៅឋានខ្មោចមុនសិនទៅ!»
យុត្តនាក្ដៅចិត្ត កាណុងគេបុកទៅមុខធ្ងន់ជាងមុន ទោះបីបុរសនោះហាក់មិនញញើតនឹងទ្វារមច្ចុរាជក៏ដោយ អ្នកប្រុសនិយាយសង្កត់ពាក្យៈ
«ពូឯងឃើញហើយ ខ្ញុំមកគ្មានកូនចៅម្នាក់ទេ! ពូឯងអាចងាប់ដូចខ្មោចឆ្កែនៅទីនេះ! ខ្ញុំបាញ់បំបែកក្បាលពូឯងទៀត ក៏គ្មានអ្នកណាដឹងដែរ!»
ប៉េងសើចក្អាកក្អាយបន្លប់ពីស្លឹតស្លក់ខំរកមធ្យោបាយអស់មួយខណៈ រួចទើបគាត់និយាយព្ញៗ
៖
«បាញ់ម៉ោៗៗៗ!»

ហួត ស៊ីវ សម្លឹងម្រាមដៃកូនប្រុសច្បង ដែលនៅអែបនឹងកៃកាំភ្លើង។
គេគ្មានទឹកមុខខឹង តែភ្នែកមមីរបស់គេកំពុងចាញ់បញ្ឆោះរបស់លេខាប៉េង។ តាមគំនិតគាត់ មិនដល់ប៉ុន្មានដង្ហើមទៀតទេ បើលេខាប៉េងនៅតែពន្យុះ យុត្តនា អាចនឹងធ្វើ ហើយអនាគតជាទេសាភិបាលរបស់គេនឹងត្រូវចប់ដោយគ្មានតម្លៃ។ បុរសជាឪពុកស្រែកឃាត់រឹងៈ
«យុត្តនា! អត់ទេកូន! កុំបាញ់!!»
អគ្គទេសាភិបាលដែលគិតគូរវែងឆ្ងាយបានដាច់ចិត្តពោលឃាត់គេ ព្រោះគាត់សង្ឃឹមថាលទ្ធផលចុងក្រោយអាចនឹងល្អជាងនេះ ដឹងអីសម្ដីផ្អែមល្ហែមនឹងពាក្យថា«កូន»របស់គាត់ បែរជាដាស់អារម្មណ៍ប៉េងឱ្យនឹកឃើញដល់រឿងផ្សេង។

បុរសអតីតអ្នកលក់ទឹកត្រជាក់សើចបញ្ឈឺកក្អៀកធ្វើឱ្យអ្នកប្រុសទីមួយនឹកងឿងឆ្ងល់ ។ គេនិយាយទាំងគ្រវីក្បាលហួសចិត្ត៖

«ឯងពិតជាចង់បានទ្រព្យគេដល់វង្វេងហើយ! ចង់ងាប់មែន?»

«បាញ់ទៅ!!»លេខាប៉េងតឿន«តែបាញ់ហើយ កុំភ្លេចទុកមួយគ្រាប់ឱ្យខ្លួនឯងផង សម្រាប់ទោសយកចោរធ្វើឪអស់ច្រើនឆ្នាំមកនេះណ៎ាអ្នកប្រុសធំ!»

យុត្តាជ្រួញចិញ្ចើមឯ ហួត ស៊ីវ បើកភ្នែកធំៗ ។

ស្ថានការណ៍បានមកក្នុងដៃ ប៉េងព្រលះបន្ថែមភ្លាម៖

«អ្នកប្រុសស្មានថាខ្លួនឯងឆ្លាតហើយបានជាថ្ងៃនេះយកកាំភ្លើងមក ភ្ជង់អ្នកមានគុណចំពោះខ្លួនហើយការពារសត្រូវ? អ្នកប្រុសដឹងទេថាហេតុអ្វីអាប៉េងនេះវាឱ្យបុស្សាបញ្ជូនអ្នក ប្រុសចេញទៅជប៉ុន?ព្រោះវាស្រលាញ់អ្នកប្រុសដូចកូនរបស់វា វាមិនចង់សម្លាប់អ្នកប្រុស! ក្នុងចំណោមកូនរបស់ ហួត ស៊ីវ អ្នកប្រុសម្នាក់គត់ដែលខ្ញុំចង់ទុកឱ្យស្នងតំណែងទាំងអស់របស់វា ព្រោះវាបានជំពាក់គ្រួសារអ្នកប្រុស តែអ្នកប្រុសយកគ្រាប់កាំភ្លើងមកភ្ជង់ក្បាលមនុស្សដែលស្រលាញ់អ្នក ប្រុសដើម្បីការពារអាចោលម្សៀតដែលសម្លាប់ឪពុកអ្នកប្រុសទៅវិញ?»

យុត្តនាចងចិញ្ចើមសម្លឹងប៉េងយ៉ាងមុតហើយសន្សឹមៗងៀងភ្នែកមករក ហួត ស៊ីវ ដែលមុខស្លេកស្លាំង ហើយចុងក្រោយគេវេភ្នែកទៅរក ប៉ែន ពេជ្រ។

បុរសនោះហើយដែលនាយតែងគិតថាបានសម្លាប់ឪពុកខ្លួន តែក្រឡេកឃើញមុខគេកាលណាអ្នកនឹកដល់ស្រីតូចដែលនៅចាំក្នុងឡានខាង ក្រោម។

អ្នកប្រុសព្រិចភ្នែកបាំងបាត់ភាពទន់ខ្សោយរបស់ខ្លួនហើយនិយាយកាត់៖

«បញ្ជី ប៉ែន ពេជ្រ ជំពាក់ជីវិតឪពុកខ្ញុំ មុនក្រោយគង់តែដោះស្រាយ! តែពូក្បត់ប៉ាខ្ញុំ មិនបាច់និយាយគ្នាទេ!»

«ឯងច្រឡំហើយ! អ្នកដែលឯងហៅថាប៉ានេះ កាលពីជាង១០ឆ្នាំមុនបានសម្លាប់ប៉ាបង្កើតរបស់ឯងហើយទម្លាក់ កំហុសឱ្យ ប៉ែន ពេជ្រ!»

យុត្តនាដឹងថាបុគ្គលនេះកំពុងស្ថិតនៅក្នុងដំណាក់កាលជួយខ្លួនឯង មិនបាន ទោះបីគេនិយាយអ្វីក៏មិនទំនងឱ្យជឿឬយកចិត្តទុកដាក់ស្តាប់ដែរ តែមិនដឹងយ៉ាងម៉េចបានជាស្តាប់ពាក្យគេមួយឃ្លានេះហើយដៃអ្នកទៅ ជាញ័រ???

«ច្រើនឆ្នាំមកនេះអ្នកប្រុសចាញ់បញ្ឆោត ហួត ស៊ីវ យកចោរធ្វើឪពុកតាមពិតវាធ្វើគ្រប់យ៉ាង

ព្រោះចង់ប្រើប្រាស់អ្នក ប្រុសឱ្យសងសឹក ប៉ែន ពេជ្រ ដែលជាសត្រូវចាស់របស់វា ចំណែក អ្នកសម្លាប់ឪពុកអ្នកប្រុសពិតប្រាកដតាមពិតគឺជាវា!»

ប៉ែន ពេជ្រ បើកភ្នែកធំៗ នៅចំពោះមុខវោហារក្តែងៗរបស់ប៉េង។ ចំណែក ហួត ស៊ីវ ខាំមាត់ស្ទើរដាច់មិននិយាយស្តីធ្វើឱ្យយុត្តនាដែលសម្លឹងមកអ្នក ទាំងពីរម្តងម្នាក់ៗទៅជាង៉េមង៉ាម ហើយបាត់ជំហរបន្តិចម្តងៗ។

«ឃាតកសម្លាប់ឪឯង ឯងមិនបាញ់ មកបាញ់អីមនុស្សមិនទាក់ទងគ្នា?»

ប៉េងនិយាយមកផ្ទួនៗធ្វើឱ្យទឹកមុខយុត្តនាក្រហមដូចរងើកភ្លើង ហើយបេះដូងនាយរំជើបរំជួលដូចស្ពានរលកសមុទ្រហៀបនឹងមានព្យុះសង្ឃរា បោកបក់។

គេរេភ្នែកសម្លឹងមក ហួត ស៊ីវ យ៉ាងមុតក្នុងពេលបុរសនោះគេចពីខ្សែភ្នែកគេ។

គេបោះសំណួរទៅទាំងអន្ទះសា៖

«ប៉ា?????»

យុត្តនាចង់សួរច្រើនណាស់ តែគេនិយាយមិនចេញព្រោះស្ទះ។ គេចេញបានត្រឹមតែពាក្យមួយម៉ាត់នេះទាំងបេះដូងចុកចាប់ ព្រោះកាយវិការ ហួត ស៊ីវ បង្ហាញជាស្រេចហើយថាគេមិនចាំបាច់សួរទៀតទេអ្វីដែលលេខាប៉េង និយាយវាជាការពិត។

គាត់ឈ្ងោកហើយជ្រួញមុខ ព្រោះខឹងថាហេតុអ្វីទីបំផុតអាថ៌កំបាំងនេះត្រូវឮដល់ត្រចៀកកូនប្រុសធំដែលធ្លាប់តែត្រូវគាត់ផ្លុំត្រចៀកបានគ្រប់ពេលនេះ?

ឆ្លៀតពេលដែលយុត្តនាធឹងធើ ប៉េងបញ្ចុះបញ្ចូលគេឱ្យកាន់តែវង្វេង៖

«ល្ងាចនោះ ហួត ស៊ីវ ហើយនឹងខ្ញុំបានឡើងទៅរកឪពុកបង្កើតរបស់អ្នកប្រុសនៅឯផ្ទះចាស់ជាន់ទីបួន! គាត់យកលេសថាទៅសួរសុខទុក្ខពេលគាត់ឈឺតែគោលបំណងធំរបស់ ហួត ស៊ីវ គឺចង់បញ្ចុះបញ្ចូលឱ្យលោកបងយុទ្ធរួមគ្នាទាមទារគម្រោងការចុងក្រោយ របស់លោករាជពីឧកញ៉ាប៉ែន ពេជ្រ មកវិញ! ល្ងាចនោះអ្នកប្រុសនិងម្តាយមិនទាន់មកពីសាលាវិញទេ។ ប៉ុន្តែនិយាយចុះនិយាយឡើងលោកបងយុទ្ធនៅតែមិនព្រមប្រឆាំងនឹង ប៉ែន ពេជ្រ ទេគឺគាត់ការពារតាកញ្ជាស់នេះរហូតដល់ហួត ស៊ីវ ក្តៅក្រហាយកើតរឿងឈ្លោះគ្នាផ្តាច់មិត្តភាព អាកញ្ជាស់នេះនឹកឃើញរំលឹករឿងបំណុលចាស់ដែលឪពុកអ្នកប្រុសបាន ជំពាក់ ក៏ទាមទាររឹបអូសប្រទាញប្រទង់យកប្លង់ផ្ទះ។ ផ្ទះនោះគឺឪពុកអ្នកប្រុសថាគាត់ចង់ទុកឱ្យអ្នកប្រុសពេល

គាត់ ស្លាប់ទៅ ដូច្នេះគាត់មិនឱ្យទេ ពេលនោះ ហួត ស៊ីវ ក៏ច្រានឪពុកអ្នកប្រុសហើយចុះមក បាត់។ ឪពុកអ្នកប្រុសមានជំងឺផងត្រូវគេធ្វើបាបផ្លូវកាយផ្លូវចិត្តផង គាត់ក៏ស្លាប់តែម្តងទៅ!»

ក្នុងពេលយុត្តនាគ្រវីក្បាលតតាំមិនទទួលយកអតីតកាលដ៏ឈឺចាប់នេះ ប៉ែន ពេជ្រ បន្លឺឡើងទាំងទោមនស្ស៖

«អាស៊ីវ! អាស៊ីវអើយ កោតតែឯងឆ្កួតភ្លីភ្លើដោយសារតែចិត្តលោភ????»

យុត្តនាទម្លាក់កាំភ្លើងចុះសន្សឹមៗបណ្តោយឱ្យស្នាមញញឹមសម្ងាត់ផុស ឡើងលើបបូរមាត់លេខាមានពុត គេខំនិយាយបន្ថែមកាន់បុរសសង្ហាដែលឈ្ងោកសម្លឹងឥដ្ឋ៖

«ហួត ស៊ីវ ខឹងស្អប់ ប៉ែន ពេជ្រ ព្រោះវានេះចេះយកចិត្តថ្លើមលោករាជ ហើយទទួលបានមរតកមុន ពេលគាត់ស្លាប់ ដូច្នេះវាបានប្រើខ្ញុំឱ្យខលហៅ ប៉ែន ពេជ្រ មកដើម្បីទម្លាក់កំហុសនេះទៅលើគាត់ហើយក្រោយមកវាយកអ្នកប្រុសមក ចិញ្ចឹមជាឧបករណ៍ឱ្យលេង ប៉ែន ពេជ្រ ជំនួសវា!»

«ឈប់និយាយ!»យុត្តនាគំហកដោយឈឺចាប់ ព្រោះគេបានសើរើនឹកឃើញឡើងវិញទាំងអស់។ រាល់សម្តីសំដៅបញ្ឆោះបញ្ឆោតទាំងឡាយដែលបុរសចិនអ្នកមានម្នាក់នេះ នេះបានអប់រំទូន្មានខ្លួនក្នុងនាមជាឪពុកធម៌។ អ្វីៗរំលឹកមកវិញក្នុងអារម្មណ៍ហាក់នៅថ្មីៗ។

មិនដែលមានពេលណាមួយដែលអ្នកមិនស្តាប់គាត់ ហើយមិនធ្វើតាមរាល់បំណងដែលគាត់បង្គាប់មកនោះទេ។ គាត់ចិញ្ចឹមខ្លួនជាមួយគំនុំប៉ុនមេឃហើយចិញ្ចឹមអ្នកប្រុសទីពីរមក ក្នុងនាមជាជនស៊ើបការណ៍នៅផ្ទះនោះទៀត តើយុត្តនាមានរឿងអីនៅភាន់ភាំង។

គេបែរក្រោយរត់ចុះជណ្តើរលែងខ្វល់ពីអ្នកណាហើយ ហើយលែងចង់ឮអ្វីតទៅទៀតបើពុំនោះទេគឺគ្មានអ្នកណាម្នាក់ដែលគេ ព្រមឱ្យរស់រានមានជីវិតឡើយនៅពេលនេះ។

ប៉េងបានរស់ម្តងទៀត គេដកកាំភ្លើងពីចង្កេះលើកមកភ្ជង់បុរសចំណាស់ទាំងពីរជាប់ព្រោះថាពេលនេះពួកគាត់បានរបូតចំណេងអស់ហើយ ទោះម្នាក់ៗសុទ្ធតែមានវ័យចាស់ហើយមើលទៅទៅទុរន់ទុរាយ៉ាងណាក៏ ប៉េងគ្មានផ្លូវប្រហែសឱ្យបែកការជាលើកទីពីរឡើយ។

.....ឯ ហួត ស៊ីវ មិនបានរវល់អ្វីនឹងលេខាក្បត់នេះទៀតដែរ គាត់មិនខ្វល់សូម្បីតែជីវិតខ្លួនឯងគឺមានតែតាម សម្លឹងការឈឺចាប់របស់កូនប្រុសច្បងទាំងឈឺផ្សាពេញបេះដូង...។

គ្រាចុងក្រោយនៃឪពុកម្នាក់...ទម្រាំតែតែយល់ច្បាស់ពីក្តីស្រលាញ់និង ភាពស្មោះត្រង់ថាមានតម្លៃប៉ុណ្ណា អ្វីៗត្រូវបានបំផ្លាញអស់ទៅហើយ។

គាត់ឈ្ងោកមុខឱបវិប្បដិសារីនិងគ្មានអ្វីសម្រាប់និយាយស្ដីទៀតឡើយ។ ប៉ែន ពេជ្រ គ្រវីក្បាលហួសចិត្តៈ
«អាស៊ីវអើយអាស៊ីវពេលណាបានឯងឈប់លោភពេលណាបានឯងឈប់ឆ្កួត???? តាមពិតគម្រោងការនោះ.....»
ប៉ែន ពេជ្រ ហួសចិត្តដែលថាដោយសារគម្រោងការនោះ ហួត ស៊ីវ ជាមិត្តរបស់គាត់ដាច់ចិត្តសម្លាប់មិត្តម្នាក់ទៀតក្នុងចំណោម ប្រុសសង្ហាទាំងបួនដែលកាលពី៣០ឆ្នាំមុនៗ អ្នកណាៗក៏សរសើរនិងច្រណែនពីមិត្តភាពរបស់ពួកគេ។
ក្នុងកាលៈទេសៈដែលគិតថាខ្លួនលែងរស់ ហើយគិតថា ឈឺចាប់ពេកដែលដឹងការពិតនៃមរណភាពរបស់ឪពុកយុត្តនា ប៉ែន ពេជ្រ ប្រុងថានិយាយឱ្យ ហួត ស៊ីវ រឹតតែឈឺចាប់ពីការពិតគ្មានន័យរបស់គម្រោងការរតនៈសោភ័ណនោះ ប៉ុន្តែ ហួត ស៊ីវ ដែលដឹងខ្លួនដូចខ្មោច៧ថ្ងៃចាប់តាំងពីត្រូវបានលោកជំទាវប្រាប់ ការពិតអស់ទៅហើយនោះបានងើបមុខនិយាយឃាត់គាត់៖
«ឯងឈប់និយាយពីរបស់នោះទៅអាពេជ្រ! រឿងដែលឯងលាក់មកយូរហើយ ឯងលាក់វាទៀតចុះ!មិនបាច់និយាយអីទាំងអស់! អញជាអ្នកខុស អញសម្លាប់អាយុទ្ធតែអញអចេតនាទេ អញច្រានវាអញមិនបានដឹងថាវាលើសឈាម ដាច់សរសៃឈាមស្លាប់ទេ! អញជាអ្នកខុស! អញនឹងទៅឋាននរកសុំទោសវា ហើយសុំទោសបងរាជ!»
ហួត ស៊ីវ នៅទីបំផុតក៏ដូច ប៉ែន ពេជ្រ គាត់គិតយល់ហើយដឹងថាខ្លួនឯងបានឆ្កួតវង្វេងអស់២០ឆ្នាំជាមួយនឹង គំនុំស្នេហាព្រមទាំងការច្រណែនជាមួយមិត្តសម្លាញ់ រហូតដល់បង្កើតរឿងរ៉ាវជាច្រើននេះមកឱ្យមនុស្សជំនាន់ក្រោយ ពិសេសកូនប្រុសដ៏ល្អទាំងទ្វេនេះមិនទាន់គិតដល់កូនភ្លោះពីរ នាក់នៅខាងណោះផង។ ដែលគាត់ឃាត់ ប៉ែន ពេជ្រ មិនឱ្យនិយាយអ្វីគឺគ្រាន់តែមិនចង់ឱ្យ មនុស្សស៊ីបាយបោកឆ្នាំដែលដឹងរឿងគ្រប់យ៉ាងរបស់គាត់ត្រូវបានគាត់ចិញ្ចឹមក្រោមក្លៀកហើយលើកដាវចាក់គាត់ម្នាក់នេះបានដឹងបន្ថែមពី អាថ៌កំបាំងដ៏ជូរចត់នៃគម្រោងការរតនៈសោភ័ណតែប៉ុណ្ណោះ។ ទីបំផុតនេះ គាត់យល់ថា ប៉ែន ពេជ្រ ធ្វើត្រូវដែលស៊ូរក្សាកេរ្តិ៍ឈ្មោះមិត្ត ហើយទុកអាថ៌កំបាំងនៃស្នាដៃចុងក្រោយរបស់មិត្តសម្លាញ់ឱ្យស្ថិតស្ថេរគង់វង្សជារៀងរហូត។

គាត់និយាយបន្ថែមក្រោមកាណុងកាំភ្លើងរបស់បុរសអតីតអ្នកលក់ទឹកត្រជាក់៖
«ឯងបាញ់អញទៅអាចង្រៃ! ឯងចាំដល់ណាទៀត! ក្រែងឯងចង់បាញ់អញណាស់អ្វី? អញស្តាយបំផុតដែលខ្វាក់ភ្នែក៣០ឆ្នាំមកនេះយកសត្វក្រពើមកចិញ្ចឹម នៅកៀកខ្លួន ហើយយកមិត្តសម្លាញ់ធ្វើជាសត្រូវស្តាប់សម្តីឯង បំផ្លាញអនាគតកូនៗអញ!»

ប៉េងសើចក្អាកក្អាយចំអកឡកឡឺយយ៉ាងមានសេចក្តីសុខ។
គឺយ៉ាងនេះហើយដែលគាត់ចង់បានគឺឃើញ ហួត ស៊ីវ ឈឺចាប់ហើយ ប៉ែន ពេជ្រ ក៏កំពុងឈឺចាប់ទ្វេនៅពេលបានឃើញលទ្ធផលចុងក្រោយដ៏បាក់បែករបស់ គ្នាគាត់បួននាក់។
លេខាប៉េងសើចរលាក់ដៃក្តាប់កាំភ្លើងជាប់៖
«រឿងដែលឯងត្រូវស្តាយ គឺវាមានច្រើនជាងនេះទៀត!......ឯងស្តាប់ឱ្យច្បាស់ មុនពេលងាប់ក៏ល្អ ដើម្បីឱ្យវាបានបិទភ្នែកជិត....»
ហួត ស៊ីវ ងើបមុខសម្លឹងប៉េង គាត់សើចខឹងក្នុងទ្រូង ហើយប្រើជើងឈូសដីខ្សាច់នៅចុងជើងមួយទំហឹងទៅរកគូបដិបក្ខដែលនៅ ចំពោះមុខ។

«បើចៅហ្វាយងាប់ អាឆ្កែបម្រើវាគួរតែងាប់ទៅ ចាំបក់កន្ទុយឱ្យនៅឋានខ្មោចដែរ!»

ក្រោមស្រមោលរាត្រីងងឹតសូន្យសុង អំពូលអាគុយតូចកំប៉ិតមិនអាចជួយលេខាប៉េងឱ្យមើលឃើញអ្វីបានច្បាស់ ១០០ភាគរយទេកុំថាឡើយ ដល់ពេលនេះគ្រាប់ខ្សាច់ជាច្រើនបាន បានទម្លុះមករំខានប្រស្រីភ្នែកគេ ។

គេស្រែកគ្រហឹមខ្ទរហើយភ្លាត់ដៃបាញ់ផ្ទង លាន់រំពងផ្អើលអស់សត្វរាត្រីចរ....

ទម្រាំតែបានបាត់រកាំភ្នែកបន្តិច គាត់ឃើញ ហួត ស៊ីវ ពន្លែងមួយជើងមកទៀតទៅហើយធ្វើឱ្យគាត់គេចមិនទាន់ ទទួលមួយជើងយ៉ាងដំណំនោះ ប៉ើងខ្ទាតទៅក្បែរឧកញ៉ា ប៉ែន ពេជ្រដែលនៅអង្គុយងើបមិនរួចលើកៅអី។
....ក្នុងវិនាទីដែលគាត់ស្តាយក្រោយហើយនឹកស្មានថា បុរសនេះចាស់ទៅតាមអាយុកាល

គាត់ហើយភ្លេចគិតថាអគ្គទេសាភិបាលដ៏មាន ជោគជ័យក្នុងពាណិជ្ជកម្មនេះមានប្រវត្តិការ៉ាតេដូខ្សែក្រវាត់ខ្មៅ តាំងពីនៅឯវិទ្យាល័យ .....

ប៉េងត្រូវសង្រួមអារម្មណ៍មកវិញបោះចោលការឈឺស្ទើរសន្លប់នោះសិន ហើយប្រមូលកម្លាំងរហ័សដូចផ្លេកបន្ទោរ ក្រោកទៅក្រៀក ប៉ែន ពេជ្រ មកក្នុងដៃឆ្វេង ហើយកាំភ្លើងដែលក្ដាប់ជាប់នៅដៃស្ដាំ ភ្ជង់តម្រង់ក្បាលគាត់ មាត់ក៏សង្រ្កឹតធ្មេញនិយាយគំរាម ហួត ស៊ីវ៖

«អញអត់ចិត្តទន់ដូចអាកូនច្បងចោលម្សៀតរបស់ឯងទេ ហួត ស៊ីវ! បើឯងកម្រើកតែកូនដៃមួយក៏អញបាញ់វានេះ បែកសន្ទះក្បាល!»

កណ្ដាប់ដៃ ហួត ស៊ីវ បោលមកក្បែរក្រអូមមាត់លេខារបស់គាត់ទៅហើយ បែរជាអាក់មកវិញ។ អាយុជីវិតរបស់ ប៉ែន ពេជ្រ មិនមែនជាអ្វីដែលគាត់ទំនងថាស្ដាយនោះទេ ព្រោះសូម្បីជីវិតគាត់ ក៏គាត់មិនគិតទៅហើយ តែគាត់យល់ថាគាត់មិនចង់ឱ្យមានមិត្តណាម្នាក់ទៀតស្លាប់ដោយសារគាត់នោះទេ។

«បើឯងស្លាប់ ឯងស្លាប់តាមធម្មជាតិឯងទៅអាពេជ្រ! យើងក៏អស់អីនឹងជំពាក់គ្នា!»

ហួត ស៊ីវ គិតទាំងកែវភ្នែកក្រៀមក្រំក្នុងពេលដៃគាត់ដកមកក្រោយឃើត១.....តែ គាត់បានគិតខុសព្រោះលេខាប៉េងមិនអាចឱ្យភ្លាត់ជាលើកទីបីឡើយ គេរេកាណុងកាំភ្លើង តម្រង់មក ហួត ស៊ីវ ដែលនៅចំពោះមុខហើយកេះកៃបាញ់ផ្ទួង។

រាងកាយអគ្គទេសាភិបាលដែលស្មោះស្នេហ៍ពេញមួយជីវិត ហើយក៏រស់នៅឯកោពេញមួយជីវិតយកមិត្តជាសត្រូវ យកសត្រូវជាមិត្ត ត្រូវបញ្ចប់ភាពខែងរ៉ែងរបស់គាត់ ហើយស្រុញធ្លាក់សន្ធឹមៗដួលចុះទៅក្រោមកម្រាលស៊ីម៉ង់។
ពន្លឺភ្នែក ប៉ែន ពេជ្រ ក្រហមរលើប គាត់ស្រែកមិនចេញ តែគាត់រើរហូតដល់ធ្លាក់ពីលើកៅអីហើយវារទៅរកមិត្តខ្វែងគំនិតរបស់គាត់។
«អាស៊ីវ!!!! ឯងតាំងស្មារតីឡើងអាស៊ីវ! »

ប៉ែន ពេជ្រ ស្រែកហៅបានតិចៗព្រោះគាត់ជាអ្នកជំងឺស្រាប់ ឯសំឡេងលេខាប៉េងលាន់មកគ្របពីលើបរិយាកាសខ្ទរស្បែរាត្រី។
«ហួត ស៊ីវ! មុនពេលឯងចុះទៅក្រោមសុំទោសអាហ៊ាអញ ឯងគួរស្តាប់រឿងនិទានល្អខ្លះដែរអ្ហ៎!»

ប៉ែន ពេជ្រសម្លឹងទៅចរន្តលោហិតក្រហមច្រាលដែលស្រក់ចេញពីស្មាខាងស្ដាំ របស់មិត្តចាស់។ គាត់ឆ្លេឆ្លាមិនដឹងបានអ្វីជួយសង្គ្រោះគេឯ ហួត ស៊ីវ គិតពីបើកភ្នែកក្រឡោតសម្លឹងទៅលេខាប៉េង។ បុរសស្គាយគំនុំនិយាយមកបន្ថែម៖
«អ្នកសម្លាប់ពួកម៉ាកឯង អាយុទ្ធកាលពីល្ងាចនោះគឺអញ! ឯងស្ដាប់ឱ្យច្បាស់! អញជាអ្នកបង្ហើយវាផ្ទាល់ដៃ! គឺពេលដែលឯងមិនដាច់ចិត្ត ហើយប្រើឱ្យអញឡើងមកមើលស្ថានភាពវា វាមិនទាន់ស្លាប់ទេ វាបានខលទៅរកអាពេជ្រ តែអញជាអ្នកសម្លាប់វា! ឯងស្ដាប់ឮនៅអាល្ងង់!»

ហួត ស៊ីវ បើកភ្នែកធំៗ ចំណែក ប៉ែន ពេជ្រ គឺញ័រដៃទទ្រើក។ ទាំងពីរនាក់ងាកមកសម្លឹងលេខាប៉េងព្រោះហួសចិត្ត។ ប្រការនេះធ្វើឱ្យជននោះកាន់តែក្រអឺតនិយាយឌឺវិញ៖

«នាំគ្នាមើលអី!??? អញជួយឯងលេងល្ខោនដ៏ធំនេះឱ្យអាកូនចម្កួតរបស់ឯងវាយលុំច្រទ្បំលើប៉ែនពេជ្រ អស់ច្រើនឆ្នាំមកហើយ ឥឡូវនេះឱ្យឯងដឹងខ្លះទៅមិនល្អ?»

ហួត ស៊ីវ ហួសចិត្ត ដែលគាត់យល់ថាខ្លួនឯងជាមនុស្សបរាជ័យបំផុតជាងម្ភៃឆ្នាំមកហើយ។ បរាជ័យមិនបានស្រីដែលខ្លួនស្រលាញ់ បរាជ័យមិនបានបេះដូងបងរាជហើយចុងក្រោយបរាជ័យបំផុតគឺបានជ្រុលដៃ សម្លាប់មិត្តម្នាក់របស់ខ្លួន ដែលជាមិត្តស្លូតត្រង់និងក្រីក្រជាងគេ។ ទីបំផុតជិតដល់ដង្ហើមចុងក្រោយសម្ដីប៉េងធ្វើឲ្យគាត់អាចលាងខ្លួន ឯងបានពីឧក្រិដ្ឋកម្មនោះ។ គាត់មិនខឹងតែបែរជាត្រេកអរ គាត់និយាយបន្តមួយៗ៖
«អញ្ចឹងនិយាយទៀតមក គ្នាអញប្អូនទាក់បានធ្វើស្អីបងប្អូនឯងអាអ្នកលក់ទឹកត្រជាក់?»

ប៉េង ដៃភ្ទង់កាំភ្លើង មុខប្រែទៅជាក្រហមងៅ និមិត្តតែនឹកឃើញដល់បងប្រុសរបស់គាត់។ សម្ដីគាត់លាន់មកតំណាលគ្នានឹងស្នាមជ្រីវជ្រួញលើថ្ពាល់៖

«អារាជ !!!! គឺទេវតាបរាមុខវា បានជាឱ្យវាទៅសុំទោសអាហ៊ាអញនៅក្រោមមុន! ៣០ឆ្នាំមុន សិស្សក្ររហាមពីរនាក់បងប្អូន លក់ទឹកត្រជាក់ទិញអង្ករស៊ីបានម៉ែ្វរួចម៉ែ្វ! មិនដែលហ៊ាន ស្រមៃអីធំដុំដូចពួកកូនអ្នកមានឯងទេ! អាហ៊ាអញ គាត់គ្រាន់តែចង់បានការងារមួយនៅក្រុមហ៊ុនបារាំង ហើយគាត់បានខិតខំផ្ចិតផ្ចង់យ៉ាងអស់ពីចិត្ត រៀបចំគម្រោងមួយយកទៅឆ្លងគេ! វាជាទឹកផ្ដាច់ព្រ័ត្រហើយ! តែគ្រាន់ប៉ុណ្ណឹងក៏ពួកឯងមិនទុកផ្លូវឱ្យគាត់ដែរ! អារាជបានចុះឈ្មោះប្រលងហើយការប្រកួតចុងក្រោយគឺនៅសល់តែពីរ នាក់គត់! ពេលនោះអាហ៊ាអញដឹងថា គាត់មិនអាចយកឈ្នះពួកឯងទេ តែគាត់នៅតែតស៊ូដើម្បីប្អូន....គាត់នៅតែទៅប្រកួតទាំងគ្មាន សង្ឃឹម...»

ប៉េងផ្អាកនិយាយព្រោះមាត់ចាប់ផ្ដើមញ័រហើយទឹកភ្នែកគាត់ធ្លាក់ខ្វាយដូចមនុស្សស្រី។ ប៉ែន ពេជ្រ ងក់ក្បាលផ្ងក់ៗបានន័យថាគាត់នឹកឃើញរឿងអស់នោះហើយ គ្រាន់តែប៉េងចាប់ផ្ដើមតំណាលនេះ។ ហួត ស៊ីវ បែរមករក ប៉ែន ពេជ្រ ភ្លាម ទោះបីមុខរបួសធ្វើទុក្ខគាត់ល្វើយយ៉ាងណា តែគាត់ចង់ដឹងអតីតកាលនោះច្រើនជាងរវល់នឹងឈាមដែលហូរជោក។

ប៉ែន ពេជ្រ និយាយម្ដង៖

«យើងដឹងហើយប៉េង! ថ្ងៃនោះមុនពេលទៅក្រុមហ៊ុន បងរាជបានមកទិញទឹកត្រជាក់របស់ឯងដូចរាល់ដង! អញ្ចឹងហើយបងប្អូនដ៏កំសាកឯងបាននាំគ្នាលេងល្បិចលួចបន្លំឯកសារ របស់គាត់ដោយប្ដូរឯកសារគ្មានន័យខ្លឹមសារមក ឱ្យគាត់វិញ! ចុងក្រោយម្ចាស់ក្រុមហ៊ុនគេមិនល្ងង់ គេក៏ឱ្យទាំងពីរនាក់ឡើងធ្វើ បទបង្ហាញ! ម្ចាស់គម្រោងពិតប្រាកដមានរឿង អីនិយាយមិនល្អជាងអ្នកលួចគេ! បងប្រុសឯងក្រោយមកត្រូវគេបណ្ដេញចេញ វាជារឿងត្រឹមត្រូវហេតុអ្វីឯងត្រូវគុំកួន!»

ហួត ស៊ីវ ហួសចិត្តឮថាជាអ្នករកស៊ីពូកែម្នាក់ដែលមានអំណាចធ្លាប់អនុញ្ញាត ដល់គម្រោងការជាច្រើនគាត់គិតមិនយល់ថាហេតុអ្វី មានរឿងលួចបន្លំដូច្នេះកើតឡើងទៅរួចដែរ?។

គាត់និយាយទាំងសើចចំអកៈ
«អញ្ចឹងសោះ?»

ហួត ស៊ីវ សើចហើយនិយាយបន្តទាំងមុខរបួសហូរឈាមខុរៈ

«តែរឿងនោះជារឿងបងរាជ ហេតុអ្វីបានជាឯងមកគុំកួនម្តងទាំងបួននាក់? បងប្អូនឯងពីរនាក់នេះមិនត្រឹមតែម្នាក់ជាចោរទុច្ចរិតថែមទាំង ម្នាក់អស្មិមានះ មិនចេះចែកខុសត្រូវ តើឯងមកគុំកួនរាប់សិបឆ្នាំហ្នឹងសមដែរទេ? កោតតែអញខំធ្វើល្អទុកឯងដូចប្អូនម្នាក់!»

ប៉េងគំហកទាំងទឹកភ្នែកស្រោក់ៈ
«បិទមាត់! បងអញស្លាប់ហើយអញអត់ត្រូវការអាណាផ្សេងមកធ្វើបងអញទៀតទេ! អញត្រូវការតែសងសឹក! ឯងពូកែធ្វើពើណាស់ឯងថាឯងមិនដឹងអី ហេតុអ្វីអញគុំ? ចុះឯងនៅចាំទេថ្ងៃដែលសាលាប្រកាសអាហារូបករណ៍ទៅចិន?? អាហ៊ាអញជាសិស្សក្រីក្ររបស់សាលា គាត់ត្រូវគេចុចឈ្មោះឱ្យទៅ គាត់រៀបចំឯកសាររួចរាល់ហើយត្រូវការតែលិខិតថ្កោលទោសនាយកហៅសិស្សៗទៅជួប សួរនាំ ពួកឯងបួននាក់គួរតែជួយលាក់រឿងគាត់លួចឯកសារនោះដើម្បីឱ្យគាត់ បានចេញទៅរៀន ដឹងអីបន្ទាប់ពីនាយកជួបពួកឯងបួននាក់ហើយគេដូរចិត្តលែងឱ្យអាហ៊ាអញទៅវិញ! មនុស្សដែលមិនធ្លាប់មានសង្ឃឹមទីបំផុតត្រូវគេបន្តក់ក្តីសង្ឃឹមឱ្យហើយចុងក្រោយត្រូវពួកឯង បណ្តាច់យកទៅវិញបាត់ ឯងយល់ថា អញគួរអរគុណពួកឯងទេដែលធ្វើឱ្យហ៊ាអញដាច់ចិត្តសម្លាប់ខ្លួន?»
និយាយមិនទាន់ផុតពីមាត់ប៉េងកេះកែបាញ់តម្រង់ ហួត ស៊ីវ សាជាថ្មីទៅតាមកំហឹងចិត្តដែលកាន់តែកើនឡើង ពេលរំលឹកដល់រឿងគួរឱ្យឈឺចាប់ទាំងនោះ។ គេប្រហែលសង្ឃឹមថាគ្រាប់ទីពីរនេះ នឹងធ្វើឱ្យអគ្គទេសាភិបាលដាច់ជីវិត ទៅជាការសម្រាលកំហឹងឱ្យគាត់បានភ្លាមៗ សឹមងាកមកចាត់ការ ប៉ែន ពេជ្រ ដ៏ទុរន់ទុរានោះជាក្រោយ តែដឹងអីឧកញ៉ានោះស្រាប់តែមាន

កម្លាំងអព្ភូតហេតុហើយបែរទទួលពាំង គ្រាប់នោះជំនួសមិត្តគាត់។
«ឯងឆ្កួតហើយអាពេជ្រ!» ហួត ស៊ីវ ស្រែកដោយបើកភ្នែកធំៗ។

ប៉ែន ពេជ្រ ឱបទ្រូងដែលរងគ្រាប់។

ភ្នែកគាត់ចាប់ព្រិល តែមាត់នៅនិយាយបាន៖

«អាប៉េង ឯងច្រឡំហើយ! គឺបងឯងយល់ច្រឡំ! អ្នកដែលរាយការណ៍ប្រាប់នាយកនៅថ្ងៃនោះមិនមែន ហួត ស៊ីវ ក៏មិនមែនបងរាជហើយក៏មិនមែនអាយុទ្ធដែរ គឺអញតែម្នាក់គត់! អញស្អប់ណាស់អ្នកបន្លំលួចរបស់គេតាំងពីដើមមក! បងឯងចិត្តមិនត្រង់ ធ្វើរឿងអញ្ចឹងៗទៅស្រុកគេនាំតែបង្ករឿងខូចឈ្មោះសាលាទេមិនបាន ទៅចិនគឺដោយសារអញ! ឯងចាត់ការអញមកចុះ!»

«ឯងឈប់និយាយហេតុផលជាមួយគ្នាទៅអាពេជ្រ!»
ហួត ស៊ីវ គំហកដោយតក់ស្លុតព្រោះ ប៉ែន ពេជ្រ មានសញ្ញាបាត់បង់ស្មារតីបន្តិចម្តងៗទៅហើយតែគាត់នៅតែប្រឹងតបត៖
«អាស៊ីវ! ទោះអញនៅរស់ក៏ដើរចុះពីនេះមិនរួចដែរ! គ្នាយើងបួននាក់គួរតែមានម្នាក់នៅ! ឯងតស៊ូឡើង! ហើយប្រាប់ក្មេងៗកុំឡើយចងគំនុំគ្នា!»
គាត់បិទភ្នែកជិតឈឹង ទន់ដៃខ្សាកនៅចំពោះមុខភាពរន្ធត់របស់ ហួត ស៊ីវ។
ប៉េងសើចក្អាកក្អាយក្រោមទុក្ខសោករបស់បុរសចំណាស់ទាំងទ្វេ គេនិយាយកាត់៖
«គ្នាឯងបួននាក់គ្មានអាណាមួយរស់បានទាំងអស់!»
ស្នូរកាំភ្លើងផ្ទុះធូង សាជាថ្មីជាពេលដែល ហួត ស៊ីវ ធ្មេចភ្នែករង់ចាំទទួលការទៅកាន់ឋានយមរាជដោយគ្មានអ្វីនឹងតដៃទៀត ឡើយ ដឹងអីគាត់ហាក់មិនបានទទួលអារម្មណ៍ណាមួយថាខ្លួនត្រូវគ្រាប់ទៀត សោះ បែរជាឮសម្រែកស្រួយស្រើបរបស់ពៅបញ្ញា ៖
«ប៉ា!!»
ហួត ស៊ីវ ក៏បើកភ្នែកឡើងវិញសន្សឹមៗក្នុងពេលមេធាវីតូចបង្ហាញខ្លួនហើយរត់ទាំងទឹកភ្នែកមករកលោកប៉ានាង។

តាមពិតចំពោះមុខគាត់ ..ប៉េងទេដែលត្រូវមួយគ្រាប់ចំកដៃហូរឈាមរហាម ហើយរបូត កាំភ្លើងទៅលើកម្រាលស៊ីម៉ង់។ នៅក្បែរនោះ យុត្តនាមុខក្រហមងៅឈរភ្នង់គាត់នៅឡើយ.....

«ឯងមិនទាន់ទៅទេ????» ប៉េងសួរឡើងទាំងឈឺចាប់....។

«នៅទេ!....គឺនៅរង់ចាំស្តាប់ការពិតដែលឯងសារភាពថាឯងជាអ្នកសម្លាប់ប៉ាខ្ញុំ!» គេឆ្លើយវិញមួយៗ។

តាមពិតយុត្តនាបានចាកចេញទៅតាំងចិត្តលែងរវល់នឹងអ្វីៗនៅ ទីនេះ តាំងពីគេខូចចិត្តយ៉ាងធ្ងន់ដោយបានស្តាប់ឮនូវអតីតកាលដ៏ហែកហួរ រវាងចាស់ៗប៉ុន្មាននាក់នេះ។

គេឡើងដល់ឡានដែលមាននារីអ្នកច្បាប់នៅទន្ទឹងរង់ចាំជាស្រេចនោះ ប៉ុន្តែស្នូរគ្រាប់កាំភ្លើងដំបូងដែលប៉េងបាញ់ស្នា ហួត ស៊ីវ បានធ្វើឱ្យគេសម្រេចចិត្តបកឡើងមកវិញព្រោះគេនៅតែមិនដាច់ចិត្ត។

ទីបំផុតគេក៏មកទាន់ចំពេលដែលប៉េងបានលាតត្រដាងការពិត ពីមរណភាពឪពុកខ្លួនដែលមានជំងឺលើសឈាមលើផ្ទះសារិកាកែវជាន់ទីបួន នោះ។

ទឹកមុខរបស់គេ និងកំហឹងក្នុងភ្នែកគេទាំងគូក្នុងពេលនេះ ធ្វើឱ្យ ហួត ស៊ីវ ដឹងថា ទោះទេវតាក៏មិនអាចឃាត់គេមិនឱ្យកេះកៃជាលើកទីពីរដែរ តែគាត់នៅតែព្យាយាមឃាត់៖

«កុំសម្លាប់វា! រកប្អូនប្រុសឯងឱ្យឃើញសិន!»

យុត្តនាបើកភ្នែកធំៗ គេនឹកឃើញភ្លាមដល់រិទ្ធិនិងសក្ខណា។ គេហើបមាត់សម្លុតបុរសចំណាស់ដែលកំពុងឱបកដៃរបួសនោះ៖

«ប្រុសស្រីពីរនាក់នោះ នៅឯណា?»

ប៉េងសើចជ្រួញអស់ទាំងភ្នែកតូចហើយលឹបទាំងទ្វេ៖

«ក្រែងឯងពូកែណាស់ហ្អី? ក្រែងដៃជើងអ្នួទាំងអស់ឯងសម្លុតបានអស់ហើយហ្អី? ម៉ោសួរធ្វើអី?»

យុត្តនារេចុងភ្នែកសម្លក់បុរសសម្បុរល្បិច នាយដឹងថាម្នាក់នេះមិនខ្លាចសូម្បីសេចក្តីស្លាប់ទៅហើយមានរឿងអី គេព្រមលេងអ្នកប្រុសរបស់ ហួត ស៊ីវ និង អ្នកនាងតូចនៃផ្ទះប៉ែន ពេជ្រ មកវិញងាយៗនោះ? អ្នកប្រុសពោលសង្កត់ពាក្យមួយៗ៖

«និយាយម៉ោ! ឯងចង់បានអី ដើម្បីដូរពីរនាក់គេមកវិញ?»

ប៉េងវិញសើចរលាក់៖
«អញបញ្ជូនវាទៅឆ្ងាយហើយ! អ្នកបញ្ជូនវាទៅមិនមែនជាមនុស្សដែលឯងស្គាល់ទេហើយក៏គ្មានអាណា ស្គាល់ពួកវាដែរ! ឯងចប់ហើយហាសហា!»
ពៅបញ្ញាងើបមុខសម្លឹងយុត្តនាទាំងយំសស្រាក់៖
«យុត្តនា!....ខ្ញុំត្រូវការនាំប៉ាខ្ញុំទៅពេទ្យ! ឆាប់....ប្រញាប់ឡើង!»
អ្នកប្រុសបែកអារម្មណ៍ពេលឮសម្រែកនាងតក់ស្លុតយ៉ាងនេះ។ គេបែរទៅរកបុរសចំណាស់ដែលគេធ្លាប់ចិញ្ចឹមចិត្តស្អប់គាត់ជាងម្ភៃ ឆ្នាំមកហើយ។ ប៉េងឆ្លៀតឱកាសហក់រឹងបំបុកកាំភ្លើងពីដៃអ្នកហើយ លោតផ្លោត បង្ហួសបង្កាន់ដៃ សំដៅទៅរានហាលជាន់បន្ទាប់ដែលមានបើកភ្លើង ត្រៀមរួចជាស្រេច។
យុត្តនារត់ទៅតាមពីក្រោយបុរសកំហូចក្នុងពេលដែលដៃនាយទាញកញ្ឆក់ បានត្រឹមតែអាវគាត់ហើយរហែកមកខ្វាក។ អ្នកសម្លឹងចុះទៅក្រោមឃើញជននោះ ស្រវាតោងឧបករណ៍បន្តោងសម្ភារៈសំណង់ហើយរវៃសម្រូតខ្លួនចុះក្រោមបន្តទៅទៀត។
តាមពិតអ្នកនៅតែអាចដេញទាន់គាត់ តែសម្រែករបស់ពៅបញ្ញាលាន់ឡើងសាជាថ្មី៖
«ប៉ា????»
គេបោះបង់ចោលប៉េងហើយ ងាកមករក ប៉ែន ពេជ្រ។ គាត់ហូរឈាមជោគទ្រូងឯទឹកមុខក៏ស្លេកស្លាំង។
ស្ថានភាពដេកស្ងៀមគ្មានកម្រើកក្នុងរង្វង់ដៃកូនស្រីពៅ គឺជាស្ថានភាពដែលយុត្តនាយល់ថាមិនអាចអូសបន្លាយបានទៀតឡើយ។
គេលើកទូរសព្ទមកចុចហៅឡានពេទ្យ....រួចទើបដើរមកបញ្ចិះគាត់ដាក់លើខ្នង....ហើយនិយាយតិចៗទៅកាន់ស្រីតូចដែលយំសស្រាក់។
«គ្រាប៉ាខ្ញុំចុះមក!»

នារីគ្រា ហួត ស៊ីវ ដែលមានស្ថានភាពរបួសស្រាលជាងឪពុកនាងឆ្ងាយ។ គាត់ដៃម្ខាងខ្ទប់របួសលើស្មាតែគាត់នៅតែអាចដើរបានយ៉ាងនឹង គ្រាន់តែត្រូវការនាងជួយទប់ខ្លះ ខុសពីឪពុកនាងដែលត្រូវផ្តួលទាំងស្រុងទៅលើខ្នងអ្នកប្រុសទីមួយ គឺគាត់លែងដឹងខ្លួនទៅហើយ។
នៅតាមផ្លូវចុះជណ្តើរ ទៅជាន់ខាងក្រោមនាងតាមសម្លឹងយុត្តនាភ្លឹះៗចំពេលគេងាកមកមើលនាងដូចគ្នា។ ក្នុងគ្រានេះហើយគេនៅតែ មិចភ្នែកជាសញ្ញាឱ្យនាងមានសង្ឃឹមទៀត។ នារី

ជ្រួញចិញ្ចើមប្រឹងទប់ទឹកភ្នែកហើយប្រឹងញញឹមជាសញ្ញាតបថា អរគុណគេណាស់ដែលព្រម ជួយប៉ានាង។
«ប៉ែន ពេជ្រ! ខ្ញុំបញ្ចិះលោកទៅមិនមែនព្រោះតែខ្ញុំយល់ពៅបញ្ញាតែមួយមុខទេ! គឺខ្ញុំត្រូវសង លោកនូវកំហុសដែលចិញ្ចឹមចិត្តគុំកួននិងបញ្ឈឺលោក អស់ច្រើនឆ្នាំមកនេះ! បើកុំតែលើកនេះ ខ្ញុំមិនដាច់ចិត្តពីពុកធម៌ខ្ញុំ ហើយបកឡើងមកលើវិញ ខ្ញុំមិនបានដឹងការពិតអស់នេះឡើយ ហើយមុខតែលេខាប៉េង បោកប្រាស់ខ្ញុំប្រើ អស់មួយជីវិតនេះមិនខាន!»
....គេគិតក្នុងចិត្តហើយក៏ងាកសម្លឹងស្រីស្អាតសាជាថ្មី ដែលកន្លងមកគេស្អប់គ្រួសារនាងយ៉ាង ណា ក៏មិនដែលបានធ្វើអ្វីឱ្យលើសលស់ចំពោះនាង ព្រោះតែគេ មាននាងពេញក្នុងបេះដូង ទៅហើយ។សំឡេងនាងកាលពីល្ងាចមិញលាន់មកវិញ ក្នុងចិត្តនរៈយើង៖
«មនុស្សស្រលាញ់គ្នាឯណា គេទៅចោលគ្នាក្នុងពេលពិបាកៗអញ្ចឹង?»
....គេញញឹមងាកមុខចេញតែបេះដូងថតរូបនាងរក្សាទុកយ៉ាងជ្រៅ.....

## ជំពូក២

បុត្រាច្បងរបស់ ប៉ែន ពេជ្រ

.....ដូចពាក្យចាស់ចំណាំតែលើកថា យីអ៊ុនដាក់អារក្សជាន់ វាគឺស្ថានភាពពិតរបស់បុស្បានារី ក្នុងពេលនេះហើយ។
ក្នុងការចុះដូរយន្តហោះនៅប្រលានសុវណ្ណភូមិក្រុងបាងកក បុប្ផានារីដ៏ក្រៀមក្រំបានបោះបង់ ចោលការបន្តជើងយន្តហោះទៅជប៉ុន ដោយនាងនៅរង់ចាំជើងយន្តហោះវិលបកមកកាន់កម្ពុ ជាវិញ។

ទឹកភ្នែកជូតមិនទាន់ស្ងួត ស្រីស្អាតដែលអ្នកណាៗក៏តាមមើល បានបញ្ឈប់ជើងនាងនៅមុខ ហាងទំនិញមួយក្នុងបរិវេណពាណិជ្ជកម្មរបស់ ប្រលានយន្តហោះដោយសារនាងវាក់អើនឹង បុរសស្រស់សង្ហា អតីតសង្សារគឺ ប៉ែន ពេជ្រប្រាថ្នា ដែលស្រូតរូតមកភ្នំពេញវិញដូចគ្នា។ ដែលរឹតតែគួរឱ្យនារីជាដួងតារាទោមនស្សនោះគឺគេបង្ហាញខ្លួនដោយ មានបណ្ដើរនារីឆើត ឆាយម្នាក់ទៀត គួរឲ្យទើសភ្នែក។
ទោះចិត្តមិនចង់ ក៏ច្បាស់ត្រូវគេវាងចូលទៅក្នុងហាងទំនិញមួយក្បែរនោះ ព្រោះមិនចង់ជួប នាយឡើយទោះបីសង្ស័យថាអាចនឹងឡើងយន្តហោះជើងជាមួយ គ្នាត្រលប់មកភ្នំពេញវិញ

ក្ដី។
«អ្នកនាងចង់បានទំនិញនេះ? វាទើបមកដល់ទេ!»
នារីអ្នកលក់និយាយមកកាន់ធីតាយើង ព្រោះជាធម្មតាប្រសិនបើនាងឈានចូលហាងគេគេត្រូវតែមកទទួលរាក់ទាក់។
បុស្បាញញឹមទាំងបង្ខំចិត្ត ៖
«អូខេសុំមើលសិន!»
ផលិតផលពិតជាល្អគាប់ភ្នែកសមទៅនឹងយីហោល្បីរបស់ហាង ប៉ុន្តែខ្ទង់ចំណាយគឺខ្ពស់ហួសហេតុ។នាងសងវាទៅឱ្យអ្នកលក់វិញ៖
«អត់ទេ! ថ្លៃពេកហើយ! អរគុណ!»
នាងបែរក្រោយចាកចេញ ព្រោះការមិនទិញទំនិញគឺគ្មានហេតុផលផ្សេងសម្រាប់គេចខ្លួននៅទីនេះបានយូរទេ។
«អត់ទេ! សូមខ្ចប់មក! របស់ដែលនាងមើលទាំងនេះ!»
សំឡេងគេធ្វើឱ្យនាងជ្រួញចិញ្ចើម។

ទីបំផុតគេពិតជាឃើញនាងមែន ហើយបោះចោលស្រីតូចឆើតឆាយនោះនៅទីណាមិនដឹងបែរជាចូលមករកនាង ក្នុងនេះរហ័សដូចផ្លេកបន្ទោរ។
គេគឺកូនប្រុសច្បងរបស់ឧកញ៉ា ប៉ែន ពេជ្រ ដ៏ល្បីឈ្មោះនៅភ្នំពេញហើយដូចរាល់ដងអញ្ចឹងគេមិនដែលកំណាញ់ដៃក្នុងការទិញទំនិញផ្គាប់ចិត្តស្រីៗទេ។
បុស្បាងើបមុខដ៏ក្រៀមក្រំសម្លឹងបុរសនោះមាត់នាងបញ្ជាក់៖
«បើទិញឱ្យគេនោះ បងទិញទៅ!»
ប៉ែន ពេជ្រប្រាថ្នា តែងតែយល់ថាក្រៅពីគេសង្ហាហើយមានប្រាក់ គេក៏ត្រូវតែមានលក្ខណៈទន់ភ្លន់ជាមួយស្រីៗជានិច្ចដូច្នេះហើយគេ តែងញញឹមទោះដឹងថានាងកំពុងមិនសប្បាយចិត្តក៏ដោយ៖
«ទិញឱ្យអ្នកនិយាយហ្នឹងហើយ!»
បុស្បាបង្ហាញភាពស្រងូតស្រងាត់។ ជាការពិតគឺនាងគ្មានចិត្តនឹងវត្ថុទាំងនេះពិតមែនដោយសារតែការខក បំណងដ៏ធ្ងន់កាលពីល្ងាច។ នាងដឹងថាប្រកែកទៀតក៏គង់ហត់នឿយមានតែបណ្ដោយឲ្យគេចាយលុយ តាមដំណើរ។

ក្នុងពេលដែលបេះដូងនារីម្នាក់លែងមានរូបបុរសនោះទៀត ប្រាថ្នារកមើលយ៉ាងណាក៏មិនឃើញភាពត្រេកត្រអាលរបស់នាងលេចឡើង ក្នុងពេលនាយបង្ហាញខ្លួនដែរ ប៉ុន្តែប្រការនេះមិនបានជួយបុស្បានារីឡើយ វាមានតែធ្វើឱ្យភាគីខាងបុរសចង់ដឹងហេតុផលពិតថាអ្វីទៅដែល ធ្វើឱ្យនាងដាច់ចិត្តពីគេបាន?

«មកពីណា?»គេសួរកំបុតដូចមនុស្សស្និទ្ធស្នេហា។

នាងរវេភ្នែកគិត ក៏មិនចង់ឱ្យគេដឹងថានាងមានគម្រោងចេញទៅជប៉ុនហើយមកទើរនៅទីនេះស្រីស្អាតនិយាយបន្លប់៖

«ខ្ញុំទៅភ្នំពេញវិញ!»

«ជួនគ្នាណាស់! បងក៏កំពុងទៅវិញដែរ!»

តរុណីចាកចេញមកអង្គុយលើកៅអីខាងក្រៅហាង។ គេនៅតែតាមមក នេះជាសារជាតិពិតរបស់បុរសមានប្រាក់និងមាននារីច្រើនក្នុងជីវិត គេ។

ទោះបីគេបានបោះបង់នាងចោលរយៈពេលយូរ តែគេនៅតែចាត់ទុកនាងជារបស់គេជានិច្ចមិនខ្វល់ពីអារម្មណ៍ភាគី ខាងស្រីឡើយ។ សម្លឹងឃើញភាពឆ្មើងឆ្មៃរបស់នាងទៀត គេកាន់តែកើតចិត្តចង់គ្រប់គ្រងសូម្បីតែអ្វីដែលនាងកំពុងតែគិត។

«បើកុំតែអ្នកផ្ទះមានបញ្ហា! ឱ្យទៅវិញបន្ទាន់ បងនឹងនាំស្រីស្អាតរបស់បងដើរបង្អើលប្រុសៗនៅបាងកកនេះម្តងទៀត!»

នាងដៀងភ្នែកគិត…មិនមែនមកពីសម្តីលែបខាយរបស់នាយទេ ប៉ុន្តែគឺគិតពីអ្វីៗដែលកំពុងកើតឡើងនៅកម្ពុជា។

នាងដឹងថាផ្ទះគេមានរឿងព្រោះគេបាត់ប្អូនស្រីគេហើយពូនាង កំពុងរៀបចំការងារទុច្ចរិតដែលនាងភ័យខ្លាចយ៉ាងចប់ដង្ហើម។ ហេតុហ្នឹងហើយបានជាគាត់តម្រូវឱ្យនាងនាំយុត្តនាចាកចេញតែគេគ្មាន ស្នេហាចំពោះនាង បានជានាងត្រូវបរាជ័យយ៉ាងដំណំ។

កាន់តែគិតពីគេនាងកាន់តែឈឺចិត្តហើយស្អប់មនុស្សប្រុសទាំងឡាយរួម ទាំងម្នាក់នៅក្បែរខ្លួនដែលជាស្នេហាដំបូងរបស់នាងនេះផង។

នាងរវេភ្នែកសម្លឹងទៅភាពជាអភិជននិងកាយវិការជាសុភាពបុរសក្នុង ស្រោមព្រាននារីរបស់គេ នាងក៏នឹកឃើញដល់ស្រីតូចសម្បុរស្បែកស្រអែមដែលប្រើត្រកូលជាមួយ គេ…គឺមេធាវី

ដែលមានសំណាងជាងនាង ក្នុងរឿងមនោសញ្ចេតនា។
«ពៅបញ្ញា! បើយើងមិនបានយុត្តនា យើងនឹងជាន់ឈ្លីគ្រួសារឯង ពិសេសព្រាននារីនេះ! បាត់ប្អូនហើយនៅតែដើរសប្បាយចែចង់ស្រី! គឺលោកមករកខ្ញុំវិញដោយខ្លួនឯង ប៉ែន ពេជ្រប្រាថ្នា! ខ្ញុំប្រើហ្លួត យុត្តនា មិនបានលោកក៏ជាកូនអុកល្អគ្រាន់បើដែរ!»

នាងគិតយ៉ាងរហ័សហើយ បបូរមាត់ពោលពីរឿងផ្សេង៖

«អញ្ចឹងពេលណាទើបបងនាំអូនដើរទិញអីវ៉ាន់ទូទាំងបាងកកនេះបាន?»

ភាពប្រែប្រួលភ្លាមៗរបស់ស្រីស្អាតធ្វើឱ្យបុរសសង្ហាយល់ខុសថាតាម ពិតគឺនាងនៅតែអាល័យនាយគ្រាន់តែមុននេះនាងង៉ក់ងរព្រោះតែ ឃើញខ្លួនបណ្តើរស្រីថៃទិញទំនិញប៉ុណ្ណោះ។ គេញញឹម ធ្វើកិច្ចសន្យាផ្ទាល់មាត់ភ្លាមៗ៖
«ពេលណាក៏បាន! ឱ្យតែបងដោះស្រាយរឿងអ្នកផ្ទះរួចសិន! អូខេ?»

បុស្បាសើចតិចៗក្នុងក្រសែភ្នែកស្លូតបូត ដែលភ្ជាប់ជាមួយល្បិចកលក្នុងជម្រៅបេះដូង។ប្រសិនបើនាងត្រូវបង្រៀន មកដើម្បីតែលាក់ពុត គឺវាមុខតែបានលទ្ធផលដូច្នេះហើយគឺភាពច្រណែននិន្ទានិងមិនសុខ ចិត្ត អាចធ្វើឱ្យមនុស្សបង្កើតគំនុំបំផ្លាញភាពសប្បុរសរបស់ខ្លួនបាន។
ស្មូរទូរសព្ទរោទ៍ឡើង។ អភិជនកំលោះលើកទទួលភ្លែតព្រោះជាលេខអ្នកម្តាយ។ គេថ្លោះទឹកមុខក្រោម ការតាមដានរបស់នារីដួងតារា។
«៣០នាទីទៀតយន្តហោះឡើងហើយជំទាវម៉ាក់! កូនកំពុងប្រញាប់ទៅដល់ឱ្យបានលឿនបំផុតហើយ!»
បន្ទាប់មកគេងើបមុខសម្លឹងScreenតារាងហោះហើរ ដែលភាពអន្ទះសារបស់គេមិនអាចលាក់កំបាំងពីបុប្ផាស្រស់បានឡើយ។
«តើគេមានរឿងអីបានជាប្រញាប់យ៉ាងនេះ? ពួយើងបានធ្វើអ្វីប្អូនស្រីគេនិងប៉ាគេពិតមែនទេ? យុត្តនាមិនបានមកទេ តើពួយើងមានគ្រោះថ្នាក់ដែរឬយ៉ាងណា?»
នាងងើបមុខញញឹមស្លូតទៅរកនាយ៖

«អូនទៅបន្ទប់ទឹកសិន!»

បុរសងក់ក្បាលឯនារីបានឱកាសចូលទៅទីកំបាំងហើយចាប់ទូរសព្ទទៅរក ពូនាងជាបន្ទាន់។ នាងខលច្រើនដងណាស់មិនឃើញគាត់លើកក៏ប្ដូរទៅរក លេខផ្សេងមួយទៀតដោយទឹកមុខស្លេកស្លាំង។វាជាលេខដែលទុកប្រើ សម្រាប់នាងនឹងគាត់តែប៉ុណ្ណោះ ទម្រាំឮសូរលេខាប៉េងលើកស្រីស្អាតដកដង្ហើមយូរ៖

«ពូ! ពូនៅខាងណោះយ៉ាងម៉េចហើយ?»

«ហើយឯងនៅឯណានេះ?»

«ពូមិនអីទេអ្អេស់! ខ្ញុំ...ខ្ញុំនៅបាងកក កំពុងចាំឡើងយន្តហោះត្រលប់ទៅភ្នំពេញវិញ!»

ប៉េងនៅស្ងៀមទំនងរិះគិត មួយខណៈទើបតបទៀត៖

«អើ! មកវិញក៏ល្អ! »

«ចុះពូមានកើតអីអត់?»

«ចុះឯងគិតថា ពូកើតស្អី? ហាសហា! ឯងចាំតែលេងល្ខោនបន្តទៅ! ស្មានតែពួកវាបានសប្បាយ ដូចបំណងមែន! រឿងមិនទាន់ចប់នៅឡើយបុស្បា! អាអ្នកប្រុសទីពីរនិងក្មេងស្រីមកពីអាមេរិកនោះ ពួកវាគ្មានថ្ងៃមកផ្ទះវិញកើតទេ!»

បុស្បាក្ដុកក្ដាក់ក្នុងចិត្ត នាងមិនដឹងថាតើដំណើរការនៅទីនោះវិវត្តដល់ណាហើយទេ តើនាងអាចជួបមុខពួកគេបានទៀតដែរឬមួយក៏តទៅត្រូវគេចពីអ្នក ទាំងនោះ? នាងឱបដៃទាំងភ័យចេញចំហាយមុខក្ដៅភាយៗ។

គិតច្រើនក៏អត់ប្រយោជន៍ដូច្នោះហើយបានជាការសម្រេចចិត្តវិលទៅនៅ កៀកនឹងស្ថានការណ៍ទើបជាមធ្យោបាយល្អក្នុងស្វែងរកដំណោះស្រាយក្នុង ពេលនេះ។

## ជំពូក៣

## លើផ្លូវវែងឆ្ងាយ

.....រថយន្តចេញដំណើរបានជិត២ម៉ោងហើយក្រោមការអត់ធ្មត់របស់អ្នក ប្រុសទីពីរ.....

ចំណែកសក្ខណាវិញនាងហាក់ស្វាត់សូន្យឈឹងមិនដឹង នាងសន្លប់ឬសំងំយកកម្លាំងដែរនោះទេ។

....ត្រចៀកនរៈយើងផ្ទៀងស្ដាប់ក្រែងលោបានឮអ្វីពិសេសៗនឹងអាចចំណាំ ពីតំបន់ដែលខ្លួន

កំពុងឆ្ពោះទៅ តែក្រៅពីសន្ទឹកឡានទង្គិចនឹងស្លឹកឈើ គឺមិនមានអ្វីពិសេសអាចឲ្យអ្នកប្រុសសម្គាល់បានឡើយ.....គេលបលួច សម្លឹងទៅខាងក្រៅការុងសាជាថ្មី....ម្នាក់ដែលមានតួនាទីយាមកាមពួក ចំណាប់ខ្មាំងនេះកំពុងអង្គុយខែងរ៉ែងគ្មានបង្ហាញថាគេអស់កម្លាំង ស្វាបឬទម្រេតខ្លួនឡើយ។ សេចក្ដីសង្ឃឹមរបស់អ្នកប្រុសនៅតែឆ្ងាយសន្លឹម.....
ទោះយ៉ាងនោះក៏ដោយ....ការអត់ធ្មត់នៅតែជាមធ្យោបាយនិងជាបណ្ដុះ សុទិដ្ឋិនិយមក្នុងកាលៈទេសៈនេះ។ គេធ្មេចវិញ ....ហើយល្បឿនរថយន្ត ចាប់ផ្ដើមលឿនជាងមុន។ វិទ្ធិដឹងថាពួកវាទំនងជាបានមកដល់ផ្លូវត្រង់ថ្មីណាមួយ ដែលចរាចរណ៍ស្ងាត់និងទូលាយល្អអំណោយផលដល់ការបញ្ជាន់លេខហើយ។ ការស្មានព្រាវៗនឹងប្រឹងតាមដានស្ដាប់មិនហ៊ានប្រហែស ជាអ្វីដែលអ្នកប្រុសបានប្រកាន់យក។

.....តែមិនដល់១០នាទីក្រោយផង សូរសម្លេងដ៏ពីរោះមួយលាន់ឡើងគ្រលួចកំដរស្បៃរាត្រី....វាជាសំឡេង ច្រៀងកំដរភាពអផ្សុករបស់អ្នកលេងទីបីដែលនៅយាមអ្នកប្រុសនៅ ក្បែរកាយនេះឯង។ ប្រសិនបើស្ថិតក្នុងស្ថានភាពដដែលអ្នកប្រុសទីពីរប្រហែលត្រូវអស់ សំណើចព្រោះបុរសនោះជាអ្នកលេងនិងមានចរិតគំហកកំហែង ប៉ុន្ដែហេតុអ្វីសំឡេងគេច្រៀងពីរោះរណ្ដំ?....ប្រហែលមកពីយ៉ាងនេះហើយ បាន គេប្រឹងច្រៀងបន្ដមួយបទហើយមួយបទទៀតមិនសម្រាក?
«វាស្ដាប់កាសហើយច្រៀងទេដឹង?»គំនិតមួយលេចភ្លែតមកជាមួយក្ដី សង្ឃឹមថ្មី។ ប្រសិនបើដូច្នោះមែនឱកាសល្អចាប់ផ្ដើមបង្ហាញរូបរាង។ បន្ថែមពីលើនោះ ....ផ្គរស្រោប់តែគ្រហឹមពីជើងពីត្បូងបណ្ដាក់គ្នារអឹក....
....វិទ្ធិលេចចេញនូវស្នាមញញឹមលើបបូរមាត់ដោយមិនដឹងខ្លួន ព្រោះអ្នកប្រុសមានជំនឿថាតំណក់ទឹកភ្លៀងនឹងជួយសម្រួលដល់ផែនការ រត់គេចនេះមួយផ្នែកធំ។...អ្នកលបសម្លឹងទៅក្រៅម្ដងទៀត ក៏ឃើញជននោះអង្គុយបែរខ្នងទៅផ្លូវ មានលើកក្រណាត់កៅស៊ូសំណេល់អាវភ្លៀង គ្របក្បាលបង្ការជាស្រេចក្រែងទីនេះជាស្រុកព្រៃ ផ្គរគ្រហឹមមួយអឺះ ក៏ភ្លៀងអាចធ្លាក់រ៉ាវទទឹកអស់ភ្លាមៗបាន។
គេហាក់បោះបង់ចោលការប្រុងប្រយ័ត្នលើអ្នកជាប់ចំណងប្រហែលសំអាងលើ ល្បឿនឡានលឿនហើយប្រុសស្រីក្នុងការុងក៏ហាក់ស្ងៀមស្ងាត់ដូចជាកំពុង សន្លប់ធំក្នុងចំណង។

...បុរសនោះចាប់ផ្ដើមប្ដូរបទចម្រៀងថ្មី ឯភ្លៀងក៏ធ្លាក់រ៉ាវមែនធ្វើឲ្យគេនោះបញ្ឈប់បទចម្រៀង ប្ដូរមកជារអ៊ូរទាំៈ
«រំបល់យក៏វា! អញថាភ្លៀង ភ្លៀងមែន!»
គេច្របូកច្របល់លាកំណាត់សំពត់កៅស៊ូ រិទ្ធិក៏សម្លឹងទៅក្រៅមិនហ៊ានប្រហែសដែរ។ ម្ដង ម្កាលជននោះងាកមកហាក់បីដូចជាប្រុងឃ្លាំមើលប្រតិកម្មអ្នក តែដល់មិនឃើញអ្វីប្លែកវាក៏នៅ សំងំក្នុងកំណាត់ភ្លៀងវិញព្រោះមិន ចង់ទទឹក។ រថយន្តបន្ថយល្បឿនប្រហែលមកពីអាពីរនាក់ នៅខាងមុខគិតដល់ពួកម៉ាក វានៅខាងក្រោយនេះដែរ។
រិទ្ធិបានប្ដូរដៃពីក្រោយខ្នងមកខាងមុខអស់ ហើយក្ដាប់ដៃចុះឡើងបន្ថែមកម្លាំងឲ្យខ្លួនឯង។ គេ ចាប់ដកស្កុតចេញពីមាត់ខ្លួនឯងថ្នមៗ...ចំណែកតំណក់ទឹកភ្លៀងក៏ បានដាស់ភ្ញោចមកវិញ យ៉ាងមានប្រសិទ្ធភាពនូវចរិតធម្មជាតិដ៏ស្វាហាប់ របស់អ្នក។
«បើចាំឲ្យភ្លៀងទទឹកការុងធ្ងន់ជាងនេះភ្លើងដែកកេះនឹងក្លាយជា គ្មានប្រយោជន៍» គេគិត ហើយក៏ប្រញាប់ដុតវាដោយប្រុងប្រយ័ត្ន គឺដុតទៅលើក្បាលចំកន្លែងក្របួចចង។ ក្លិនឈៀម និងផ្សែងខ្មៅធ្វើឲ្យរិទ្ធិសឹងថាអត់ទ្រាំបិទដង្ហើម យូរយ៉ាងនេះលែងបាន ចំណែកឯម្នាក់ដែល យាមនៅខាងក្រៅប្រហែលអាល័យគេចគ្រាប់ភ្លៀងបានជា មិនចាប់អារម្មណ៍នឹងក្លិននេះ សូ ម្បីតែស្នូរកេះដែកកេះ។
ការុងរហែកប៉ុនបាតដៃធ្លាក់ចំណងដែលទទឹកជោកមកខ្ពាកលើផ្ទៃមុខ កំលោះយើង។ រិទ្ធិ រូតរះស្រាយវា ហើយលែងខ្លួនឯងចេញពីទីនោះ។
គេងាករកនារីកម្សត់ដែលនៅតែស្ងៀមស្ដូកស្ដឹងមុនពេលឈានទៅពីក្រោយ អ្នកកំពុងជ្រក ភ្លៀងនឹងស្ដាប់ចម្រៀងជាប់ត្រចៀក។ ម្នាក់នេះរវៀសរវៃគ្រាន់បើដែរ តែចំណុចខ្សោយរបស់វា គឺជក់ចម្រៀងពេក។ ឥតគិតច្រើន អ្នកប្រុសលើកដៃស្ដាំក្រៀក កជននោះតែក៏មិនដាច់ចិត្ត មួលផ្ដាច់ដង្ហើមគេ បានត្រឹមឡើងមួយជង្គង់ពីក្រោយក្បាលឲ្យវាដួលត្នោលសន្លប់ស្ដូក ទាំង មានបទចម្រៀងកំដរល្វើយៗ ក្បែរត្រចៀក។

អ្នកដកយកពិលឡេហ្សឺពីដៃវា ហើយរវៀសរវៃងាកមកស្រាយការុងឲ្យនារីតូច។ គេបញ្ចាំង ពិលទៅពិនិត្យមុខនាងទាំងអន្ទះសាខ្លាចថានាងពិបាកពេក លែងដកដង្ហើមបាន ដឹងអីតាម ពិតនាងក៏មិនបានសន្លប់នៅបើកភ្នែកដែលទទឹកជោកដោយ ជលនេត្រសម្លឹងផ្ដោតមកអ្នក។ ទោះបីនេត្រាទាំងទ្វេសើមជោក តែវាបង្កប់មកនូវភាពត្រេកអរ។

អ្នកប្រុសទីពីរលើកម្រាមដៃមួយដាក់លើបបូរមាត់ខ្លួនឲ្យសញ្ញាថា កុំឲ្យនាងលាន់មាត់អ្វី ហើយគេបន្តបកស្កុតចេញពីមាត់នាង។

.....ស្រីតូចដកដង្ហើមយូរក្នុងសេរីភាពសាជាថ្មីនេះ ហើយបុរសឈ្ងោកមកស្រាយចំណងដៃនាងពីក្រោយខ្នង។....ក្នុងភាពអំណរនាង ស្រាប់តែទាក់ចិត្តនឹងក្លិនម្យ៉ាងដែលនាងធ្លាប់ស្គាល់ម្តងរួចមក ហើយ គឺកាលដែលច្រឡំទៅគេងលើគ្រែរបស់គេ។

«ម្នាក់នេះត្រូវគេចាប់ចង បង្អត់បាយហាលភ្លៀងខ្យល់ជិតម្ភៃបួនម៉ោង ខ្លួនគេនៅតែសល់ក្លិនទឹកអប់ស៊ិចស៊ីម៉េះ? គេសមជាជំនួយការមានប្រាក់ខែប៉ុន្មានរយដែរទេ? ទឹកអប់គេបើមិនឃីហោកម្រិតមួយ ក៏ស៊ីវិល័យល្មមឲ្យឯងចងចាំបានដែរសក្ខណា! ណាមួយគេបង្ហាញខ្លួនជាមួយរថយន្តទំនើបមានអ្នកឱនលំទោននៅលាន កូនគោល តើគេជាអ្នកណាឲ្យប្រាកដទៅ?»

នាងនឹកគិតបណ្តើរចេញដង្ហើមក្តៅឧណ្ហៗកំដរដើមទ្រូងអ្នកប្រុសដែលឱនមកគិតពីរូសរាន់ស្រាយចំណងដ៏ស្មុគស្មាញឲ្យនាង។

ភាពទាក់ទាញរបស់បុរសម្នាក់ទៅក្នុងបេះដូងស្រីម្នាក់ វាអាចកើតឡើងត្រឹមតែប៉ុន្មានវិនាទីដែលរាងកាយគេនៅក្បែរគ្នានេះ មែនឬ? ប្រាកដជាអត់ទេ តែស្ថានភាពសក្ខណាគឺងាយស្រួលក្នុងការទោរទន់ចិត្តទៅលើនាយដោយសារ តែនាងត្រូវផ្លាស់ប្តូរពីស្អប់មកជាសោកស្តាយបន្ទាប់ពីបានធ្វើ ទុក្ខនាយឲ្យធ្លាក់ក្នុងអន្ទាក់ជនពាលវិញកាលពីល្ងាច។

«ស្រាយជើងទៅ ហើយកុំទាន់ធ្វើអីផ្តេសផ្តាស!»

គេក្រោកចេញពីនាង នាំយកទាំងក្លិនមនុស្សប្រុសដ៏ថ្មីសន្លាងក្នុងជីវិតនារីអភិជនទៅ ជាមួយផង ប៉ុន្តែពន្លឺភ្នែកគេ អត្តចរិតនឹងននិងសម្តីមួយៗរបស់គេ បាក់ផ្តិតជាប់នឹងដួងចិត្តសក្ខណា។ និស្សិតអាមេរិកឈ្ងោកស្រាយចំណងជើងខ្លួនឯង ឯអ្នកប្រុសក្រោកឈរពិនិត្យស្ថានការណ៍ក្រោមតំណក់ភ្លៀង។

នាងងើបមុខមើលគេម្តងៗ ហើយរាងកាយខ្ពស់មាំទាំរបស់គេធ្វើឲ្យចិត្តនាងទៅជារំភើប។

«ឯងមិនមែនមកជាប់ចិត្តលើជំនួយការគ្មានពូជត្រកូលនេះទេមែនអត់ សក្ខណា?» នាងបង្គាប់ខ្លួនឯងទាំងទោមនស្ស។ ទោះយ៉ាងណានាងគេចមកវិញហើយនៅតែងាកទៅរកគេសាជាថ្មី។

នាងនឹកឃើញដល់កាយវិការអង់អាចរបស់គេកាលពីពេលដែលតស៊ូជាមួយពួកជន ពាល។

ព្រោះតែនាងត្រូវគំរាមជីវិតទើបគេសុខចិត្តចូលក្នុងចំណងសាជាថ្មី។
សម្ដីជនអនាមិកដែលលួចប្រថុយគ្រោះថ្នាក់ជួយគេម្ដងជាពីរដងនោះ បានផ្ដាំគេកុំឲ្យរវល់នឹងនាងទៀត តែគេនៅតែមិនបោះបង់នាងចោល ត្រង់នេះហើយដែលនាងយល់ថានាងពិបាកភ្លេចគេ។
ប្រអប់ដៃធំមាំរបស់រិទ្ធិ លូកមកចាប់កដៃនាងហើយទាញនាងឲ្យក្រោក។ គេនិយាយតិចៗជាមួយគ្រាប់ភ្នែកមុតថ្លានៅពេលដែលស្រីតូចនៅ ស្រឡាំងកាំង៖
«ជុំវិញនេះ គ្មានភូមិអ្នកស្រុកទេ តែពន្លឺចន្លុះមួយក៏អត់ឃើញដែរ! យើងត្រូវរង់ចាំក្រែងនៅខាងមុខមានទីប្រជុំជន ចាំគិតទៀត! យកល្អនាងជួយពិនិត្យគ្នាក្រែងស្គាល់ភូមិសាស្ត្រថានេះជាផ្លូវណា ខេត្តណា!»
គេងាកចេញវិញពិនិត្យតាមបណ្ដោយផ្លូវក្រែងឃើញស្លាកសញ្ញាសម្គាល់ អ្វី ទោះបីរថយន្តបោលលឿនរន្ថើន អ្នកប្រុសក៏នៅតែព្យាយាម។

សំឡេងនារីអភិជនលាន់មកង៉ូវៗក្បែរត្រចៀក៖
«លោកនៅស្រុកខ្មែរស្រាប់នៅតែមិនស្គាល់ ចុះចំណែកខ្ញុំ?»
រិទ្ធិនឹកហួសចិត្ត ព្រោះសម្ដីធ្វើឲ្យគេចងចាំឡើងវិញពីចរិតគ្មានហេតុផលនិងទម្លាប់ និយាយដែលមិនចេះគិតដល់អ្នកដទៃរបស់ស្រីម្នាក់នេះ។ ភាពខុសគ្នារវាងនាងនិងពៅបញ្ញា អណ្ដែតមកឲ្យនរៈយើងធ្វើការប្រៀបធៀបសាជាថ្មី។ កាលៈទេសៈនេះហើយគ្រោះថ្នាក់ក៏នៅកៀកបង្កើយនាងនៅតែគ្មានភាព ទន់ភ្លន់គួរឲ្យអាណិតអីបន្តិចណាសោះ។
«មនុស្សស្រីអីកូនអ្នកធំបានរៀនចេះដឹងគ្រាន់បើ ចរិតវិញគ្មានទំនងសូម្បីបន្តិច!»
គេគិតដោយស្វ័យប្រវត្តិតែមិនងាកមុខមកមើលនាងឬធ្វើការតបតណាមួយឡើយ។ ដោយសាររិទ្ធិមានទម្លាប់លាក់កំបាំងការគិតរបស់ខ្លួនគេមានធម្មជាតិ ជាមនុស្សស្ងប់ស្ងាត់និយាយតិចធ្វើច្រើនគ្មានអ្នកណាអាចស្មានដឹង ពីអត្តចរិតពិតរបស់នាយដោយងាយៗឡើយ សូម្បីតែ ហួត ស៊ីវ ឬពៅបញ្ញាស្រីដែលជាស្នេហាដំបូងរបស់គេ។
ប្រសិនបើគិតឲ្យជ្រៅ អ្នកផងគួរតែដឹងថា ហួត ខេមរិទ្ធិ ជាមនុស្សឆ្លាតតែសុចរិត។ ក៏ប្រហែលដោយសារភាពល្អឥតខ្ចោះក្នុងបុគ្គលិកលក្ខណៈរបស់គេ ដែលស្អប់អំពើអាក្រក់និងការបោកប្រាស់គ្នា ដូច្នេះហើយស្រីដែលគេស្រលាញ់ក៏ប្រាកដជារើសបន្តិចហើយ។ គាប់ជួនវេលាកន្លងមកនោះគេទម្លាប់ចិត្តមកជាមួយនឹងស្រីតូចដែល មានគ្រប់ចរិតលក្ខណៈ ទាំងភាព

ជាកុលស្រ្តី ទាំងចំណេះដឹងនិងការប្រព្រឹត្តិថ្លៃថ្នូរពិតៗ ពៅបញ្ញាបានក្លាយជាលក្ខខណ្ឌទីមួយក្នុងបេះដូងគេ ហើយលក្ខខណ្ឌនោះក្លាយជាទម្លាប់ដែលចាក់យ៉ាងជ្រៅក្នុងការគិតរបស់នាយ អញ្ចឹងហើយប្រសិនបើតទៅគេមិនបាននាងគេក៏ប្រហែលពិបាកក្នុងការរក នារីណាផ្សេងមកជំនួសណាស់ ព្រោះគេតែងធ្វើការប្រៀបធៀបនារីនោះ ចង់ឲ្យនារីនោះត្រូវតែល្អដូចនាង។

អ្នកនាងធំរបស់ជំទាវកុសុមា គឺ ប៉ែន ពេជ្រអមរា ដែលស្រស់ដូចបុប្ផាដាំថែទាំក្នុងរាជឧទ្យានជាផ្កាក្នុងរបងមាស ដែលកំលោះនានាដណ្ដើមគ្នាចង់បាន នាងក៏ទន់ភ្លន់ពេញដោយកិត្តិយសគង់តែមិនអាចឈ្នះបេះដូងអ្នកប្រុសបានកុំថាឡើយស្រីតូចសក្ខណាដែល គ្មានលក្ខណៈជាស្រីខ្មែរហើយ កន្ដើយមាត់ដាចគួរឲ្យរអានេះទៀត។
គិតហើយអ្នកបណ្ដោយឲ្យពេលវេលាកន្លងទៅជិតមួយម៉ោង ដោយមិនមានវាចារកនាងអីបន្ថែមសូម្បីតែមួយឃ្លា។ ភ្នែកទាំងគូគិតតែរំពៃមើលភូមិសាស្រ្ត តែគ្មានសញ្ញាថាមានអ្នកស្រុកណានៅក្បែរនេះឡើយ។
«ព្រៃនេះធំម្ល៉ឹងៗ ចំណែកផ្លូវក៏មិនសូវធំប្រាកដជាផ្លូវលំ ផ្លូវកាត់ទៅកាន់តំបន់ណាមួយតែមិនសមថាជិះយូរហើយសូម្បីតែកូន ភូមិតូចមួយក៏គ្មាន?»
គេគិតទាំងស្មុគស្មាញចំណែកភាគីនារីកូនអ្នកមាន គិតពីឈរតោងរថយន្តទាំងទឹកមុខអស់សង្ឃឹម។
សំឡេងធំមួយលាន់មកជ្រែកកាត់អំណាចព្រះភិរុណេះ
«អ្ហ៎!??? ខាងក្រោយម៉េចហើយរ៉ឺ??»
រិទ្ធិងាកមកវិញយ៉ាងរហ័ស។ វាប្រាកដជាសូរសម្លេងអ្នកណាម្នាក់ក្នុងចំណោមជនពាលពីរនាក់នៅ ក្នុងឡានដែលបើកកញ្ចក់សួរមកគ្នាវា។
«អាគ្រាក់??? ឯងឮអត់?»
រិទ្ធិសម្លឹងមករកសក្ខណាដែលបើកភ្នែកធំៗក្នុងពេលទឹកភ្លៀងស្រោច ទទឹកទាំងសក់និងថ្ពាល់នាង។អ្នកប្រុសលូកដៃទាញនាងឲ្យអង្គុយចុះ ទាបជាបន្ទាន់ដើម្បីពួនលាក់ខ្លួនពីភ្នែកជនពាលនៅក្នុងឡាន។ គេរុញពិលនោះទុកក្នុងដៃនាងដូចចង់ប្រាប់ថារក្សាវាឲ្យគង់ ក្នុងករណីចាំបាច់នាងអាចបំភ្លឺផ្លូវហើយរត់យករួចខ្លួន។ នាងឆ្លាតណាស់ដោយអាចយល់គ្រប់កាយវិការគេ ទោះគេមិននិយាយចេញមកក៏ដោយ អញ្ចឹងហើយបានជាស្រីតូចឱនសម្លឹងឧបករណ៍បំភ្លឺ

ផ្លូវហើយលើកដៃ ម្ខាងខ្ទប់មាត់យំ។ នាងងាយស្រែកងាយហូរទឹកភ្នែកពេកហើយ បើធៀប ទៅនឹងប្អូនស្រីពៅបញ្ញារបស់នាង។ក្នុងវិនាទីដ៏ចង្អៀតនេះ ហើយ រិទ្ធិនៅតែអាចឆ្លៀតប្រៀប ធៀបនារីទាំងពីរបាន។

ព្រមពេលសំឡេងដដែលនោះផ្ញើនសំណួរមក៖
«អ្ហែងស្ដាប់កាសទៀតហើយអ្ហះ? យីអានេះវ៉ី និយាយមិនចេះស្ដាប់! អាគ្រាក់?»
ការហៅដោយអន្ទះសារបស់ជននោះនាំអ្នកប្រុសទីពីរឲ្យប្រុងប្រៀបជា ស្រេចថាគេមិនអាច រង់ចាំទម្រាំជំនិះនាំគេឲ្យទៅដល់ទីប្រជុំជនបាន ឡើយ។
ពិតជាមិនខុសមែន រថយន្តបន្ថយល្បឿនហើយ អែបឈប់ទៅឆ្វេងដែលរាំងដោយដើមឈើ ធំតូច។
រិទ្ធិមិចភ្នែកឲ្យសញ្ញានាងមុនពេលគេអែបក្បែរទ្វារខាងស្ដាំរង់ចាំទទួលវា។
អ្នកលេងមាឌធំម្នាក់នោះចុះមកឃើតៗដោយមានកាំភ្លើងខ្លីក្នុងដៃ។ កន្ទុយភ្នែកវារេមកមិន មែនវាមិនដឹងថាស្ថានការណ៍ គឺខុសធម្មតានោះទេ។ សំឡេងវាក៏គំហកស្ទើរបែកអាកាស ៖
«អឺអាគ្រាក់!»
គូកនវាដែលមានភារៈនៅក្រោយនេះតាមពិតជាមនុស្សម៉ត់ចត់ណាស់ដែរ ប៉ុន្តែចំណុច ខ្សោយមួយគឺស្រលាញ់សិល្បៈពេកបានជាពេលនេះគ្នីគ្នា ចេញមករក ក៏ឃើញដេកឈ្ងោក មុខព្រោះត្រូវមួយកណ្ដាប់ដៃចំឆ្អឹងកញ្ចឹងក។
រហ័សដូចផ្លេកបន្ទោរ ប្រសិនបើចាំឲ្យវាឈានជើងទាំងពីរចុះផុតមកបានរិទ្ធិមិនអាចគេច ចេញផុតពីកាណុងកាំភ្លើងវាឡើយម្ល៉ោះហើយអ្នកប្រុស ប្រថុយព្រលែងជើងតម្រង់ថ្វាសវា។
....ទោះបីឡាននេះខ្ពស់ពេក ហើយវានៅទាបពិបាកកំណត់តម្រង់គោលដៅក៏ដោយ។
....ដូចការគិត...ការត្រៀមខ្លួនរបស់ជនមាឌធំ បានជួយវាឲ្យស្ដាប់ឮសន្ទឹកជើងនេះហើយ ដោយបទពិសោធន៍ជាជើងអ្នកលេង គេបានឱនគេចរហ័សជាង ព្រមទាំងក្រោកមកវិញព្រម ៗគ្នា។ រិទ្ធិក៏គ្មានឱកាសបង្អង់សម្រាកដែរ ព្រោះយល់ថាគ្រោះថ្នាក់នៅកៀកបង្កើយ លើកនេះ ដើម្បីសុវត្ថិភាព ជើងអ្នកលេងគ្មានផ្លូវឲ្យអ្នករស់សល់ជីវិតនឹងបានរបូតពីចំណាងជា លើកទីបី ឡើយ ម្ល៉ោះហើយអ្នកប្រុសរបស់ ហួត ស៊ីវ ទាត់ជាលើកទីពីរផ្ទួនៗតម្រង់ទៅកាំភ្លើងលើដៃ វា។

ជើងទីពីរត្រូវចំកដៃវាដូចគេវាស់ស្មានទុក ….កម្លាំងជើងវាត់យ៉ាងដំណំ ថ្នាក់វាស្រែកអូយប្រើដៃម្ខាងទៅជួយខ្ទប់ការឈឺចុកចាប់វានៅតែ មិនព្រមរបូតអាវុធបាន ដោយគ្រាន់តែរេជំហរហើយក៏មិនដួល។ រិទ្ធិដឹងថាកម្លាំងម្នាក់នេះខុសឆ្ងាយពីពួកមនុស្សបួនប្រាំនាក់ ដែលអ្នកបានប៉ះជាមួយកាលពីព្រឹក។លើកនេះកុំថាឡើយវាមានកាំភ្លើង ទោះបីជាវាគ្មាន ហើយបើមានឱកាសលោតឡើងមកនៅស្មើនឹងអ្នក ក៏មិនប្រាកដថាអាចយកឈ្នះវាដោយងាយស្រួលដែរ។

…..កាន់តែអាសន្នទៅទៀតនោះគឺកាលពីរេដៃចេញអំបាញ់មិញវាបានកេះកៃ របូតមួយគ្រាប់ទៅលើមេឃទៅហើយផ្អើលដល់គូកនម្នាក់ទៀតដែលបើកឡាន ហើយរិទ្ធិជឿថា វាច្បាស់ជាស្លន់ស្លោស្ទុះចេញមក។

ស្ថានភាពនេះ អ្នកដឹងថាគឺជាស្ថានភាពគ្មានអំណោយផល។ គេនៅតែបន្តជើងទីបីទៅក្នុងវិនាទីដ៏ប្រថុចញ៉ិចបំណងផ្តួលអ្នកទី មួយជាមួយកាំភ្លើងវាឲ្យរាបទៅដីកុំឲ្យឡើងមករួចសិន ចាំចាត់ការអ្នកបើកបរដែលស្ទុះចេញមកពីទ្វារខាងឆ្វេង។

…បានដូចចិត្ត អ្នកនៅខ្ពស់ជាងប្រាកដជាអាចសម្រុកទៅរកអ្នកនៅទាបជាងត្រូវគោលដៅហើយធ្វើឲ្យវាដួលត្មោលចោលកាំភ្លើងទៅម្ខាងមែន ប៉ុន្តែមុនពេលគេងាកមករកតស៊ូនិងអ្នកបើកបរដែលស្ទុះមកពីក្រោយ ខ្នង សំឡេងវាបង្ហើរមកបានមុន៖

«ឈប់ភ្លាមអាក្របី!!!»

គេជាអ្នកស្រុកណាដែលជេរអ្នកថាអាក្របីក្នុងពេលដែលខឹងបំផុត? រិទ្ធិមិនមានពេលនឹងរកចម្លើយឲ្យសំណួរនេះបានភ្លាមៗទេ ទោះគេចាប់អារម្មណ៍វាក៏ដោយព្រោះថា ចុងកាំភ្លើងគេកំពុងភ្ជង់មកអ្នក។ អ្នកដឹងថា បើអ្នកកម្រើកតែបន្តិច វាមុខតែលះបង់ចិត្តដែលចង់បានលុយហើយសំឡេះអ្នកចោលដើម្បីសំអាតដាន ប៉ុន្តែពន្លឺពិលឡេហ្សឺដែលស្រីតូចបញ្ចាំងទៅលើមុខវា ឯណោះទេដែលអ្នកប្រុសត្រូវរហ័សប្រើវា ជាឱកាសចុងក្រោយ។

គេក្រឡាស់ខ្លួនហក់ទាំងភ្នែនកាត់ពីមុខការភ្ជង់របស់វា ក្នុងពេលពន្លឺនោះបានបង្អើលភ្នែកវាឲ្យព្រិចចេញហើយបន្ទាប់ពីវា អាចវិលភ្នែកមកវិញគឺទទួលជើងទាំងពីររបស់ ហួត ខេមរិទ្ធិ ចំកណ្តាលមុខដួលផ្ងារក្រោយគ្រាំង។

«ក្រាបចុះសក្ខណា!»

គេបញ្ជាយ៉ាងញាប់ ទាំងខ្លួនឯងស្ទុះឡើងទៅរកកន្លែងបើកបរ ….

….គេថយឡានធ៊ឹត ហើយជាន់ហ្គែស្ទុះទ្រោលទៅមុខ។

ពីកញ្ចក់ខាងស្តាំ រិទ្ធិឃើញជនពាលដែលចុះមកមុនគេនោះ ប្រវាក្រោកទ្រេតទ្រោត ដើរទៅរើសកាំភ្លើងវា ហើយរូបរាងវាកាន់តែតូចទៅៗ គ្មានតម្រុយថាវាអាច រត់មកប្រណាំងជាមួយឡានបានឡើយ។ ចំណែកតែកុងឡានដែលដកកាំភ្លើងមកភ្ជង់អ្នកតាមក្រោយ ហើយនៅដេកខ្ទប់មុខលើថ្នល់នៅឡើយមិនដឹងថា បែកភ្នែក ឬច្រមុះបាក់ឆ្អឹងដែលត្រូវមួយជើងចំកណ្តាលមុខ។

សំខាន់គឺគេត្រូវការដឹងថាសក្ខណា នៅលើនេះរថយន្តនេះជាមួយគេ....គេស្រែកខ្លាំងៗ៖

«សក្ខណា???»

……………………

ជំពូក៥

របួសអតីតជាសះជាថ្មី?

.....សាជាថ្មី គ្រួសារ ប៉ែន ពេជ្រ ទាំងផ្ទះទីមួយនិងផ្ទះទីពីរមកជួបជុំគ្នានៅមន្ទីរពេទ្យ លើកលែងតែស្រីពៅរបស់ជំទាវកុសុមាដែលនៅបាត់ខ្លួននៅឡើយ។

«ពេទ្យថាម៉េចហើយ?»

យុត្តនាពោលសួរខ្សឹបក្បែរត្រចៀកពៅបញ្ញាដែលកំពុងចុចទូរសព្ទដៃ។ ការបង្ហាញខ្លួនភ្លាមៗរបស់នាយ ធ្វើឲ្យនាងភ្ញាក់ផ្អើលស្រេចទៅហើយកុំថាឡើយមកឈរកៀកសែនកៀកហើយខ្សឹបក្បែរត្រចៀកទៀត។ នាងជ្រួញចិញ្ចើមមិនពេញចិត្តការពញ្ញាក់នេះ តែក្រឡេកមកឃើញស្នាមញញឹមរបស់គេនាងហាក់រសាយពីភាពខ្វល់ខ្វាយ។ មេធាវីតូចតបមួយៗ៖

«លោកប៉ាផុតពីគ្រោះថ្នាក់ហើយ! តែនៅមិនទាន់ដឹងខ្លួន»

គេញាក់ចិញ្ចើមជាសញ្ញាថា«ល្អ!»ហើយជ្រែងហោប៉ៅនៅពីមុខនាងរង់ចាំស្តាប់ព្រោះនាងកំពុងនិយាយបន្ថែមមក។

«ដូចលើកមុនអញ្ចឹង! មិនដឹងពេលណាលោកប៉ាបានទៅផ្ទះទេ! »

គេនៅតែមិននិយាយស្តី ស្រីស្អាតក៏សួរបន្ត៖

«ចុះលោកអ៊ំ?»

«ប៉ាខ្ញុំស្រាលជាងប៉ានាង! ពេទ្យឲ្យសម្រាន្តព្យាបាលនៅផ្ទះបាន!»

ស្រីស្រស់ដកដង្ហើមធូរទ្រូងពេលឮថា ហ្ស៊ុត ស៊ីវ ចេញទៅផ្ទះ នាងពោលបន្ត៖

«ល្អហើយ! ចង់ឲ្យពួកគាត់ជាឆាប់ៗបានជជែកគ្នាលេងវិញ!»

យុត្តនារវើ្ភែកគិត។
តើដោយសារតែលេខាប៉េងបានជាអ្វីៗទៅជាធូរស្រាលវិញ? គំនុំអតីតកាលបានរំលាយ ហើយនាយនឹងនាងក៏គ្មានបន្លាបាំងមុខទៀតដែរ? អ្នកយល់ថា ទោះបីជាស្ថានភាពពេលនេះពិតជាមិន អំណោយផលសម្រាប់ឲ្យអ្នកនិងនាងសាងអនុស្សាវរីយផ្អែមល្ហែមបាន ប៉ុន្តែរង់ចាំទម្រាំប៉ានាងជា ប្អូនស្រីនាងអាចរកឃើញមកវិញ ក៏មិនជាយូរប៉ុន្មានដែរ។ គេនិយាយតិចៗទៅកាន់ទឹកមុខខ្វល់ខ្វាយរបស់នាងដែលឱនចុចទូរសព្ទ បន្ត៖
«ហើយទូរសព្ទហ្នឹងក៏មមាញឹកម៉េះ?»
ស្រីស្រស់តបទាំងមិនងើបមុខ៖
«លោកដឹងហើយ! បងរិទ្ធិក៏មិននៅ ឥឡូវការងារនៅក្រុមហ៊ុនគឺខ្ញុំត្រូវដោះស្រាយទាំងអស់!»
គេដឹងថានាងហត់នឿយហើយបានរ៉ាប់រងរឿងរ៉ាវជាច្រើន គេចង់ឲ្យនាងសប្បាយចិត្តនិងមិនសូវទទួលអារម្មណ៍ឯកាបានជាមក បង្ហាញខ្លួននៅទីនេះ។ គេពោលសួរបន្ថែម៖
«ខ្ញុំចង់ចូលទៅមើលគាត់! អ្នកណានៅខាងក្នុងអត់?»
«បងប្រាថ្នាទើបមកពីថៃ! គាត់ប្រហែលនៅក្នុងជាមួយអ្នកបងអមរា!»
យុត្តនាបញ្ចេញភាពមិនសប្បាយចិត្តតាមរយៈក្រសែភ្នែក....ពៅបញ្ញាក៏មើល យល់....នាងដឹងថា គេនឹងមិនចូលទៅទេ បើបងប្រុសធំនាងមិនទាន់ចេញ ...តែនាងមិនដឹងទេថាសូម្បីតែប៉ែន ពេជ្រអមរា ក៏យុត្តនាមិនចង់ប្រឈមដែរ ព្រោះស្រីនោះជាគូដណ្ដឹងដែល ហួត ស៊ីវ ធ្លាប់លើកឡើង។
នារីដែលមិនខ្វាយខ្វល់រឿងក្នុងចិត្តយុត្តនា និយាយបន្តពីករណីផ្សេង៖
«មានដំណឹងអីពីសក្ខណានិងបងរិទ្ធិអត់?»

## ភាគទី៣២

យុត្តនានៅតែរក្សាភាពធូរស្រាល ទោះបីចិត្តកំពុងតឹងនៅពេលនឹកឃើញដល់ប្អូនប្រុសធម៌ខ្លួន។ គេតបនឹងស្រីស្នេហ៍៖
«ពួកដៃជើងរបស់ពូប៉េងប្រាប់មកថា តានោះបញ្ចេញបងរិទ្ធិរបស់នាងនិងសក្ខណាទៅឲ្យពួកចោរទល់ដែនមួយ ក្រុម! គ្មានអ្នកណាស្គាល់ថា វាជាអ្នកណា ហើយបញ្ចេញទៅខេត្តណាមួយទេ! បណ្ដាញរបស់ខ្ញុំកំពុងធ្វើការនៅតាមទល់ដែនអស់នោះ! មិនយូរទេ.....កុំអន្ទះសាពេក»
ពៅបញ្ញាបញ្ចេញក្ដីព្រួយបារម្ភលើវង់ភក្ត្រនាងផ្អាកចុចទូរសព្ទហើយងើបមុខនិយាយ៖

«អរគុណហើយ ខ្ញុំទៅនិយាយជាមួយអ្នកបងអមរាបន្តិច!»
នាងដើរតម្រង់ទៅបន្ទប់អ្នកជំងឺតែគេនិយាយតាមពីក្រោយតិចៗ៖
«នាងជំពាក់ខ្ញុំទៀតហើយមេធាវី!»
ស្រីស្អាតឮហើយដឹងថាគេនៅតែមានចរិតឌឺដងលេងសើចតែនាងគ្មាន ពេលវេលាគ្រប់គ្រាន់សម្រាប់រឿងនេះទេ បានត្រឹមងាកក្រោយញញឹមបន្តិចឲ្យគេបានអស់ចិត្តប៉ុណ្ណោះ ដឹងអីថាស្នាមញញឹមនាងត្រូវរោយដោយសាររវត្តមានស្ត្រីអភិជនដែល បង្ហាញខ្លួនក្រោយខ្នងយុត្តនា។ ជំទាវកុសុមាមកដល់ដោយមាន ប៉ែន ពេជ្រប្រាថ្នា បងប្រុសនាងចុះទៅទទួលគាត់តាំងពីពេលណាក៏មិនដឹង ប្រហែលជាស្ត្រីនោះមកដល់ចំពេលនាងងាកក្រោយសើចដាក់យុត្តនាហើយ បានជាគាត់សម្លឹងមកក្នុងក្រសែភ្នែករិះគន់ពេបជ្រាយនាង។
យុត្តនាសម្លឹងតាមភ្នែកនាង ហើយក៏ងាកទៅមើលលោកជំទាវដ៏ឫកធំសម្បើមនោះដែរ។

នៅពេលដែលពៅបញ្ញាឱនលំទោនសំពះសួរគាត់ អ្នកនៅធ្វើមិនដឹងព្រោះយល់ថាស្ត្រីនេះមិនមានអ្វីគួរឲ្យខ្វល់ខ្វាយកោតគោរពទេ ពិសេសគាត់បង្ហាញខ្លួនជាមួយយុវជនដែលនាយស្អប់ផងនាយរឹតតែធ្វើងើយ ហាក់មិនឃើញគាត់។
ប៉ែន ពេជ្រប្រាថ្នា ដៃកាន់កែវកាហ្វេដើរក្រអឺតហួសកាត់ពីមុខស្រីប្រុសទាំងទ្វេ សម្តែងសញ្ញាថាពួកគេមិនមានសមត្ថភាពដល់ឲ្យខ្លួនរវីរវល់និយាយរក ទេ។
តែឃើញមុខយុត្តនាកាលណាស្ត្រីអភិជនក៏នឹកឃើញដល់សម្ព័ន្ធសង្សារចាស់ ដែលតែងតែចង់ឲ្យកូនស្រីអមរារបស់គាត់ភ្ជាប់ជីវិតជាមួយនាយ រហូតដល់ហ៊ានប្រគល់តួនាទីធំបង្អស់របស់គ្រួសារខ្លួនឲ្យទៅគេទៀត ដល់មកឃើញគេនៅញញឹមដាក់គ្នា គាត់កាន់តែទើសចិត្ត ទ្រាំរក្សាឫកជាចាស់ទុំមិនបានក៏ឆ្លៀយស្រដីមួយៗ៖
«ក្មេងៗឥឡូវគ្រាន់បើមែន ឪពុកឈឺក្រោកពីគ្រែមិនរួចម្នាក់ៗ អាល័យរវល់មកឌឺដងសប្បាយ! ថា ហួត ស៊ីវ ចុះរវល់តែរកស៊ីមិនចេះប្រដៅកូន! ប៉ែន ពេជ្រ ក៏ប្រហែលមិនគ្រាន់បើជាងប៉ុន្មានដែរ!»
ថាហើយគាត់ដើរហួសទៅទុកឲ្យស្រីប្រុសទាំងទ្វេងាកមើលមុខគ្នា ឡិងឡង់ទាំងតឹងចិត្ត។ នៅសុខៗត្រូវស្ត្រីចំណាស់ស្មើម្តាយម្នាក់មករករឿងដោយគ្មានហេតុ គាប់ជួនស្ត្រីនោះដើរផុតទៅមែនតែកូនប្រុសច្បងបងគាត់ដែលដៃដឹក ម្តាយហើយនៅឆ្លៀតងាកមកញញឹមឌឺដងឲ្យយុត្តនាទៀត ធ្វើឲ្យអ្នកប្រុសទីមួយរបស់ ហួត ស៊ីវ កើតចិត្តឆេវឆាវ។

គេងាកទៅញាក់ចិញ្ចើមដាក់ស្រីស្អាត៖
«ម៉េចដែរ គេថាឲ្យនាងណ៎ា ចង់សងសឹកអត់?»
ពៅបញ្ញាឱគេវិញទាំងបើកភ្នែកក្រឡង់ហើយញាក់ចិញ្ចើមដូចគ្នាដែរ៖
«គាត់ថាឲ្យលោកហ្នឹងហើយ!»
យុត្តនាបន្តភ្លាម៖
«អញ្ចឹងនាងចាំមើលណ៎ា!»
ថាចប់គេស្ទុះរឹងលើកទូរសព្ទមកធ្វើជានិយាយហើយដើរហួសទៅយ៉ាង ញាប់ឲ្យទាន់ដំណើរស្ត្រីអភិជននឹងកូនប្រុសគាត់។ ពៅបញ្ញជ្រួញចិញ្ចើមស្ទើរដល់គ្នា ព្រោះថានាងលើកដៃផ្ទប់មាត់មិនទាន់ផងយុត្តនាបំបុកបងប្រុសនាង ផាំងធ្វើឲ្យកែវកាហ្វេលើដៃគេ ខ្ទាយកំពប់ទៅលើកម្រាលឥដ្ឋនឹងប្រឡាក់សំលៀកបំពាក់គេដោយអន្លើ។
ក្រោមភាពស្រឡាំងកាំងរបស់កំលោះអភិជន ដែលទុករូបរាងសង្ហានិងសំលៀកបំពាក់ជាមធ្យោបាយទាក់ស្រីៗរបស់គេនោះ យុត្តនាធ្វើជាដាក់ទូរសព្ទចុះ ហើយបើកភ្នែកធំៗភ្ញាក់ផ្អើល៖
«សុំទោសថៅកែ! ប៉ាខ្ញុំឈឺនៅផ្ទះ ខ្ញុំបារម្ភពេកបានជាដើរអត់បានប្រយ័ត្ន! សុំទោស!»
អ្នកប្រុសធំរបស់ ប៉ែន ពេជ្រ កើតចិត្តសៅហ្មងពន់ពេកទៅហើយនឹងការកខ្វក់កណ្តាលចំណោមនេះតែគេនៅ តែរក្សាចរិតសុភាពបុរសមិនរវល់នឹងតបត មានតែងាករកជំទាវកុសុមាហើយស្រដី៖
«ជំទាវម៉ាក់! កូនទៅបន្ទប់ទឹកសិន!»
គេចាកចេញទៅ ក្រោមស្នាមញញឹមរបស់យុត្តនាធ្វើឲ្យជំទាវកាន់តែឆេះឆួលចិត្ត រេភ្នែកមកសម្លក់ទាំងពៅបញ្ញាដែលមិនដឹងរឿងហើយគាត់ហួសដើរចូលទៅ ក្នុងបាត់ទុកឲ្យស្រីតូចកើតចិត្តសៅហ្មង ក្តាប់មាត់សម្លឹងមុខអ្នកប្រុសយើង។
គេបែរក្រោយដើរយឺតៗមកប្រឈមនឹងនាង។
ស្រីតូចដឹងថាបើនៅតែប្រឈមនឹងគេដែលមានចរិតមិនចេះក្រែងចិត្ត អ្នកណានេះទៀតមិនត្រឹមតែជំទាវកុសុមាទេដែលគិតខុសលើនាង កិត្តិយសនាងនឹងត្រូវខូចបង់ព្រោះគេនេះមែនទែនមិនខាន។នាងលែងខ្វី រវល់ដើរហួសពីគេទៅ តែដើរកាត់គេកាលណាទ្រាំនឹងស្នាមញញឹមឌឺរបស់គេមិនបាន នាងលាន់មាត់ថាឲ្យគេខ្សឹបទាំងគ្រឹត៖
«ចរិតស្រី!»

គេឈរញញឹមតាមសម្លឹងភាពអាក់អន់ក្និកក្នក់របស់នាង។ បើនេះមិនមែនមន្ទីរពេទ្យគេនឹងចាប់ទាញនាងមកវិញជាស្រេចហើយ តែគេអត់ធ្មត់។

ពៅបញ្ញាត្រលប់មកវិញជាមួយកន្សែងមួយក្នុងដៃ ហើយដើរហួសឆ្ពោះទៅបន្ទប់ទឹក មិនខ្វីងាកមើលទឹកមុខងងើលរបស់គេដែលពេលនេះលាក់ក្រោមវ៉ែនតា ខ្មៅធំនោះឡើយ។

«ស្រលាញ់បងប្រុសណាស់ហ្ន៎!??»

គេឱនាងតិចៗពេលនាងដើរកាត់មុខតែស្រីតូចធ្វើមិនដឹង តែបបូរមាត់នាងដែលមានស្នាមញញឹមលំអតិចៗធ្វើឲ្យយុត្តនាស្ទើរ ឆ្កួតវង្វេង។

តាមថាគេមិនអាចចូលពិនិត្យអ្នកជំងឺបានទេ ព្រោះមនុស្សដែលបង្ហាញខ្លួនសុទ្ធតែមនុស្សដែលគេទើសភ្នែកទៀត តាមចរិតយុត្តនាគួរតែវិលទៅវិញ តែគេនៅមិនដាច់អាល័យពីស្រីតូចទើបនៅឈររេរាចាំនាងចេញមកវិញ នឹងអាលបានលានាងមួយម៉ាត់.....ភ្លាមនោះនាងស្រាប់ត្រហេបត្រហបចេញមក វិញលឿនហួសពីការរំពឹងទុកជាមួយទឹកមុខស្លឹតស្លក់

«យុត្តនា!.....»

នាងហៅគេតិចៗតែទឹកមុខស្លេកស្លាំងធ្វើឲ្យបុរសស្ទុះទៅក្បែរជាបន្ទាន់...

«មិនមែនត្រូវប្រឡាក់កាហ្វេមួយកែវ បងនាងសន្លប់ទេមែនអត់?»

គេសួរខ្សឹបៗតែចិត្តនៅរង់ចាំស្តាប់នាង។ តរុណីនិយាយខ្សឹបៗ៖

«លេខាប៉េងនៅខាងក្នុង!»

យុត្តនាមមីភ្នែកស្ទើរមិនជឿត្រចៀកខ្លួន។ គេរេភ្នែកទៅរកបន្ទប់ទឹក ហើយបោះជំហានវែងៗសំដៅទៅទីនោះ មានទាំងស្រីសតូចដើរទៅតាមក្រោយទាំងបុកពោះភឹបៗ...។

មុននេះពេលនាងយកកន្សែងទៅឲ្យបងប្រុស នាងបានឃើញបុរសទុច្ចរិតនោះបង្ហាញខ្លួនផ្ទាល់នឹងភ្នែក....គឺលេខា ប៉េងហាក់ដូចជាកំពុងជជែកអ្វីម្យ៉ាងជាមួយ ប៉ែន ពេជ្រប្រាថ្នា។ សំខាន់គឺ បងប្រុសនាងទំនងជាមិនបានដឹងទេថា បុរសចិនចំណាស់នោះហើយដែលជាអ្នកបង្កហេតុឲ្យឪពុកនាងត្រូវចូល ពេទ្យហើយសក្ខណាត្រូវបាត់ខ្លួន។ មិនដឹងធ្វើយ៉ាងណា នាងមានតែរត់ចេញមកប្រាប់យុត្តនា....តែនៅពេលអ្នកប្រុសទីមួយរបស់ ហួត ស៊ីវ ចូលទៅដល់គេឃើញមានតែសភាពបុរសក្នុងស្រោមឈរលោងដៃស្ងប់ស្ងាត់ម្នាក់ឯង ប៉ុណ្ណោះ....

យុត្តនាដៀងភ្នែកសម្លឹងពេញផ្ទៃបន្ទប់ទឹក ដែលគ្មានសូម្បីតែស្រមោលមនុស្សផ្សេងណា។ គេដើរយឺតៗចូល....ឯប្រាថ្នា ក៏ងាកមកដោយទឹកមុខស្មើ....

ហាក់មិនខ្វីរវល់នឹងសុភាពបុរសក្លែងក្លាយនេះ...យុត្តនានិយាយស្មើតែម្នាក់ឯង៖
«លេខាប៉េង! ចេញមក!!»

ស្ងាត់ច្រៀបគ្មានចម្លើយមានតែស្នូរស្បែកជើងកែងចោតរបស់ស្រី តូចមេធាវីដែលប្រកប ដោយទឹកមុខស្លេកស្លាំង។ នាងតាមមើលកាយវិការយុត្តនាដែលទៅរុញបើកទ្វារបង្គន់ម្តងមួយៗ....
....ពិតជាគ្មានអ្នកណាម្នាក់មែន....
គេបែរមុខមករកនាង...តែទឹកមុខនាងបានធ្វើឲ្យគេជឿជាក់ថា អ្វីដែលនាងបានឃើញជាការពិត ម្ល៉ោះហើយអ្នកប្រុសប្រញាប់ចាកចេញទៅតម្រង់ជណ្តើរឯត្រចៀកឮនាង និយាយជាមួយបងនាង៖
«ខ្ញុំឃើញបងនៅជាមួយលេខារបស់ ហួត ស៊ីវ អម្បាញ់មិញនេះ!»
ប៉ុន្តែប្រាថ្នាឆ្លើយវិញធ្វើវាហី៖
«ឯងស្រវឹងស្នេហ៍ ឡើងស្រវាំងភ្នែកហើយដឹង?»
មេធាវីរូបស្អាតហួសចិត្តនឹងការដោះសាស្ទីលនេះ។ ដោយមិនទម្លាប់ចេះជាអ្នកចេះល្បិចល្បងច្រើន នាងមិនមាត់រួចមួយម៉ាត់ធ្វើឲ្យបុរសជាបងខុសម្តាយកាន់តែបាន ចិត្តចាក់បន្ថែមមកទៀត៖
«បងដឹងថាឯងដល់វ័យមានស្នេហាហើយ! តែបើឯងរើសយកអាអ្នកលេងនេះ បងពិបាកចិត្តជំនួសឯងពៅបញ្ញា!»
ស្រីស្អាតឆេះឆួលចិត្ត នាងមិនទាន់តបអ្វីបានផងស្រាប់តែកន្ទុយភ្នែកឃើញខ្នងយុត្តនាដែលចេញទៅហើយនោះស្រាប់តែថយមកវិញ។
នាងងាកភ្លែតទៅឃើញមុខគេក៏ដឹងថាមេឃរៀបបាក់សង្កត់ផ្ទៃបន្ទប់ទឹកនេះដែរ។
សម្តីបងនាងដែលហៅគេថា«អ្នកលេង»ប្រាកដជាគេបានឮបានជាគេបោះបង់ចោលការប្រដេញលេខាប៉េងហើយថយត្រលប់មកវិញ។
នាងដើរទៅរាំងគេ តែគេនៅតែធ្វើមុខស្មើហើយទាញនាងចេញពីមុខ ដើម្បីឆ្ពោះមករក ប៉ែនពេជ្រប្រាថ្នា។
នារីខ្សឹបតិចៗព្រោះមិនចង់ឲ្យគេបង្ករឿងណាមួយខាតបង់ដល់កិត្តិយសទៀតទេ៖
«ទៅវិញទៅយុត្តនា???»

កូនចិញ្ចឹម ហួត ស៊ីវ សើចក្អឹកទៅកាន់ផ្ទៃមុខឪរបស់កូនបង្កើតឥតខាន់ស្លារបស់ ហួត ស៊ីវ នាយនិយាយតបនឹងស្រីស្នេហ៍៖

«អាសុភាពបុរសកន្ទុយខ្មៀននេះ វាគួរតែស្គាល់ពីពួកអ្នកលេងឲ្យច្បាស់ជាងនេះដែរ!»

ពៅបញ្ញាស្អប់ចរិតហិង្សារបស់គេណាស់ តែនាងរឹតតែមិនអាចចាកចេញក្នុងពេលនេះព្រោះនាងដឹងថា បងប្រុសនាងច្បាស់ជាត្រូវធ្ងន់មិនខាន នាងរុញយុត្តនាចេញអស់មួយទំហឹងតែគេមិនថយកម្រើកសូម្បីមួយចំអាម ទៅក្រោយ ធ្វើឲ្យស្រីតូចកាន់តែបារម្ភ នាងប្រាប់ទៅប្រាថ្នា៖

«...បងប្រាថ្នាទៅវិញទៅ!....»

តាមចរិតកំសាករបស់គេគេមិនហ៊ានប្រចុយជាមួយយុត្តនាស្រាប់ហើយ លុះបានប្អូនស្រីជួយធ្វើរបងឲ្យទៀតគេក៏សសៀរចាកចេញតែបានលើកដៃ មួយមកចង្អុលយុត្តនាជាសញ្ញាថា« ឯង! ប្រយ័ត្នខ្លួនផង!»

យុត្តនាមិនអាចចេញទៅរកបុរសនោះក្របួចកអាវគេដូចចិត្តក្តៅ ព្រោះស្រីតូចតោងគេជាប់ហើយគេក៏មិនដាច់ចិត្តថាច្រាននាងចេញ ដូចច្នេះហើយពេលប្រាថ្នាចេញបាត់ នាងងើបមុខមកវិញឃើញទឹកមុខសោះអង្គើយរបស់គេសម្លឹងនាង ប្រៀបដូចជាក្រសៃភ្នែករបស់គេដែលសៅហ្មងរកនាងនារាត្រីដែលនាង បង្ហាញខ្លួនជាមួយ ឈុតសមោសរពណ៌ទឹកមាសកណ្តាលចំណោមពួកធុរកិច្ចជននោះដែរ។

ស្រីស្អាតមានអារម្មណ៍ថាហេតុអ្វីទឹកមុខគេរបៀបនេះអាចធ្វើឲ្យនាងកើតបារម្ភ? តែនាងសម្រួលបរិយាកាសនិយាយតិចៗបន្លប់៖

«កោតណាស់ៗពាក្យប៉ុណ្ណឹងៗក៏កើតជាកំហឹងបាន?»

គេនៅតែសម្លឹងនាងដោយមិនមាត់ តែគេមិនព្រមញញឹមឡើងវិញតាមដែលនាងចង់បានទេ។ ស្រីស្អាតក្តាប់មាត់និយាយបន្ថែមទៀត ក្នុងពេលលែងដៃពីរាងកាយគេសន្សឹមៗ៖

«ធ្វើកាចអញ្ចឹង ស្មានថាមានគេសរសើរណាស់?»

គេនៅតែមិនមាត់រក្សាទឹកមុខដដែល ....នាងជ្រួញចិញ្ចើមហើយបែរខ្នងចាកចេញ គេក៏មិនឃាត់ហើយ ឈានហួសទៅបើកទឹកលុបមុខ...នាងដៀងកន្ទុយភ្នែក លបមើលគេ ក៏ដឹងថាគេកំពុងខំប្រើភាពត្រជាក់នៃទឹកម៉ាស៊ីននេះពន្លត់កំហឹង ដែរ...ស្រាប់តែឮគេនិយាយមកភ្លាម៖

«ឯណាកន្សែង?»

ស្រីស្អាតឈ្ងោកមើលកន្សែងដែលនាងកាន់មកក្នុងដៃបម្រុងថាឲ្យទៅបងប្រុសជូតស្នាម

ប្រឡាក់....នាងហុចទៅឲ្យគេ...

....ស្រីស្អាតសម្លឹងទៅគេដែលប្រើកន្សែងដៃនាងផ្ចិតទឹកពីផ្ទៃមុខ....នាងញញឹមក្នុងពេលគេដៀងភ្នែកមើលមកតាមកញ្ចក់....

«មានអីគួរឲ្យសើចមេធាវី?»

«សើចនាយកធនាគារដែលក្រដល់អត់កន្សែងប្រើ មកសុំកន្សែងគេជូតមុខ!»

«កុំយកលេស! ចង់នាងហៅខ្ញុំ ពីរោះជាងនេះទៀតក៏ខ្ញុំមិនភ្លេចសម្តីអាបងសំអុយរបស់នាងដែរ!»

ស្រីស្អាតក្តាប់មាត់មិនពេញចិត្តដែលគេចេះនឹកឃើញមកដៀលបងប្រុសគេនៅនឹងមុខប្អូនស្រីគេនាងនិយាយ៖

«បើបងគេសំអុយប្អូនស្រីគេក៏....»

យុត្តនានិយាយកាត់៖

«....នាងនឹងវាមិនមែនបងប្អូនបង្កើតទេ! ត្រូវចាំ!»

នាងបើកភ្នែកមុខមូលក្រឡង់នៅពេលគេនិយាយពាក្យអសុរោះនេះចេញមក រួច។ ទោះបីនាងមានសម្បុកមុនក្រោយមែនអ្នកណាក៏ដឹងឮតែអ្នកចេះ ដឹងគេនឹងមិននិយាយពាក្យមកឲ្យនាងប្រេះទ្រូងឡើយ។ ស្រីស្ងួនអន់ចិត្តបែរខ្នងដើរចេញទាំងមុខក្រញូវ ស្រាប់តែគេទាញចង្កេះនាងមកវិញហើយញ៉ុកកន្សែងទៅលើដៃនាង ជាមួយក្រសែភ្នែកប្រចៃប្រចណ្ឌ៖

«ហើយមនុស្សស្រីអី ដើរយកកន្សែង ឲ្យគេជូតមុខតែពាស?»

នាងជ្រួញចិញ្ចើម ព្រោះមិនយល់....គេសំដៅលើខ្លួនគេឬសំដៅលើមុននេះនាងប្រុងឲ្យវាទៅបងប្រុសនាង....នាងពេបមាត់របៀបហួសចិត្ត....

«អស់មនុស្សប្រចណ្ឌហើយ?»

គេបានចិត្តព្រោះនាងចូលស៊ងក៏បកវិញ៖

«អ្នកណាប្រចណ្ឌនាងមេធាវី!?? កញ្ចក់នេះធំណាស់....យកឱកាសនេះមើលមុខខ្លួនឯងផងទៅ! ខ្មៅក៏ខ្មៅ....មុខក្រញូវគ្រប់តែពេល....ចរិតប្រុស....»

នារីជ្រួញចិញ្ចើមខឹងក្អិកក្អក់នឹងពាក្យបង្អាប់ចំៗចំណុចខ្សោយនាង ....នាងមិនរង់ចាំឲ្យគេនិយាយចប់ទេក៏លើកដៃទាំងពីរច្រានគេចេញពេញ ទំហឹង តែយុត្តនាគីដឹងចិត្តនាងគ្រប់សព្វហើយ គេមិនព្រលែង នាងឲ្យទៅរឹតតែឱបនាងមកកៀកហើយ ត្រដុសច្រមុះទៅលើថ្ពាល់នាង ជាមួយប្រយោគខ្សឹបៗ៖

«និយាយលេងផងមិនបាន!??? ទៅណា?»
ស្រីស្អាតក្តិចខ្ទាំប្រាថ្នាឲ្យគេលែងនាងវិញភ្លាមៗ ព្រោះនាងទើបនឹងត្រូវមាត់ម្តាយធំហើយ ប្រសិនបើលើកនេះគាត់បានមក ឃើញជាយថាហេតុទៀត នាងនឹងត្រូវស្ត្រីនោះមាក់ងាយពេញទំហឹងមិនខាន។
«បើលោកមិនលែង ខ្ញុំនឹងឈប់រវល់ជាមួយលោកមួយជាតិនេះ យុត្តនា!»
នាងខាំមាត់និយាយដាក់ត្រចៀកនាយ។ បុរសដឹងថានាងមានភាពតឹងតែងចិត្តពិតប្រាកដនាង១០០% មិនទទួលយកកាយវិការស្នេហានេះ គេក៏លែងនាងសន្សឹមៗ ហើយប្រែទឹកមុខទៅស្មើដូចដើម។ ស្រីស្ងួនងាកមុខដែលក្រហមដូចភ្លើងនោះចេញពីខ្សែភ្នែកនាយជាមួយវាចាបន្ត៖
«បើលោកចេះគិតពីខ្ញុំបន្តិច លោកមិនធ្វើរឿងខូចឈ្មោះអស់នេះទេ!»
ដឹងអីគេស្រាប់តែញាក់ចិញ្ចើមវាចាតមកភ្លាម៖
«ហើយបើខ្ញុំមិនគិតពីនាង អាបងនាង វាបែកកញ្ជាប់មាត់រត់ទៅឲ្យពេទ្យដេរផ្អើលគេឯងបាត់ហើយ!»
មុនពេលឈានជើងចាកចេញពីនាងទៅ គេនៅឱនមកនិយាយជាចុងក្រោយ៖
«បើនាងមកដេកឱបខ្ញុំជាប់មិនឲ្យងើបទៅណារួច ប្រហែលជានាងអាចការពារវានោះបានយូរ!»
គេចាកចេញទៅ ឯស្រីពៅគឺខឹងថប់ណែនទ្រូង។
នាងសម្លក់ក្បាលរ៉ូមីណេទឹកតែម្នាក់ឯង ដែលបុរសនោះបើកចោលឈ្យូរមិនខ្ចីទាំងបិទ....
«លោកពិតជា អ្នកលេងមែនហើយយុត្តនា!!! មនុស្សហិង្សានេះ!»
នាងគិតក្នុងចិត្តទាំងក្តៅក្រហាយ...

ជំពូក៦

ដែនព្រៃទីស្នេហ៍

....នៅឯណោះ អ្នកប្រុសទីពីរឈប់ឡានងឹត....ហើយស្ទុះចុះមករកស្រីតូចនៅបាំងខាងក្រោយ....មេឃនៅងងឹតស្លុបនៅឡើយ...អ្នកដឹងថាកាលដែលបណ្តោយឲ្យនាងនៅ ឈរតោងម្នាក់ឯងនៅលើនោះ នាងច្បាស់ជាភ័យខ្លាចមិនខាន។
«សក្ខណា ឆាប់ចុះមក!»

នារីអភិជនប្រកបដោយមុខស្លេកស្លាំង ក៏នៅតែប្រកាន់គេដែលមិនហៅនាងថាអ្នកនាងដូចពីមុន គ្រាន់តែនាងមិនមាត់មិនកថាឲ្យគេឆាល់ៗទៀតទេ ព្រោះកំពុងពេញចិត្តនឹងភាពអង់អាចរបស់គេ។
នាងបោះដៃទៅឲ្យគេជួយទាញនាងចុះ។ ពេលមកដល់ដីគេមិនត្រឹមមិននាំនាងឡើងរថយន្តខាងមុខទេបែរជា ក្រឡេកឆ្វេងស្តាំហើយទាញនាងរត់តម្រង់ផ្លូវលំមួយ។ នាងមិនយល់ពីបំណងគេតែក៏មិនហ៊ានបង្អង់នៅ តែតាមផ្លូវនាងឆ្លៀតសួរតិចៗ៖
«ចុះពីឡានធ្វើអី? គ្មានឡានជិះទៅភ្នំពេញវិញម៉េចកើត?»
គេមិនឆ្លើយតែបែរជានិយាយពីរឿងផ្សេងទាំងភ្នែកក្រឡេបក្រឡាប់៖
«នាងចាំខ្ញុំនៅទីនេះ! ខ្ញុំយកឡានទៅលាក់!»
គេរត់ទៅដោយមិនរង់ចាំចម្លើយពីនាងនោះទេ។
នាងតាមសម្លឹងគេដែលថយឡានទៅទុកក្នុងគុម្ពោតព្រៃ ស្រីតូចដឹងថាតាមពិតគេកំពុងគេចចេញពីការតាមដានរបស់ពួកនោះ ដោយលាក់អត្តសញ្ញាណពួកខ្លួន ហើយទោះពួកបីនាក់នោះខលហៅគ្នាវាផ្សេងជិះមកស្ទាក់ផ្លូវក៏មិន ងាយនឹងរកឃើញដានអ្វីដែរ បើនាងនិងអ្នកប្រុសចុះពីឡានទៅហើយនោះ។
គេបកមកវិញជាមួយទឹកសុទ្ធក្នុងដៃពីរដប។ វាប្រហែលជារបស់អាបីនាក់នោះគឺមានត្រឹមតែប៉ុណ្ណឹងនៅលើរថយន្ត គ្មានអ្វីអាចនឹងចម្អែតក្រពះទេ។ ស្រីតូចលើកដៃឱបពោះអង្វរកុំឲ្យកូរខ្លាំងពេក ព្រោះនេះជាភាពវេទនាពិតប្រាកដមួយ ដែលនាងទើបតែជួបក្នុងជីវិត។
«ញ៉ាំទឹកទៅ តែកុំញ៉ាំច្រើនពេកព្រោះយើងត្រូវរត់ទៅមុខឆ្ងាយទៀត!»
គេនិយាយតិចៗ ក្នុងពេលដែលនារីទទួលយកទឹកសុទ្ធពីដៃគេក៏នឹកឃើញដល់គ្រាដំបូងបង្អស់ដែលនាងបានជួបគេក្នុងពេលរថយន្តបើកប៉ះគ្នា។ គេបានហុចទឹកសុទ្ធមកឲ្យនាងដូច្នេះដែរ គឺសកម្មភាពគេនៅតែទន់ភ្លន់ហើយសោះអង្គើយ។
នាងក្រេបផ្សើមបំពង់កតិចៗហើយទើបពោលសួរវិញ៖
«ហេតុអ្វីយើងមិននៅទីនេះរង់ចាំហៅឡានឈ្នួលជិះទៅ?»
រិទ្ធិមិនងាកមុខព្រោះគេហាក់កំពុងស្ថិតនៅក្នុងស្ថានភាពពិនិត្យស្ថានការណ៍ តែមាត់គេតបវិញតិចៗ៖
«មិនងាយមានទេ បើមើលស្ថានភាពផ្លូវនេះ! បើមានក៏គេមិនងាយនឹងឈប់ដាក់មនុស្សកណ្តាលព្រៃអញ្ចឹងដែរ! ជួនកាលទោះឡើងឡានបានក៏ពួកនោះអាចនាំគ្នាតាមរកយើង នៅ

បេនឬក៏វាស្ទាក់ឆែកឡានតាក់ស៊ីតាមផ្លូវ មានតែរកផ្លូវផ្សេងពីផ្លូវជាតិនេះប្រហែលគ្រាន់បើជាង!»
ទឹកមុខសក្ខណាកាន់តែអស់សង្ឃឹម នាងទម្លាក់ដៃទាំងអស់កម្លាំងកាយចិត្ត។ ប្រសិនបើពេលនេះមានទូរសព្ទមួយក៏គ្រាន់បើ តែនេះពឹងលើសំណល់ទឹកសុទ្ធពីរដបនឹងកូនពិលមួយពីពួកជនពាល តើនាងត្រូវឆ្លងព្រៃក្រាស់នេះដោយរបៀបណា។
នាងបញ្ចាំងពិនិត្យស្ថានភាពជុំវិញខ្លួនទាំងសៅហ្មង ស្រាប់តែត្រូវគេថាឲ្យតិចៗ៖
«ឈប់ខ្វះខ្វាយភ្លើងទៅ! កន្លែងដែលនៅអាចមើលឃើញ មិនបាច់ប្រើពិលទេ!»
ណាព្រោះឃ្លានណាអស់កម្លាំងណាសៅហ្មងដែលត្រូវប្រថុយដើរកាត់ព្រៃ នាងចាប់ផ្ដើមយំហ៊ូ តែម្ដងធ្វើឲ្យអ្នកប្រុសទីពីរងាកមកវិញទាំង ហួសចិត្ត។ គេសម្លឹងទៅស្រីតូចដែលអង្គុយទាបចុះហើយផ្ទប់មុខយំ ទុកឲ្យនាងយំបានបន្តិចទើបគេចាប់ពោលថ្នមៗ៖
«សុំទោសដែលខ្ញុំនិយាយខ្វះគួរសម!»
ទោះយ៉ាងណានាងក៏អ្នកនាងតូចដែលត្រូវបានស្រលាញ់ទំយើ។ ចរិតនាងគឺមិនដែលស្គាល់លំបាកស្រណុកនឹងមិនដែលពុះពារអ្វី ម្ល៉ោះហើយរមែងនិយាយស្ដីមិនចេះក្រែងចិត្តនឹងធ្វើអ្វីតាមចិត្ត នឹកឃើញ។ ពេលនេះឲ្យនាងមកបាក់អំនួតកណ្ដាលព្រៃ ទោះយ៉ាងណានាងក៏គួរឲ្យអាណិតជាងខ្លួនអ្នកដែរ។ ឃើញនាងគិតពីផ្ទប់មុខយំមិនត នាយអង្គុយចុះសន្សឹមៗហើយនិយាយបន្ថែមទៀត៖
«ទីនេះមានផ្លូវលំ ជួនកាលក៏អាចថាមានភូមិអ្នកស្រុក! នៅទីនោះយើងនឹងអាចមានទូរសព្ទប្រើផងក៏ថាបាន! យើងត្រូវមានសង្ឃឹមមិនត្រូវអស់សង្ឃឹមទេ!»
ស្រីស្អាតនៅសំងំតែអ្នកដឹងថានាងកំពុងរង់ចាំស្ដាប់អ្នក ទើបរិទ្ធិពោលបន្ថែម៖
«ខ្ញុំឃើញដើមម៉ៃសាក់តូចៗក្បែរៗនេះ! តាមមើលយើងនៅម៉ុំក្រចេះឬមណ្ឌលគិរី! បើអញ្ចឹងមែន តំបន់នេះអ្នកស្រុកមិននិយមរស់នៅក្បែរថ្នល់ទេ គឺគេរស់នៅក្នុងព្រៃស្រួលដាក់អន្ទាក់សត្វនិងរកជ័រ!»

សក្ខណាងើបមុខទាំងយំគគ្រុក នាងនិយាយអណ្ដឺតអណ្ដក៖
«ខ្ញុំអត់ខ្វល់ទេ! លោកត្រូវនាំខ្ញុំចេញពីកន្លែងឆ្គួតៗអស់នេះ! លោកត្រូវខលឲ្យបងប្រុសខ្ញុំយកខ្ញុំទៅផ្ទះវិញឮអត់?»
រិទ្ធិសម្លឹងវង់ភក្ត្ររលើបរលោងរបស់នាងដែលស្រោចដោយទឹកភ្នែក។ ត្រង់ហ្នឹងហើយដែល

គេកាន់តែនឹកដល់ទេពធីតារបស់គេ។ នារីចំពោះមុខនេះត្បិតតែនាងមានភិនភាគស្រដៀង នឹងពៅបញ្ញាជាខ្លាំង ទាំងនិយាយទាំងរបៀបដើរក្រោកអង្គុយ តែហេតុអ្វីចិត្តនាងទន់ជ្រាយ ហើយគ្មានហេតុផលខុសពីប្អូនរួមឪពុក របស់នាងម្ល៉េះ?។ ពិតជាគ្មាននារីណាម្នាក់ដែលអាច ប្រដូចនឹងពៅបញ្ញាបានមែនឬ?

គេធ្វើមុខក្រៀម ព្រោះចំណុចខ្សោយរបស់សក្ខណាធ្វើឲ្យស្រមោលពៅបញ្ញាកាន់តែមាន អានុភាព កាន់កាប់បេះដូងអ្នកមកជំនួយការស្រស់សង្ហា។

គេក្រោកឈរឡើងសន្សឹមៗ ដោយទឹកមុខស្ងួត ស្រាប់តែដៃដ៏តូចហើយទន់ល្មើយរបស់នាង លូកមកចាប់កដៃអ្នកដែរ។ នាងទាញដៃគេដើម្បីយោងខ្លួនឯងក្រោកមកឈរសម្លឹងអ្នកតទល់ ។

«និស្សិតស្រុកអាមេរិកពិតជាប៉ះមនុស្សប្រុសស្និទ្ធស្នាលដល់ថ្នាក់ហ្នឹងមែន?»

គេគិតម្នាក់ឯងទាំងមិនស្រួលចិត្ត។

គេងាកមុខចេញលែងមើលនាង តែនាងនៅតែនិយាយមកបន្ថែម៖

«លោកកុំចង់គេចមិនទទួលខុសត្រូវរឿងខ្ញុំឲ្យសោះណ៎ា! គឺលោកជាអ្នកនាំរឿងស៊យអស់នេះ មកឲ្យខ្ញុំ !.គឺលោក....»

នាងចង់និយាយថាដោយសារតែគេជាមនុស្សមានល្បិចជាមនុស្សរបស់ ហួត ស៊ីវ បានជា នាងខំតាមដានគេរហូតដល់កំពង់ស្ពឺហើយត្រូវជនពាលឆ្លៀតឱកាស ចាប់មកបាន តែនាង មិនទាន់បញ្ចប់ផងឃើញគេងាកមកសម្លឹងនាងដោយពន្លឺភ្នែកភ្លឺ មុត នាងទៅជាបញ្ឈប់សម្តី កណ្តាលទីព្រោះយល់ថាបុរសនេះមានប្រវត្តិយ៉ាង ណាមានគោលបំណងយ៉ាងណាក៏ដោយ នាងមិនបានដឹង ពេលនេះបើនាងជ្រុលមាត់បើកកាយកណ្តាលព្រៃឲ្យគេដឹងថានាងបាន តាម ដានដឹងទំនាក់ទំនងគេនឹង ហួត ស៊ីវ អស់តើគេអាចនឹងបំបិទមាត់នាងចោលដែរទេ?

នារីលែងកដៃគេ ហើយលើកដៃបិទមាត់ខ្លួនឯងដោយងាកមុខគេចចេញឃើតៗពីក្រសែភ្នែក គេ តែក៏ទទួលអារម្មណ៍ថាគេមិនបោះបង់ចោលការសម្លឹងនាងឡើយ។ បេះដូងស្រីតូចចាប់ ផ្តើមភ័យ ហើយភ្នែកនាងរេចុះឡើងរង់ចាំមើលប្រតិកម្មរបស់ពីក្រោយខ្នងនាង។

សំឡេងគេលាន់មកតិចៗ៖

«ខ្ញុំអត់គេចទេ! ខ្ញុំក៏ប្រញាប់ទៅវិញដែរ! ប្អូនស្រីនាងពៅបញ្ញាកំពុងនៅក្នុងដៃពួកវា! វាមិនព្រម បញ្ជូននាងមកជាមួយយើងប្រហែលជាមានបំណងអាក្រក់អីផ្សេង ហើយ!»

សក្ខណាចងចិញ្ចើម នាងមិនយល់ទេថាហេតុអ្វីបានជាប្អូនស្រីនាងក៏ត្រូវចាប់មកដែរទេ។ នាងនៅចាំបានថាកាលពីព្រឹកគឺពេលពៅបញ្ញាទៅលុបលាងមុខ នាងក៏បានដេញតាមរថយន្តរបស់បុរសនេះហើយក៏ត្រូវជនអនាមិកដាក់ ថ្នាំសន្លប់ផ្ទប់មុខនៅក្បែរលានកូនគោល។ បើពៅបញ្ញាពិតជាត្រូវគេចាប់ដែរ មានតែនាងបានជិះមកតាមពីក្រោយដែរឬយ៉ាងណា។ តើអ្នកចាប់នោះជាអ្នកណាវាមានបំណងអ្វី? ហេតុអ្វីនាំពីរនាក់មកទល់ដែនម្នាក់ទៀតរក្សាទុក។

នាងនិយាយទាំងសៅហ្មង៖

«វាជាអ្នកណា? ធ្វើរឿងឆ្កួតយក៏អស់នេះធ្វើអី?»

គេមិនមាត់ នាងបែរក្រោយសម្លឹងគេ៖

«ម៉េចលោកដឹងថា ពៅបញ្ញាត្រូវគេចាប់មកដែរ?»

នាងចង់និយាយថា ចាប់ពីពេលនោះមកគឺគេជាប់នៅលានវាយកូនគោល ហើយនាងតាមដានគេជាប់ ចំណែកពៅបញ្ញាចូលទៅលុបមុខនៅបន្ទប់ទឹកស្ត្រីនិយប្រេងឯណោះ ចុះម៉េចក៏រិទ្ធិដឹងពីដំណើរក្រោយមករបស់នាងមេធាវីកើត?

រិទ្ធិតបមួយៗ៖

«គេចាប់ខ្ញុំមកបានព្រោះ គេប្រើលេខអ្នកនាងពៅខលមក! បន្ទាប់មកគេបង្ហាញកាបូបដៃរបស់គាត់ដែលខ្ញុំស្គាល់ច្បាស់»

សក្ខណាវេភ្នែកគិតហើយងាកសម្លឹងទៅរកបុរសដែលនាងកំពុងសង្ស័យថាគេ គិតខុស។ កាបូបនោះគឺនាងជាអ្នកយកចេញរួមទាំងទូរសព្ទនោះផង ថាមិនបានមិនមែនគេនាំទុកនាងទេគឺនាងជាអ្នកនាំទុកដល់គេ។

«អញ្ចឹងលោកមិនដែលឮសំឡេងពៅបញ្ញាទេ???»នាងសួរបញ្ជាក់តិចៗព្រោះកំពុងវវល់គិត។

«អត់ទេ! ពេលឃើញនាងដំបូងខ្ញុំស្មានថានាងគឺគាត់!»

សក្ខណាកើតចិត្តមួហ្មងភ្លាម នាងងរង៉ក់៖

«បើដឹងថាជាខ្ញុំ មិនដឹងថាលោកព្រមជួយឬក៏អត់ទេអញ្ចឹង!»

រិទ្ធិជ្រួញចិញ្ចើម គេដៀងភ្នែកមកមើលនាងដែលធ្វើមុខក្រញូវ ។ គេចង់សើចតែសើចមិនចេញព្រោះយល់ថានាងទៅរៀននាំតែបំបង់លុយបើមក វិញនៅតែគំនិតចង្អៀតហើយតែងតែគ្មានហេតុផលម្ល៉េះៗ។ ឃើញគេមិនមាត់មិនព្រមមកលួងលោមនាង នាងបន្តទៅទៀតវ៉ាវះ៖

«ប្អូនខ្ញុំអត់ត្រូវពីណាចាប់ទេ! គឺកាបូបវានិងទូរសព្ទផងជាប់នៅក្នុងឡានខ្ញុំមក! គេចាប់ខ្ញុំដោយទាំងរបស់វាមក ឮហើយពេញចិត្តឬនៅ? សប្បាយចិត្តណាស់មែនអត់?»

ថាហើយនាងក្រោករឹងដើរលឿនស្លេវឆ្ពោះទៅក្នុងផ្លូវលំតូច។ ដើរបណ្ដើរនាងរអ៊ូបណ្ដើរទាំងសៅហ្មង៖
«គាត់ៗៗៗ! អ្នកនាងៗៗៗៗ! ហៅគេអីក៏ខ្ពស់ម៉េះ? អត់ចេះហត់ទេ? ខ្ញុំវិញលោកគំហកកំហែងសព្វបើខ្ញុំប្រើពិល! មកពីខ្ញុំមិនអ្នកឲ្យប្រាក់ខែលោក? ធុញណាស់! »
មិនដឹងជាគេឮនាងរអ៊ូដែរឬអត់ទេបានជាគេឈានមកតាមនាងប្រឹបៗ ជាហេតុធ្វើឲ្យចិត្តនាងដែលកំពុងទោមនស្សហាក់រំញោចឲ្យជើងទាំងគូ រត់ឲ្យបានកាន់តែឆ្ងាយគេចចេញពីគេ។
«មនុស្សគ្មានចិត្តនេះ ស្រលាញ់ម្នាក់អត់ម្នាក់! ពៅបញ្ញាគេទុកដូចមាសពេជ្រ គ្រាន់តែគេប្រើលេខទូរសព្ទមួយខលទៅក៏ចាប់នាយបាន ចំណែកខ្ញុំនៅមុខនាយឲ្យជ្រងោ អ្នកនាងមួយម៉ាត់ក៏នាយកំណាញ់មិនព្រមហៅ! នាងត្រដរមកតាមរកស៊ី! ត្រលប់ទៅលើកទូលអ្នកនាងរបស់លោកទៅមនុស្សអត់ចិត្ត!»
នាងគិតក្នុងចិត្តបន្ថែមភាពខឹងមួម៉ៅឲ្យខ្លួនឯង ហើយចាប់ផ្ដើមរត់គេចចេញពីភាពច្រណែន។ នាងមិនដឹងទេថានាងកើតទោសៈនេះមិនមែននាងច្រណែនខឹងពៅបញ្ញាទេ តែគឺខឹងបុរសនេះ ព្រោះគេល្អពេក ទាក់ចិត្តពេកហើយរឹងមាំពេកចម្លែកតែក្នុងចិត្តគេគ្មានមនោសញ្ចេតនាឲ្យនាងសូម្បីមួយសរសៃ។
នាងមិនមែនដើរទេគឺរត់ រហូតដល់ដំណើរនាងលឿនពេកធ្វើឲ្យវិទ្ធិត្រូវតែហាឃាត់នាង៖
«កុំរត់លឿនពេក! គ្រោះថ្នាក់ណាស់ណ៎ា!»
បំណាច់នឹងខឹងមនុស្សនេះតើគ្រោះថ្នាក់អីដែលអាចនឹងធ្វើឲ្យនារីខ្លាចនោះ?
សក្ខណាតាំងចិត្តថាមិនខ្វល់នឹងគេ គិតពីបន្តទៅមុខរហូតដល់វិទ្ធិចាំបាច់ត្រូវស្រវាចាប់កដៃនាង មកវិញទោះនាងមិនព្រមបង្អន់ចិត្តមានះគ្រវាត់ដៃនាយចេញអន្ទះអន្ទែង ក្ដី។
ឃើញនាងមិនព្រមឈប់រើ អ្នកប្រុសទីពីរក្រសោបនាងជាប់ក្នុងរង្វង់ដៃព្រោះប្រសិនបើភ្លាត់បាត់នាងនៅក្នុងព្រៃដ៏ធំនេះមុខតែវិវរមិនខាន។ គេនិយាយមួយៗក្នុងពេលតរុណីកំពុងប្រឹងរើចុះឡើងក្រោមកម្លាំងដៃ អ្នក៖
«សត្វច្រើនណាស់! ថ្មើរណេះជាម៉ោងពួកវាចេញរកស៊ី!»

មានប្រសិទ្ធភាពមែននាងស្រាប់តែបន្ថយកម្លាំងហើយទម្លាក់ដៃចោល ទាំងស្រុង។ ភ្នែកនាងបើកគ្រលួងសម្លឹងមកអ្នក មិនដឹងគិតយ៉ាងម៉េចនាងលោតឡើងមកពាក់គាវលើចង្កេះអ្នកតែម្ដង។ មាត់សក្ខណាស្រែកក្នុងពេលដែលវិទ្ធិទៅជាភាន់ភាំង៖

«ពស់! ពស់! ជួយផង!»
អ្នកប្រុសទីពីរនៅស្ងៀមទ្រឹងដោយមានរាងកាយស្រីស្អាតស្អិតល្អួតនៅ លើខ្លួនអ្នក។ នារីនេះមានប្រតិកម្មរហ័សហួសនិងទទួលយកបាន ប៉ុន្តែមិនស្មានថាទីបំផុតនាងធ្វើដល់ថ្នាក់នេះសោះ។ មួយខណៈដែលអ្នកកំពុងស្រឡាំងកាំង នាងហាក់ដឹងខ្លួនមកវិញ ដែលមុននេះគ្រាន់តែគេនិយាយពី«សត្វ»នាងក៏ស្រមៃដល់សត្វពស់តូចធំ ហើយលោតឡើងលើគេមួយទំហឹង ទើបតែភ្ញាក់ខ្លួនមកវិញឃើញខ្លួនឯងលើចង្កេះគេស្អិតថ្នាក់នេះ ក៏នឹកអៀនខ្មាសជាខ្លាំង មិនដឹងធ្វើយ៉ាងណា មានតែស្រែកសន្ធាប់ព្រមទាំងវាយស្មារិទ្ធិភូសៗ៖
«លែងខ្ញុំ លែង!!! ដាក់ខ្ញុំចុះ ដាក់ខ្ញុំចុះឮអត់!?»
នាងរើបម្រះគេក៏ទម្លាក់នាងភឹងអុកគូទញ៉ាច់ព្រោះកំពុងភាំងស្មារតី។
ស្រីតូចសក្ដួណាឈឺស្ទើរថ្លោះចង្កេះ ណាខឹងនាយ នាងស្រែកទាំងទឹកភ្នែក៖
«ទៅវិញ ខ្ញុំនឹងប្រាប់ប៉ាឲ្យបណ្តេញលោកចេញ!»
រិទ្ធិហួសចិត្ត គេអង្គុយចុះបម្រុងជួយលើកនាងឡើង តែនាងប្រើដៃទាំងពីរវាយគេញាប់ស្មេទាំងបិទភ្នែកស្រែកដូចកូនក្មេងមិនដឹងក្តី៖
«ចេញទៅ! មនុស្សគ្មានចិត្តមនុស្សចិត្តអាក្រក់! ចាំមើលតែខ្ញុំជួបលោកប៉ាខ្ញុំ....»
គេហាក់អស់ការអត់ធ្មត់នឹងនាងបានជាគេក្រោកសន្សឹមៗចេញពីនាង ....ស្រីស្អាតវាយគេមិនដល់ ប៉ះត្រូវតែខ្យល់ ទើបដឹងថាគេមិននៅទីនេះទៀតទេក៏បើកភ្នែកឡើងវិញភ្លាមដើម្បីរកមើលគេ។ អ្នកប្រវាសបែរខ្នងដើរចេញទៅ គេមិនមែនថាទៅចោលនាងទេ តែពិតជាធុញទ្រាន់នឹងប្រឈមមុខចំពោះនាងមែនបានជាសម្រេចចិត្តទុក គម្លាតមួយសម្រាប់ឲ្យខ្លួនឯងដកដង្ហើមបានស្រួលបន្តិច។
«បើនាងពិតជាកូនអ្នកធំមានការអប់រំមកសព្វយ៉ាង នាងគួរតែតែចេះគិតពីចិត្តថ្លើមមនុស្សផង ! ខ្ញុំរបួសពេញខ្លួន ក៏អត់ថ្ងូរមួយមាត់ ពោះអត់អ្វីមួយគ្រាប់ទ្រាប់ពោះតាំងពីព្រឹកមក នាងមិនព្រមជួយគិតគ្នាមានតែបង្ករឿងរំវែងឆ្ងាយ មិនចេះចប់ តើខ្ញុំនឹងស្លាប់នៅក្នុងព្រៃនេះ ព្រោះខ្លាហែកចចកស៊ីឬ ប្រេះទ្រូងស្លាប់ព្រោះចរិតរបស់នាង?»

គេគិតក្នុងចិត្តដោយទោមនស្ស ហើយរក្សាភាពស្ងប់ស្ងាត់ ដើរទៅមុខធ្វើឲ្យនារីលើកជើងដែលឈឺឆ្វើកៗដើរត្រឹកៗទៅតាមគេ។ នាងទើបតែដឹងថាជើងនាងឈឺកាន់តែខ្លាំងឡើងៗប្រាកដជាវាគ្រេចពេល ដួលចុះពីលើខ្លួនអ្នកប្រុសទីពីរអម្បាញ់មិញ។

ស្ថានភាពនាង គឺមុខជាដើរមិនទាន់គេទេ ព្រោះថាមើលទៅគេគឺដើរតម្រង់ទៅមុខលែងខ្វល់ពីនាងចំណែកនាងជើង កាន់តែចុកដើរកាន់តែយឺត។ ដូច្នោះហើយ នាងក៏សម្រេចចិត្តបញ្ឈប់កណ្ដាលទី លែងដើរទៅមុខទាំងឈឺចិត្ត។ នាងងាកមុខចេញ ហើយហូរទឹកភ្នែកដូចភ្លៀងឈ្ងោកមកពិនិត្យជើងខ្លួនឯងទាំងអស់ សង្ឃឹម ព្រោះកុំថាឡើយប្រេងរឹតសូម្បីតែអ្វី ក៏នាងគ្មានដែរក្នុងពេលនេះ។

នៅពីក្រោយខ្នងនាងអ្នកប្រុសទីពីរបញ្ឈប់ជើងតែគេនៅបែរខ្នងដាក់នាងនៅឡើយ។ ជាធម្មជាតិរបស់នាយគឺចូលចិត្តតែនារីទន់ភ្លន់ហើយមានហេតុផលតែ ប៉ុណ្ណោះ មកប៉ះនាងតូចសក្ខណាមហាឆ្នាសឆ្នើមបំពានសម្ដីដាក់ខ្លួនម្ដងជាពីរ ដងអ្នកក៏ចេះតែអត់ធ្មត់បាន ព្រោះតែនឹកថាគ្មានអ្វីត្រូវជួបគ្នារាល់ថ្ងៃក៏ខ្ជិលប្រកាន់ ពេលនេះទៀតត្រូវមកកម្សត់កណ្ដាលព្រៃ ត្រូវពាក់ព័ន្ធគ្នាជៀសមិនរួច នាងនៅតែប្រកាន់ចរិតយ៉ាប់មួយទំហឹងអ្នកសឹងថាផុតការអត់ធ្មត់ ព្រលែងនាងឲ្យស្គាល់ ក្ដៅត្រជាក់ម្ដងដែរ តែមិនឮស្នូរជើងនាងតាមមកទៀត អ្នកក៏នៅតែមិនដាច់ចិត្ត។

ប្រុសស្អាតបែរក្រោយសន្សឹមៗទាំងទឹកមុខស្មើ ប៉ះជួននាងកំពុងងើយមើលមកអ្នកដូចគ្នា។ នៅក្រោមរស្មីព្រះចន្ទខៀវស្រទន់ ធម្មជាតិទាំងឡាយកាន់តែមានភាពស្រងេះស្រងោច អ្នកដឹងថាស្ថានភាពនាងគឺដើរមិនរួច....គេប្រុងថាឈរគ្រពាត់ដៃ រង់ចាំមើលនាងចេះកែចរិតហារស្ដីស្លូតទន់ សមជាអ្នកពឹងពគេដែរអត់ តែស្ថានភាពហាក់មិនអំណោយផលទេ ព្រោះថាស្នូរសន្ធឹកម៉ូតូធំៗបោលង៉ាងមកពីចម្ងាយ ។

គេបើកភ្នែកក្រឡោតសញ្ជឹងគិត .....សំឡេងមនុស្សជជែកគ្នាឮជាភាសាអ្វីម្យ៉ាងស្រដៀងវៀតណាមបន្តិចតែ ក៏ស្រដៀងថៃបន្តិច តែវិទ្ធិដឹងថា វាមិនមែនភាសាជនជាតិជាប់ខាងពីរនេះទេ....

«ឡាវ?????»

គេរភ្នែកគិតក្នុងពេលដែលនារីតូចកំពុងអង្គុយត្របោមនៅលើដី បើកភ្នែកមូលក្រឡង់ដោយភ័យរន្ធត់ដូចគ្នា។ អ្នកប្រុសហាក់នឹកឃើញដល់អ្វីម្យ៉ាង គេស្ទុះមកក្បែរនាងហើយលូកដៃគ្រានាងឡើង។

សក្ខណានៅរក្សាការរង់ក់ងរចិត្តច្រើនតាមរបៀបអ្នកនាងតូចផ្ទះធំនៅ ឡើយ។ នាងច្រានគេចេញហើយបម្រះពីគេ តែគេក្រៀកជាប់ហើយខ្សឹបប្រាប់ព្រោះគ្មានពេលវេលាច្រើន៖

«ពួកវាជាគ្នាអាចោរទល់ដែនផងមិនដឹង! គ្នាវាជិះក្រវែលមករកយើងហ្នឹងហើយ!»

នាងទន់ដៃជើងបណ្ដោយឲ្យគេអូសនាំទៅណាមិនដឹងទេ តែនាងគ្មានកម្លាំងរលើងធេង និមិត្តតែឮថាពួកអស់នោះដេញតាមមកនាងស្រមៃដល់ខ្សែចំណងនិង ស្ថានភាពកាលពីថ្ងៃ បើឲ្យនាងវិលទៅរកចំណងនោះវិញនាងមុខជាដាច់ខ្យល់មិនខាន។ អស់ពីបម្រះដល់ពេលនាងតោងគេជាប់ម្ដង ព្រោះខ្លាចគេដាច់ចិត្តគេចពីចោរព្រៃទៅដោយរត់ចោលនាង។

ចុងដៃតរុណីត្រជាក់ដូចទឹកកកមិនមែនមកពីអាកាសធាតុនាវេលារំលង អគ្រាត្រតែមួយមុខឡើយប៉ុន្តែវិទ្ធិដឹងថានាងអស់អំនួតហើយ។ នរៈនាំស្រីតូចពួនជាមួយគ្នាក្បែរគល់ឈើធំមួយមិនឆ្ងាយប៉ុន្មាន ពីមាត់ផ្លូវ ឯត្រចៀកនៅតែតាមដានសន្ទឹកម៉ូតូដែលមានប្រមាណបីបួនគ្រឿងបោលទៅ មក។
«មិនយូរប៉ុន្មានទេ ពួកវានឹងរកឃើញឡានវា ហើយវានឹងរំលើងព្រៃនេះចាប់អ្នកនិងនាងឲ្យខាងតែបាន។ ម្យ៉ាងវាជាអ្នកស្រុកនេះ ភូមិសាស្ត្រគឺច្បាស់ដូចថ្ងៃ! ឯពួកខ្លួនជាអ្នកទីក្រុងរត់យ៉ាងណា ក៏នៅក្នុងបាតដៃគេដដែល!»
គិតហើយគេតឹងតែងចិត្តណាស់ ប៉ុន្តែបើនឹងវាចាទៅពិគ្រោះជាមួយនាងប្រហែលដូចចាក់សាំងលើភ្លើង ព្រោះនាងមិនចេះគិតវែងឆ្ងាយ គ្មានភាពអត់ធ្មត់ផង បើនាងមិនហាស្រែកបែកអាកាសទេ ក៏នាងមុខតែយំលិចព្រៃនេះ ម្ល៉ោះហើយអ្នកមានតែលេបភាពស្មុគស្មាញហើយលួងនាងតិចៗ៖
«កុំមាត់! វារកយើងអត់ឃើញទេ! យើងត្រូវរកភូមិអ្នកស្រុកឲ្យបានមុនថ្ងៃរះហើយខលទៅភ្នំពេញ!»
ស្រីតូចដឹតក់ស្លុត ងក់ក្បាលផ្ញក់ៗតាមគេគ្រប់យ៉ាងខុសពីចរិតមានះច្រណែនប្រចណ្ឌកាលពីមុននេះតែដែលអាសន្នគឺពេលនាងស្រវាខំក្រោកដើរគឹកជើងធ្ងន់ដូច អូសថ្ម៣០គីឡូមកតាម។
នាងប្រឹងដើរឡើងបែកញើស តែទោះដើរក្រោមរង្វង់ដៃ បានគេជួយគ្រាហើយក៏ដើរលែងចង់ទៅមុខដែរ។
នាងនៅសំចតព្រោះឲ្យតែកម្រើកគឺឈឺចុកចាប់ដូចត្រូវបុកនឹងដែកមុត ដល់ឆ្អឹងឆ្អែង។ សក្ខណាបើកភ្នែកគ្រលួងដោយអស់សង្ឃឹមតបទៅកាន់អ្នកប្រុសដែលសម្លឹង មកទាំងចម្ងល់ព្រោះថាកាលៈទេសៈ នេះមិនមែនជាពេលត្រូវឈប់សម្រាកទេ។ ដោយសារសត្រូវគឺនៅជិតបង្កើយប្រុសស្រីទាំងទ្វេមិនអាចនិយាយគ្នា ឬសូម្បីតែហ៊ានដកដង្ហើមឲ្យឮតាមសម្រួលនោះ

ដែរ ដូច្នេះភ្នែកពួកគេជាភាសាដែលអាចឆ្លើយឆ្លងគ្នាបាន។
ខណៈដែលខ្សែភ្នែកគេកំពុងតឿននាងព្រោះស្ថានការណ៍វាបង្ខំពិតមែននោះ នាងអស់សមត្ថភាពក៏គ្រវីក្បាលទាំងទឹកមុខអស់សង្ឃឹមក្នុងន័យថា នាងដើរលែងរួចហើយ។
គេឱនសម្លឹងជើងនាង ......មេឃក្នុងព្រៃគឹងងឹត......មិនដូចនៅផ្លូវលំខាងក្រៅដែលអាចពឹងលើ ពន្លឺព្រះចន្ទនោះទេ រិទ្ធិមើលមិនឃើញជើងនាងទេតែខ្លួនប្រាណនាងចាប់ត្រជាក់ខ្លាំងដែលគេចាំបាច់ត្រូវធ្វើអ្វីម្យ៉ាង។ សំឡេងនាងលាន់មកជ្រែកកាត់អារម្មណ៍តឹងតែងរបស់នាយ ៖

«you go first and I wait here »

ជាលើកដំបូងដែលអ្នកឮនាងនិយាយភាសាអង់គ្លេសមកកាន់អ្នក។ ទោះបីអត្ថន័យវាមិនសូវធ្ងន់ធ្ងរដូចភាសាខ្មែរតែអ្នកចាប់ផ្តើម ខ្លោចចិត្តអាណិតនាង។
អ្នកដឹងថានាងទន់ខ្សោយហើយពូកែយំ តែពេលនេះនាងមិនយំទៀតទេ ព្រោះនាងឈឺពេកហើយអស់សង្ឃឹមពេក។
គេមិនតទេព្រោះពន្លឺភ្នែកនាងសម្លឹងមកបង្ហាញថានារីអភិជននិយាយ មែន ដែលចុងបញ្ចប់ក្នុងវេលាដ៏គ្រោះថ្នាក់នាងក៏មិនដាច់ចិត្តឲ្យអ្នក នៅជាប់អន្ទាក់ជាលើកទីបីដោយសារនាងដែរ។
«ម្នាក់នោះនិយាយត្រូវ! បើលោករត់ម្នាក់ឯង ក្រែងសង្ឃឹមរស់! កុំព្រោះតែខ្ញុំ ឲ្យពួកវាចងលោកបានម្តងទៀត!»

នាងចង់និយាយថាបើត្រូវពួកវារកឃើញ ប្រហែលវាលែងចងហើយព្រោះបានប្រដៅគ្នាវាធ្ងន់ដៃពេក សង្ស័យវាអាចកាត់ទោសអ្នកទាំងពីរភ្លាមៗផងក៏ថាបានតែនាងទប់ មាត់លែងស្រដី។
នាងទទួលអារម្មណ៍ថា គេលែងដៃពីរាងកាយនាងសន្សឹមៗ ហើយខ្សែភ្នែកនៅតែផ្តោតជាប់នឹងពន្លឺភ្នែកនឹងនរបស់នាង ដែលមុតថ្លាកណ្តាលធម្មជាតិបោកទង្គិចស្លឹកឈើលាន់ប្រេះប្រោះ។ នាងហេងហាងហើយប្រាប់ខ្លួនឯងថាប៉ុន្មានដង្ហើមទៀតនេះគេនឹងចាកចេញ ទៅហើយ នៅសល់តែនាងម្នាក់ឯងកណ្តាលវាលរហោស្ថាននេះ។ នាងមិនស្រក់ទឹកភ្នែកហើយមិនអាចទន់ជ្រាយឲ្យគេឃើញទេព្រោះគេអាច ថាមិនដាច់ចិត្តហើយនឹងស្លាប់ទាំងអស់គ្នា ដូច្នេះនាងប្រឹងធ្វើមាំទាំ៖
«លោកត្រូវមើលថៃលោកប៉ាខ្ញុំ ហើយអ្នកម៉ាក់ខ្ញុំ.....»

នាងមិនទាន់ចប់ប្រយោគផង គេឈ្ងោកមកអៀវនាងដាក់លើខ្នង ហើយព្រមានស្រាលៗ៖
«ឈប់និយាយច្រើនទៅសក្ខណា!»
គេបោះជំហានចេញទៅក្រោមភាពស្រលាំងកាំងសាជាថ្មីរបស់នាង។ អ្នកប្រុសទីពីរ ហួត ស៊ីវ មាននារីតូចច្រឡឹងជាងសែសិបគីឡូក្រាមនៅលើខ្នងទៅហើយគេនៅតែធ្វើ ដំណើរបានស្មើស្រាលស្ទើកហើយរហ័សដូចធម្មតា។ ស្ថានភាពគេធ្វើឲ្យនារីតូចច្រមក់ដែលអស់សង្ឃឹមទៅជាចំហមាត់ផ្លុង លែងនិយាយអ្វីចេញ។
....ចុងក្រោយគេពិតជាលីយើងទៅតាម????
គេពិតជានៅតែមិនព្រមបោះបង់ចោលយើងដែលតែងតែឆ្មាសឆ្មើមរករឿងគេហើយ គ្មានហេតុផលដាក់គេនេះមែនក៏អី? គេជាមនុស្សចិត្តព្រះមកពីស្ថានទេវលោកឬមួយគេធ្វើនេះដើម្បីលោក ប៉ាយើង? មានមនុស្សឯណា ថ្មើរណោះក្នុងភាពគ្រោះថ្នាក់យ៉ាងនេះហើយនៅមានភក្ដីភាពនឹងចៅហ្វាយ ដល់ម្លឹង?
ការជិះលើខ្នងមនុស្សវាមិនមែនជាសុកភាពដូចនៅលើរថយន្ត Luxury របស់នាងទេ ហើយកម្លាំងរេចុះឡើងរបស់គេបានធ្វើឲ្យកជើងគ្រេចរបស់នាង ឈឺចុកណែនសឹងផុតដង្ហើមម្ដងៗ តែនាងនៅតែអាចធន់ទ្រាំបាន មិនឆ្លោយសំណោកណាមួយ ដោយផ្ដេកក្បាលទាំងល្វិតល្វៃទៅលើស្មាគេ។
គេអស់កម្លាំងហើយកំពុងពិបាក...នាងដឹងហើយអាណិតគេ....តែការអាណិតនោះ មិនបានយូរឡើយព្រោះនាងក៏ទន់ភ្នែក ក្នុងភាពល្វិតល្វៃ ដែលទីបំផុតនាងចាប់ផ្ដើមលង់សន្សឹមៗទៅក្រោមអាកាសធាតុរងារណ្ដំ ថ្ពាម និង ចំហាយដង្ហើមកក់ក្ដៅរបស់គេដែលលាន់មកកំដរទ្រូងនាង....
«ប៉ែន ពេជ្រសក្ខណា យើងដឹងថាមួយជីវិតរបស់ឯង ឯងនឹងគ្មានថ្ងៃភ្លេចរាត្រីមួយនេះបានឡើយ!»
នាងប្រាប់បេះដូងខ្លួនឯង ហើយបិទភ្នែកបណ្ដោយខ្លួនឯងទៅក្នុងភាពទន់ខ្សោះ....
.....មិនដឹងពេលវេលាកន្លងទៅយូរប៉ុណ្ណា....ស្រីស្នួនភ្ញាក់ដឹងខ្លួនមក វិញហើយស្រវារកស្មាធំមាំទាំងសងរបស់គេដែលនាងនៅតែនឹកសូម្បី តែក្នុងយល់សប្ដិ ប៉ុន្តែនាងបើកភ្នែកចំពេលគេកំពុងដាក់នាងថ្នមៗចុះ ទៅលើគ្រែមួយគ្រោតគ្រាតដូចជារនាប តែមានលក្ខណៈធំតូចមិនស្មើគ្នាឡើយ។
នាងភ្ញាក់ស្មារតីមកវិញហើយបើកភ្នែកទាំងស្រុងជាមួយវាចាស្រាលៗ៖

«ដល់ភូមិអ្នកស្រុកហើយ?»
គេមិនតបតែនាងឃើញបុរសមាឌធំបួនប្រាំនាក់កំពុងសម្លឹងមកនាង។ ស្ថានភាពនាងគឺប្រវេប្រវាក្រោកឡើងអង្គុយកណ្ដាលចំណោមមនុស្សប្រុស សម្បុរខ្មៅភ្នែកធំៗដែលនាំគ្នាចោមរោមសម្លឹងមក។ នាងមិនខ្វល់ថាពួកគេជាអ្នកណា ជាក្រុមចោរទល់ដែនឬអ្នកភូមិឲ្យពិតប្រាកដទេតែនាងស្រវាចាប់ដៃ រិទ្ធិទាំងញ័រខ្លួនភ័យហើយតោងគេជាប់ធ្វើឲ្យ ពួកបុរសអស់នោះកាន់តែបើកភ្នែកធំក្រឡេតសម្លឹងមកប្រុសស្រីទាំង ទ្វេ។
រិទ្ធិកំពុងក្រោកឈរក្បែរគ្រែ ម៉្លោះហើយនាងស្ទុះស្ទាទាំងស៊ើងមើងរកចុះទៅឈរក្បែរគេដែរតែរក ចុះមិនបានព្រោះត្រូវភ្លាត់មាត់ស្រែកអូយ ហើយឈ្ងោកទៅមើលកជើងខ្លួនដែលហើមស្មើសាច់កំភួនទៅហើយ។
សំឡេងបុរសចម្លែកម្នាក់និយាយស្អកស្អាព្ទៗក្នុងភាសាអ្វីដែលនាង ស្ដាប់មិនយល់។ តែមានម្នាក់ផ្សេងទៀតប្រញាប់ប្រែមកឲ្យប្រុសស្រីទាំងពីរយល់៖
«គាត់សួរថាអ្នកទាំងពីរជាប្ដីប្រពន្ធឬអ្វី?»
ស្រីតូចធ្វើភ្នែកម៉ក់ៗសម្លឹងរិទ្ធិក្នុងពេលគេក៏ដៀងមើលមកនាង ដូចគ្នា។ គេដកខ្សែភ្នែកទៅវិញដោយកិរិយារិះគិតយ៉ាងប្រយ័ត្នប្រយែងតែ រហ័សរហួន។ ស្រាប់តែនាងឮគេតបវិញមួយៗ៖
«ពួកខ្ញុំពង្រត់គ្នាមក!»

ស្រីតូចចងចិញ្ចើម តែនាងឈ្ងោកមុខវិញជ្រប់ព្រោះខ្មាសភ្នែកអ្នកទាំងនោះក៏មិនចង់ ឲ្យពួកគេឃើញកំហឹងរបស់នាង។ ចុះបើចាំបាច់ត្រូវកុហកក៏គ្រាន់តែងក់ក្បាលថាជាប្ដីប្រពន្ធ នឹងគ្នាទៅវាចប់ទៅហើយចាំបាច់អីគេប្រឌិតរឿង ដ៏អាស្រូវនេះឡើង?
«ពីណាពង្រត់គ្នាជាមួយលោក?»
នាងសួរក្នុងចិត្តទាំងគ្នាន់ក្នាញ់ស្រាប់តែឮ សូរអ្នកប្រុសទីពីរនិយាយបន្ត៖
«ប៉ាម៉ាក់នាងជាអ្នកធំ ហើយខ្ញុំជាអ្នកក្រ ពួកគេមិនព្រមឲ្យពីរនាក់ខ្ញុំបានគ្នាទេ! ឥឡូវគាត់កំពុងតែឲ្យមនុស្សដេញតាមសម្លាប់ពួកខ្ញុំ!»
ពេលតាចាស់នោះកំពុងបកប្រែនាងក៏រវេភ្នែកគិត នាងយល់ថាគេនិយាយអញ្ចឹងព្រោះចង់ការពារក្រែង ថាពួកចោរទល់ដែននាំគ្នាតាមមករកឃើញដល់ទីនេះ ហើយអ្នកស្រុកអាចនឹងយល់ថាពួកនោះជាដៃជើងឪពុកនាង។

នាងងើបមុខសម្លឹងទៅបុរសទាំងនោះមិនដឹងថាគេកើតចិត្តអាណិតនឹងរក វិធីជួយ ប្រុសស្រីពង្រត់គ្នាមួយគូនេះដែរឬយ៉ាងណាទេ តែនាងកាន់តែមានអារម្មណ៍មិនស្រណុកចិត្តសោះ ព្រោះថាពួកគេមុខកាច ពេកហើយនិយាយភាសាអ្វីក៏នាងស្តាប់ក៏មិនយល់ ពិសេសគេជជែកខ្លាំងៗដូចឈ្លោះប្រកែកគ្នា។
នាងឃើញមានតែបុរសដែលចេះភាសាខ្មែរម្នាក់នោះទេ ដែលទំនងថាស្លូតបូតជាងគេ។ នាងខំសម្លឹងគាត់ហើយនិយាយសួរតិចៗព្រោះទ្រាំមិនបាន៖
«អ៊ំៗ! ពួកគេថាម៉េចហ្នឹង?»
គាត់លាក់ភាពព្រួយបារម្ភក្នុងខ្សែភ្នែកហើយប្រឹងញញឹមបន្លប់ ភាពងឿងឆ្ងល់របស់សក្ខណាហើយគាត់និយាយតបវិញ៖
«មិនអីទេ! រកថ្នាំលាបជើងសិន ចាំព្រឹកចាំគិត!»
រិទ្ធិងៀងភ្នែកមកមើលជើងនាងបន្ទាប់មកគេមើលមុខនាង។ ទឹកមុខគេគ្មានអ្វីជាសញ្ញាធូរស្រាលឡើយអារម្មណ៍សម្ងាត់ប្រាប់នាង ថា គេក៏ដូចនាងដែរគឺកំពុងពិបាកចិត្តរឿងអត្តចរិតបុរសៗប្លែកមុខ ទាំងនេះ ។
នាងព្ទគេនិយាយស្រាលៗទៅកាន់ បុរសចំណាស់ដែលចេះខ្មែរ៖
«អ៊ំ! ជួយរកទូរសព្ទឲ្យខ្ញុំមួយបានទេ! ខ្ញុំមានការចាំបាច់ទាក់ទងទៅភ្នំពេញ!»
នាងអរផើត។ នាងយល់ថានេះជាមធ្យោបាយតែមួយគត់ ហើយនាងក៏ទន្ទឹងរង់ចាំចម្លើយបុរសនោះដូចគ្នាស្រាប់តែគាត់ហាក់ងឹងើ  សំឡេងគាត់លាន់មកភ្លាមៗ៖
«ស៊ីទៅ....វាជាស៊ី.?»
....ថាម៉េច? សូម្បីតែទូរសព្ទក៏គាត់និយាយមិនចេញកុំថាឡើយស្គាល់ថាវាជាអ្វី ....តើនេះជាកន្លែងណា? សម័យនេះទៅហើយមានមនុស្សអត់ស្គាល់ទូរសព្ទដែរ???
...នាងងាកភ្លែតទៅរកនរៈយើង....សញ្ញាណព្រួយបារម្ភសម្ងាត់មួយលេចចេញលើផ្ទៃមុខគេ....

...ស្រីតូចរកតែសួរគាត់បន្តក៏និយាយមិនចេញ ព្រោះថាគាត់ងាកទៅរកក្រុមបុរសមាឌធំហើយនាំគ្នាជជែកអ្វីមួយឡូឡាគួរឲ្យពិបាកចិត្ត។ ដោយមិនដឹងខ្លួនសក្ខណាលូកដៃទៅរកប្រអប់ដៃរិទ្ធិព្រោះនាងភិតភ័យ ឯបុរសក៏ច្របាច់ដៃនាងវិញថ្នមៗព្រោះជាប់រវល់តាមដានសម្លឹងទៅ ក្រុមមនុស្សប្រុសទាំងអស់នោះ។ លុះដល់ដៃស្រីត្រជាក់ពេកគេចាប់អារម្មណ៍មក

វិញថានាងកំពុងភ័យ ទើបទ្រាំក៏ងាកមកមិចភ្នែក ជាសញ្ញាឲ្យនាងអត់ធ្មត់រំងាប់ចិត្តរង់ចាំមើលត ទៅទៀតសិន។ ស្រីប្រុសទាំងពីរនៅសំងំស្ងៀមស្តាប់ពួកគេប្រកែកគ្នាអស់មួយខណៈ ទើប ឃើញបុរសចេះខ្មែរវិលមកវិញ ជាមួយទឹកមុខធូរស្រាលៈ

«បាន! នាំគ្នាទៅដេកសិន! ចាំព្រឹកចាំគិតមើលទៀត!»

គាត់ឲ្យសញ្ញាឲ្យពួកគេដើរតាមអញ្ចឹងហើយនរៈត្រូវអៀវនាងលើខ្នង សាជាថ្មី។ ទោះបីមិន ដឹងថាទៅណាហើយតើពួកគេគិតយ៉ាងណាចំពោះពួកខ្លួន តែក្នុងស្ថានភាពគ្មានជម្រើសនេះ ក្តីមេត្តារបស់ពួកគេជាទីពឹង ផ្អែកចុងក្រោយសម្រាប់កំលោះក្រមុំទាំងទ្វេហើយ។

រិទ្ធិនិងសក្ខណាសុទ្ធតែចង់ដឹងថាតើការពិភាក្សាតឹងតែងមុននេះគេ សំដៅលើវត្តមានកណ្តាល អធ្រាត្ររបស់ពួកខ្លួននោះឬអ្វី? តែគេមិនហ៊ាននាំគ្នាហើបមាត់សួរអ្វីទាំងអស់ដោយសារនៅ តាមផ្លូវ បុរសៗមាឌធំនិងបុរសចេះខ្មែររក្សាការស្ងាត់ស្ងៀមយ៉ាងចម្លែក។ ដើរចម្ងាយ ប្រមាណជិត ៥០០ម៉ែត្រទៀតទៅហើយ រិទ្ធិនៅតែគ្មានបង្ហាញសញ្ញានឿយហត់ម្យ៉ាង ដោយសារអាកាសធាតុត្រជាក់ ម្យ៉ាងចិត្តគេកំពុងបារម្ភចំពោះស្ថានការណ៍ចំពោះមុខ។ នារីយល់ពីប្រការនេះបានជានាងនិយាយតិចៗៈ

«លោកកុំភ្លេចសុំថ្នាំគេឲ្យខ្ញុំលាបជើង អ៊ំនោះថាមានអម្បាញ់មិញ! ខ្ញុំមិនចង់ឲ្យលោកអៀវអញ្ចឹ ងរហូតទេ!»

មិនដឹងយ៉ាងម៉េចគេមិនយល់ពីបំណងល្អនាង បែរជានិយាយតបមកវិញកំបុតកំបុយៈ

«កុំនិយាយច្រើនពេក!»

ដំបូងនាងចង់ប្រកាន់គេដែរតែនាងគិតមកវិញយល់ថាតាមមើលសម្តី នាងដែលហៅគេថា លោកៗហ្នឹងអាចនឹងឲ្យតាចាស់ចេះខ្មែរចាប់ អារម្មណ៍ បានដូច្នេះហើយបានជាគេមិនដឹងធ្វើ ម៉េចឲ្យនាងយល់ក៏បង្ខំឲ្យនាង ស្ងាត់មាត់អញ្ចឹងទៅ។

នាងងើបមុខសម្លឹងកូនផ្ទះតូចមួយមានលក្ខណៈជាខ្ទមផុតពីដីដែរ ប៉ុន្តែទាបប៉ុណ្ណោះមិនខ្ពស់ ប៉ុន្មានទេឯខាងក្នុងខ្ទមគឹងងឹត ស្លុប ។

«មិនមែនយប់នេះត្រូវដេកនៅទីនេះទេដឹង?»

នាងគិតតែនាងដឹងថាអ្វីដែលត្រូវមកដល់គឺគង់តែមកដល់។ ព្រោះពួកគេពិតជាតម្រង់ទៅរក ខ្ទមនោះពិតមែន។

«នេះជាផ្ទះរបស់មេភូមិ! នាំគ្នាដេកនៅទីនេះលាបប្រេងជ្រូកឲ្យជាជើងសិនទៅ!»

នារីវេភ្នែករកមើលបុរសម្នាក់ដែលចេះខ្មែរចង្អុលទៅ។ គាត់នោះជាមេភូមិគឺនាងស្រួលដឹង

ណាស់ដោយសារតាំងពីដើមមកបុរសនោះ មិនសូវនិយាយស្ដីតែគាត់យកចិត្តទុកដាក់ស្ដាប់គេឯងនិយាយតែពេល គាត់ហើបមាត់ម្ដងៗគេឯងនៅស្ងៀមស្ដាប់គាត់ដោយក្ដីគោរព។

ពេលនេះគាត់ក៏មកជាមួយដែរតែទឹកមុខគាត់គឺស្រពោន។ ពន្លឺភ្លើងគប់របស់ពួកគេ ពិតជាភ្លឺគ្រប់គ្រាន់ឲ្យនាងមើលឃើញស្ថានភាពក្នុងខ្ទមតូចដែល មិនដល់បួនម៉ែត្របួនជ្រុងទេ។ទោះយ៉ាងណានៅខាងក្នុងក៏មិនគគ្រិច ពេកដូចដែលនាងគិតដែរ។ កន្ទេលស្អាតមួយត្រូវបានលាក្រាល ដោយបុរសចេះខ្មែរហើយក៏មានវាំងននពណ៌ក្រហមមួយបាំងចំកណ្ដាលបន្ទប់ ផង។ ប្រុសស្រីទាំងទ្វេមិនទាន់បាននិយាយអ្វីផង ស្រាប់តែបុរសនោះប្រាប់បន្ត៖
«ផ្ទះនេះគាត់សង់ឲ្យកូនស្រីគាត់ពេលសែនប្ដី!»
«ចុះនាងទៅណាហើយ?»សក្ខណាសួរឡើងភ្លាមតែរិទ្ធិដឹងថានាងអន្ទះសា ចង់ជួបយ៉ាងហោចណាស់មនុស្សស្រីម្នាក់ ព្រោះឥឡូវនេះជុំវិញនាងគឺសុទ្ធតែមនុស្សប្រុសទាំងអស់។
«នាងស្លាប់ក្រោយការរួចប៉ុន្មានថ្ងៃ! ជាង១០ថ្ងៃហើយ!»
ចម្លើយរបស់គាត់បានទាញបរិយាកាសទាំងមូលឲ្យទៅជាព្រឺព្រួច។ ព្រោះតែអញ្ចឹងបានជាវាំងននក៏ក្រហមទែងហើយថ្មីភ្លឹង។ ស្រីស្អាតគិតម្នាក់ឯងចុះឡើង....«ប៉ែន ពេជ្រសក្ខណានឹងត្រូវដេកនៅខ្ទមដែលខ្មោចស្រីម្នាក់ទើបនឹងស្លាប់ ហើយសង់ដាច់ឆ្ងាយពីគេឯងនេះពិតមែនឬ?»
នាងគិតទាំងស្លន់ស្លោក្នុងចិត្ត ស្របពេលបុរសនោះវាចាបន្ថែម៖
«ដាក់ប្រពន្ធចុះទៅ! ឡើងទៅសំងំបានហើយ!»
«តែ....ទីនេះស្ងាត់ណាស់អ៊ំអើយ!»នាងរអ៊ូទាំងទឹកមុខគួរឲ្យអាណិត។
បុរសនោះដៃជួយលាកន្ទេលបន្ថែមផងនិយាយតបវិញផង៖
«ស្ងាត់ល្អណាស់! ពួកមនុស្សដែលដេញមក មករកក៏មិនងាយឃើញដែរ! »
នាងងាកមករករិទ្ធិឃើញគេមិចភ្នែកឲ្យសញ្ញានាងថាឲ្យឈប់រអ៊ូនាង ក៏នៅស្ងៀមតាមគេប្រាប់។ ដឹងអីនាងមិនព្រមឈប់ពេលបុរសចំណាស់បែរចេញទៅវិញ នាងឆ្លៀតសួរ៖
«អ៊ំអ្ហា មុននេះពួកគាត់ជជែកគ្នាអីឮៗម៉េះ?»
បុរសនោះដកដង្ហើមធំនិយាយពន្យល់៖
«ស្រុកនេះ គេមានទម្លាប់ច្រើនណាស់! សុខៗមានមនុស្សចម្លាយមកគេពិបាកគិតដែរ ព្រោះជូននាំល្អជូននាំចង្រៃ! បើជាប្ដីប្រពន្ធវាមិនអីតែបើមិនទាន់ប្ដីប្រពន្ធហើយពង្រត់គ្នា មក គេខ្លាច

អារក្សអ្នកតាខឹង នាំឲ្យធ្វើស្រែមិនកប កើតអត់ឃ្លានពេញស្រុក! ហើយអាពួកខាងឪពុកនាងក៏ដេញមកទៀត តើគេគិតតស៊ូនឹងវាបានឬមិនបានច្នេះបាននាំគ្នាយៗទាំងបីមក លាក់ខ្លួនឲ្យឆ្ងាយដល់ជើងភ្នំនេះ!»

«ចុះម៉េចពួកគាត់ព្រមជួយពីរនាក់ខ្ញុំ?»នាងសួរបន្ថែមទាំងងឿងឆ្ងល់ពេញក្នុងចិត្ត។

«ព្រោះមេភូមិកាលពីនៅក្មេងក៏មានប្រវត្តិលបស្រលាញ់កូនស្រីមេ កុលសម្ព័ន្ធផ្សេងហើយត្រូវឪពុកម្ដាយគេតាមធ្វើបាបដែរបានជាគាត់ នឹករឿងដើមចង់ជួយពីរនាក់ឯងនេះ!»

នាងនៅស្ងៀម តែរិទ្ធិឆ្លៀតឱកាសសួរបន្ថែម៖

«អ៊ំ! នេះជាភូមិអីស្រុកអី? ផ្សារនៅឆ្ងាយដែរទេ? ហើយបើចង់ជិះឡានមានឡានដែរ? ត្រូវឡើងទៅជិះនៅឯណា?»

បុរសនោះងឹងើគិតបន្តិចទើបឆ្លើយ៖

«កន្លែងនេះនៅកណ្ដាលព្រៃជ្រៅ! ចង់ទៅទល់ដែនឆ្លងទៅស្រុកលាវត្រូវដើរបួនប្រាំយប់បានដល់!ផ្សារ ក្រណាត់ត្រូវទៅទិញនៅទល់ដែននោះហើយ! រីឡានក៏គ្មានទេ!

រិទ្ធិធ្លាក់ទឹកមុខ គេមិនមាត់ហាក់ទុកពេលឲ្យសក្ខណា សួរវិញម្ដង៖

«តែ...ចុះទៅស្រុកខ្មែរ ?»

បុរសនោះមិនទាន់ឆ្លើយ តែត្រូវរិទ្ធិសួរបន្ថែម៖

«នេះនៅជាប់ខេត្តស្ទឹងត្រែងមែនទេអ៊ំ!»

«អ៊ំក៏មិនដឹង! ប្រឹងតែរស់នៅទីនេះតាំងតែពីតូចមក មិនស្គាល់ដើរឯណាឲ្យបានឆ្ងាយផ្ទះមួយយប់អីនឹងគេផងទេ!»

«ចុះម៉េចក៏អ៊ំចេះខ្មែរ?»

«គឺចេះពីម្ដាយឪពុកមក ឥឡូវគាត់ស្លាប់អស់យូរហើយ!»

សេចក្ដីអស់សង្ឃឹមលេចឡើងលើផ្ទៃមុខប្រុសស្រីទាំងទ្វេ តែបុរសនោះមិនទំនងជាមានពេលតាមដានដឹងទេ។ គាត់និយាយមកបន្ថែម៖

«សំងំទៅទម្រាំភ្លឺចាំរកគិតថាធ្វើអ្វីទៀត! មិនបាច់ខ្លាចអីទាំងអស់ ពួកនោះរកពីរនាក់ឯងមិនឃើញទេ បើទុកជារកឃើញក៏ចូលមិនកើតដែរ។ នៅក្រៅមេភូមិឲ្យមនុស្សពីរបីនាក់នេះឈរយាមឲ្យហើយ! »

នរៈនិងនារីទាំងទ្វេងាកមើលមុខគ្នាព្រោះមិននឹកស្មានថា មេភូមិនេះប្រយ័ត្នប្រយែងដល់ម្លឹង? អញ្ចឹងបានជាមុននេះឃើញជជែកគ្នាតឹងតែ្អងណាស់?

បុរសនោះចេញទៅមួយសន្ទុះត្រលប់មកវិញជាមួយ ដំឡូងបួនប្រាំមើម និងចេកទុំមួយស្និត ហើយទឹកមួយកូនប៊ីដុង។ គាត់មិននិយាយអ្វីច្រើនទេព្រោះយប់ជ្រៅហើយ តែបានហុចប្រេងមួយក្រឡតូចឲ្យទៅរិទ្ធិ។

នាយដឹងថានោះជាប្រេងខ្លាញ់ជ្រូកព្រៃលាយថ្នាំបុរាណសម្រាប់ ថ្លោះគ្រេច តែគ្រាន់តែក្លិនវាគឺអាក្រក់ពិបាកទ្រាំ ដែលអ្នកអាចស្មានដឹងថានាងនឹងមិនព្រមលាបដាច់ខាត។ អ្នកប្រុសហៅស្រីតូចដែលអង្គុយត្របោមជង្គង់សម្លឹង កូនចង្កៀងប្រេងកាតមិននិយាយស្ដី។
«ញ៉ាំដំឡូងសិនទៅ!»
នាងរេក្រសែភ្នែកក្រៀមក្រំចេញពីចង្កៀង ហើយសម្លឹងមកអ្នកបន្ទាប់មក គឺក្រឡក្រមួនដែលអ្នកកាន់វាមកជាមួយ។
«លោកមិនមែនមកលាបជើងឲ្យខ្ញុំទេដឹង?»នាងគិតទាំងសម្លឹងគេឆ្ងែរ ហើយទីបំផុតគឺគេពិតជាធ្វើយ៉ាងនោះមែន។ ទោះគេលាបអង្អែលថ្នមយ៉ាងណា ក៏នាងនៅតែត្រូវឈឺចុកចាប់ព្រោះជើងថ្លោះហើមធំពេកទៅហើយ។
នាងលួចសម្លឹងផ្ទៃមុខដែលមិនងាយឃើញស្នាមសើចរបស់គេ។ ស្គាល់គេយូរហើយបើមិនធ្វើមុខស្មើគឺងាកមុខចេញ ប៉ុន្តែម៉េចក៏គេមានភាពទន់ភ្លន់ចំពោះមនុស្សស្រីម្ល៉េះ បើគេចង់សម្ដែងល្ខោនជាប្ដីប្រពន្ធ ក៏មិនសមថាសម្ដែងដល់ថ្នើរណេះដែរព្រោះគ្មានអ្នកណានៅទីនេះ ទេ។ សំឡេងគេស្រាប់តែលាន់មកខ្សឹបៗ៖
«សក្ខណា! មុននឹងក្រោយអាពួកនោះវាគង់តែមកដល់កន្លែងនេះទេ! ជនជាតិភាគតិចទាំងនេះមុននឹងក្រោយក៏នៅតែមិនអាចការពារពួកយើង បានដដែល! នាងត្រូវខំលាបប្រេងនេះឲ្យជា ហើយខំញ៉ាំអ្វីក៏ដោយឲ្យតែអាចញ៉ាំបានដើម្បីមានកម្លាំងរក មធ្យោបាយតទៅទៀត! »
បបូរមាត់គេកម្រើកតិចៗពីក្រោមច្រមុះសមស្រួចដែលនាងមើលឃើញកាលណា គិតថាគេជាបុរសពិសេសបំផុតសម្រាប់នាងក្នុងលោកនេះ ដូច្នេះសម្ដីគេមិនបានធ្វើឲ្យនាងភិតភ័យកោលាហលដូចពេលមុនៗឡើយ។
«ហេតុអ្វីម្រាមដៃគេធ្វើឲ្យយើងបាត់ការចុកចាប់? ហេតុអ្វីច្រមុះយើងអាចធន់នឹងក្លិនជ្រូកដ៏អសោចនេះបាន ?ហេតុអ្វីយើងលែងខ្លាចពួកអស់នោះ? ព្រោះយើងយល់ថាបើទោះបីយ៉ាងណាក៏យើងអាចរត់លូនមកជាមួយគេវា គ្មានអ្វីគួរឲ្យសោកស្ដាយទៀតទេមែនទេ?ឯងឆ្កួតមែនទែនហើយសក្ខណា? គេជាអ្នកជំនួយការម្នាក់ បើទោះអ្នកទាំងពីរមានចិត្តលើគ្នា តើ

ជំទាវម៉ាក់ដ៏វាយឬករបស់ឯងព្រមទទួលគេជាកូនប្រសាដែរ?»
នាងគិតហើយ ក៏នៅទ្រឹងបើកភ្នែកគ្រលួងសម្លឹងនាយ។ ភាគីខាងបុរសវិញ ពេលឃើញនាង មិនមាត់អ្វីសូម្បីតែមួយម៉ាត់ខុសពីចរិតឆ្លេឆ្លារបស់ នាងគេក៏ងើបមុខមកវិញដែរ។ គេមិនយល់ចិត្តនារីដែលកំពុងវើរវាយនៅក្នុងទំនោរអារម្មណ៍ តែបែរជាយល់ថានាងរន្ធត់ពេកដល់ថ្នាក់អស់អ្វីគិតចេញអស់អ្វីនឹង និយាយចេញ។
អ្នកប្រុសទីពីរពោលស្រាលៗ៖
«បញ្ហាអ្វីក៏មានដំណោះស្រាយដែរ! យើងដោះវាសន្សឹមៗទៅ!

នាងនៅតែទ្រឹងសម្លឹងគ្រាប់ភ្នែកគេទាំងសងខាង ....គេនេះអ្នស់? ជាជំនួយការដែលមានប្រាក់ខែប៉ុន្មានរយ? ជាមនុស្សគ្មានបុណ្យយសស័ក្តិអ្វីជុំកំភួនក្នុងសង្គម? ចុះហេតុអ្វីពេលប្រឈមនឹងគ្រោះថ្នាក់គេមិនស្លុតរន្ធត់ហើយគេ សុទិដ្ឋិនិយមយ៉ាងនេះ? បើបងប្រុសជាអភិជនរបស់នាងធ្លាក់ក្នុងស្ថានភាពនេះក៏មិនប្រាកដ ថាអាចគ្រប់គ្រងចិត្តបានល្អដូចគេដែរ? តើគេជាតួប្រុសដែលនាងធ្លាប់តែឃើញក្នុងកុនឬមិនមែន? រូបរាងសង្ហា កម្លាំងខ្លាំងដូចដំរី ហើយមានស្មៀតការពារខ្លួនល្មមស្ងប់ស្ងែងចំណែកចិត្តអត់ធ្មត់វិញ គឺធំទូលាយនិងរាបស្មើដូចមហាសមុទ្រពេលស្ងប់ខ្យល់ បើស្រីណានៅក្បែរគេរបៀបនេះក្នុងខ្ទមកម្សត់នេះ ហើយក្រោមពន្លឺចង្កៀងប្រេងកាតបែបនេះ មិនបើកបេះដូងស្រូបយករូបគេ តើនោះជានារីបេះដូងថ្មមកពីណាទៅ?
បុរសសម្លឹងនាងតប ពេលនាងកាន់តែភ្លឹក គេក៏កាន់តែបារម្ភពីផ្លូវចិត្តនាង។ នាងជាកូនអ្នកមានមិនដែលដើរព្រៃមិនដែលមកជួបស្ថានភាពឃោរឃៅអស់ នេះតើអ្វីៗ កំពុងប៉ះទង្គិចចិត្តនាងកម្រិតណាបានជានាងលែងនិយាយមួយម៉ាត់ទៅ ហើយ?
គេប្រឹងពន្យល់បន្ថែម៖
«កុំតក់ស្លុត! ណ៎ា! នាងទុកចិត្តខ្ញុំទេ? ខ្ញុំនឹងនាំនាងទៅដល់ផ្ទះ ប៉ែន ពេជ្រ វិញឮទេសក្ខណា! នាងត្រូវរឹងមាំ »
បបូរមាត់នាងចាប់ផ្ដើមញ័រ ហើយនាងស្រាប់តែស្រមៃដល់ភ្នំពេញ ដែលសម្ដីគេមុននេះបានធ្វើឲ្យនាងបំភ្លេចវាចោលទៅហើយ។
នាងនិយាយរអាក់រអួល៖
«មែនអ្នស់? យើងអាចទៅវិញមែនអ្នស់?»

គេសម្លឹងនាងដោយពន្លឺភ្នែកស្រទន់។ គេនឹងនយ៉ាងនេះ រឹងមាំយ៉ាងនេះ តើគេអាចប្ដូរគំនិតពីការរើសអើងចរិតមនុស្សស្រីដែលគេស្រលាញ់មក ដាក់ចិត្តសម្លឹងស្រីគ្មានហេតុផលម្នាក់នេះវិញកើតដែរបើស្នេហា ដំបូងរបស់គេគឺគេបានឲ្យតម្លៃទៅលើមេធាវីពៅបញ្ញាលើសលប់ពេកទៅ ហើយ?

តើខ្សែភ្នែកស្រទន់របស់គេ ជាសញ្ញាថាចិត្តគេកំពុងតែទន់ដែរឬមួយគេពិតជាធ្វើវាដើម្បីបំពេញកាតព្វកិច្ចសម្រាប់គ្រួសារ ប៉ែន ពេជ្រ ព្រោះថានាងជាបងស្រីរបស់ស្រីដែលគេស្រលាញ់? ព្រោះនាងជាកូនស្រីម្នាក់ដែររបស់មនុស្សដែលគេគោរព? ឬព្រោះគេជាមនុស្សដែលតែងតែធ្វើបែបនេះចំពោះមនុស្សទូទៅដូចតែ គ្នាទេ?

«យើងនឹងចេញពីទីនេះ! យើងធ្វើបានសក្ខណា!»

នាងនៅស្ងៀម តែគ្រាប់ភ្នែករេរកគ្នាម្ខាងហើយម្ខាងទៀត។ គេនិយាយបន្តនូវប្រយោគចុងក្រោយ៖

«ខ្ញុំនឹងនឹងនាងត្រលប់ទៅផ្ទះវិញ!»

នាងខំញញឹម គឺញញឹមទាំងតឹងតែង ប៉ុន្តែបន្ទាប់មកនាងងក់ក្បាលញាប់ឆ្មេរជាចម្លើយថានាងជឿគេហើយទុកចិត្តលើគេជាទីបំផុត។ ដៃស្រីតូចរាវរកដំឡូងក្នុងកញ្ច្រែងហើយរួសរាន់បកសំបកវា....នាង ធ្វើតាមគេគ្រប់យ៉ាង ហើយនាងបានបំភ្លេចចោលភាពជាស្ត្រីត្រកូលអភិជន បំភ្លេចគម្លាតនិងឋានៈរវាងនាងនឹងគេជំនួសមកវិញនូវពាក្យថា នាងមានសំណាងដែលមានគេក្នុងកាលៈទេសៈបែបនេះ...។

## ជំពូក៧

## ល្ហោនថ្មីរបស់លេខាប៉េង

ប៉ែន ពេជ្រប្រាថ្នា វិលត្រលប់មកដល់ផ្ទះទាំងស្ររឹងជោគ....ក្នុងផ្ទះស្ងាត់ជ្រងំ តែជំទាវស្រស់ឆើតនៅរង់ចាំកូនដូចសព្វមួយដងទាំងទឹកមុខទោមនស្ស...។ អ្នកប្រុសទីមួយផ្ទះ ប៉ែន ពេជ្របោះចោលឡានទៅឲ្យអ្នកបម្រើ ហើយឈានចូលទ្រេតទ្រោតកាត់បន្ទប់ទទួលភ្ញៀវដែលអ្នកម្ដាយកំពុង អង្គុយសម្លឹងមកដោយទឹកមុខក្រញូវ....តាមថារាល់ដងគេនឹងធ្វើខ្លួនជា សុភាពបុរស...ឱនលំទោនឬដើរទៅប្រលោមជំទាវយកចិត្តថ្លើម តែលើកនេះក្រឡេកឃើញគាត់កាលណា ចិត្តគេចេះតែនឹកឆេះឆួល។

អាវរាត្រីស្រស់រលើបពណ៌ទឹកប្រាក់របស់អ្នកជំទាវបង្ហាញសាច់ស ទ្រលុកទ្រលន់ដូចពងមាន់

បក....សម្រស់របស់ស្ត្រីខ្មែរ ហួងពិតជាធ្វើឲ្យកូនប្រុសនឹកឃើញភ្លាមដល់សម្ដីបញ្ឆេះរបស់លេខ ប៉េងដែលស្ទាត់មករកគេក្នុងបន្ទប់ទឹកមន្ទីរពេទ្យ....

«ឧកញ៉ា ប៉ែន ពេជ្រ ឪពុករបស់អ្នកប្រុស សម្រាន្តស្ងៀមនេះ គឺជាស្នាដៃមិត្តទ្រុស្តមិត្ត ហួត ស៊ីវរបស់គាត់...អ្វីៗជាផែនការរបស់វាតែម្នាក់គត់?»

«ឯងនិយាយស្អីគេ? លោកអ៊ំស៊ីវជាមនុស្សល្អ គ្រួសារយើងទាំងពីររាប់អានគ្នាយូរមកហើយ គាត់មកធ្វើអញ្ចឹងធ្វើអី? គ្រប់គ្នាគេថាឯងជាមេខ្លោងក្នុងរឿងចាប់ជំរិតនេះ ....ឯងនៅហ៊ានបង្ហាញមុខមកទៀត?.»

«អត់ទេៗអ្វីៗទាំងអស់ជាល្បិចរបស់ ហួត ស៊ីវ....មកពីអ្នកប្រុសត្រង់ពេកបានជាមិនដឹងរឿងពិតដែលចាស់ៗបាន លាក់ពីត្រចៀកអ្នកប្រុស! អ្នកជំទាវកុសុមាពីដើមឡើយជាសង្សាររបស់ហួត ស៊ីវតែគាត់បានតាមឪពុកម្ដាយមករៀបការជាមួយ ឪពុកអ្នកប្រុស បានជាធ្វើឲ្យ ហួត ស៊ីវ ចងគំនុំនេះទុក មិនងាយរសាយទេ! ចំណែកលោករាជមុនស្លាប់ទៅក៏ប្រគល់មរតកគម្រោងអច្ឆរិយដែល គេល្បីតៗគ្នានោះឲ្យមកឪពុកលោកទៀត ដូច្នេះហើយបានជា ហួត ស៊ីវ តែងតែចង់ឲ្យឪពុកលោកស្លាប់! អាម្នាក់យុត្តនានៅខាងក្រៅតាមពិតជាកូនប្រុសចិញ្ចឹមរបស់វាហើយអាម្នាក់ទៀតឈ្មោះរិទ្ធិដែលនៅជាមួយឪពុកអ្នកប្រុសរាល់ថ្ងៃ ក៏ជាកូនធម៌ទីពីរដែលវាបញ្ជូនទៅជារនុកក្នុង ហើយអ្នកប្រុសខ្លួនឯងក៏ជាកូនធម៌ទីបីដែលវាប្រើប្រាស់លួងលោម ឲ្យលេងឪពុកខ្លួនឯង!»

តាំងពីដើមមក អ្នកប្រុសធំ ប៉ែន ពេជ្រប្រាថ្នា តែងចាត់ទុក ហួត ស៊ីវ ថាជាឪពុកទីពីរ ពិតមែនដោយសំអាងទៅលើក្ដីស្រលាញ់និងកិត្តិយសព្រមទាំងភាព ស្និទ្ធស្នាលដែលបុរសអ្នកមានម្នាក់នោះតែងតែមានចេតនាផ្ដល់ឲ្យ ខ្លួន។ ទើបតែបានឮពាក្យស៊កសៀតរបស់ប៉េង នៅក្នុងបន្ទប់ទឹកនៅឯមន្ទីរពេទ្យនោះទេដែលធ្វើឲ្យចិត្តគេទៅជា វិលវល់។ គេចេញពីទីនោះដោយមិនលាម្ដាយសូម្បីមួយម៉ាត់ហើយ ចាប់ផ្ដើមស្វែងរកការពិតមួយចំនួនជុំវិញអតីតកាលរបស់ប្រុសស្រីទាំង បី....ពេញមួយថ្ងៃនេះគេទទួលបានព័ត៌មានមួយចំនួនជុំវិញការបែកបាក់ គ្នារបស់ ហួត ស៊ីវ និងឪពុកគេដោយសាររឿងស្នេហាត្រីកោណនោះ ហើយចុងក្រោយគេទើបនឹងដឹងជាលើកដំបូងពីរឿងកេរដំណែលរតនៈសោភ័ណ។ សំណួរដដែលៗលេចឡើងក្នុងផ្នត់គំនិតរាយមាយរបស់គេ«យើងត្រូវ ហួត ស៊ីវ បោកប្រើមែនទេ? វាបោកឲ្យយើងលេងឪពុកខ្លួនឯងយកលុយ១១លានដើម្បីឲ្យគាត់ទាល់ច្រក? តាមពិតដោយសារវាបានជាឪពុកម្ដាយយើងលែងលះគ្នា? ចុងក្រោយនេះវាធ្វើបាបឪពុកយើងឲ្យរបួសសម្រាន្តលើគ្រែទៀត?»

ត្រូវសុរាស្រៀងៗផង ចិត្តឆេះឆួលនឹងអាថ៌កំបាំងអតីតកាលនេះផង គេដកខ្សែភ្នែកចេញពីម្ដាយមិនខ្វីនិយាយ មិនខ្វីសួរហើយដើរទ្រេតទ្រោតតម្រង់ជណ្ដើរ។
«ឈប់ភ្លាមប្រាថ្នា!!»
សំឡេងអ្នកម្ដាយលាន់មកត្រជាក់ស្រេបពីក្រោយខ្នង ធ្វើឲ្យអគ្គនាយកសាជីវកម្ម K-P-I ឈប់ជើងនៅពីមុខជណ្ដើរ។

ភាគទី៣៥

លោកជំទាវនៅតែរក្សាភាពម៉ឺងម៉ាត់តាមទម្លាប់របស់គាត់។ អ្នកប្រុសធំ ប៉ែន ពេជ្រប្រាថ្នា គេមិនបែរខ្នងមកទេ ហើយទឹកមុខគេគឺសោះកក្រោះ។ ចន្លោះរវាងសេចក្ដីសង្ស័យថាស្ត្រីជាម្ដាយនៅលួចលាក់មានទំនាក់ទំនង ស្នេហាជាមួយ ហួត ស៊ីវ គឺមានភាគរយខ្ពស់ព្រោះតាំងពីតូចមកនាយតែងតែឃើញពីរនាក់គាត់ចេញ ចូលរាក់ទាក់គ្នា ហើយ ហួត ស៊ីវ ទុកផ្ទះនេះជាផ្ទះអ្នកជិតស្និទ្ធ គាត់ចេញចូលពេលណាក៏បាន។ ស្និទ្ធជាមួយប្រពន្ធតែមិនត្រូវជាមួយប្ដី? រឿងអីថារំលឹកពីករណីទាំងអស់នោះហើយអ្នកប្រុស ប្រាថ្នាមិនកើតជំងឺក្ដៅក្រហាយចិត្ត?
«កូនឯងកើតអីបានជាទៅសេពស្រា?»
គេឆ្លើយតបស្ទើៗ៖
«កូនមិនសប្បាយចិត្ត!»
«ហើយចុះទៅសេពគ្រឿងស្រវឹងហ្នឹងកូនបានអីមកវិញខ្លះ? សប្បាយចិត្តទេ!? ប្អូនស្រីនៅបាត់មិនទាន់រកឃើញ ឪពុកក៏ឈឺ...»
ស្ត្រីជាម្ដាយទើបតែរំលឹកដល់ឪពុក អ្នកប្រុសស្រាប់តែផ្ទុះទោមនស្ស។ គេយល់ថាស្ត្រីនេះតាមពិតដាច់ចិត្តលែងលះប្ដីព្រោះនៅអាល័យសង្សារ ចាស់ ហើយមកធ្វើជាយកចិត្តទុកដាក់ស្អីទៅ ?
គេនិយាយកាត់រឹង៖
«ជំទាវម៉ាក់! កូនងងុយហើយ! មានការអ្វី ចាំព្រឹកសឹមជជែក!»
គេឈានទៅមុខក្រោមភាពភ្ញាក់ផ្អើលរបស់ម្ដាយ។ ជាលើកទីមួយដែលគេខ្វះសុជីវធម៌ដល់ម្ល៉ឹងនិយាយស្ដីមិនសម្លឹងមុខ ហើយនិយាយកាត់ប្រសាសន៍អ្នកមានគុណផង។
ព្រោះមិនដឹងពីកំហឹងដែលនាយខំអត់សង្កត់ចិត្តយ៉ាងលំបាកនោះ លោកជំទាវក្រោកមករឹង៖
«ឈប់សិនប្រាថ្នា! កូនប្រើអាកប្បកិរិយាអីជាមួយម្ដាយ? ស្រីតារានោះមែនទេ?នាងនោះធ្វើ

ឲ្យកូនក្លាយជាអញ្ចឹងមែនទេ ប្រាថ្នា?»
អ្នកប្រុសទីមួយរបស់ ប៉ែន ពេជ្រ ងាកក្រោយទាំងស្មុគស្មាញ។ ទំនាក់ទំនងគេជាមួយស្រីៗគឺស្ងាត់កំបាំងហើយកម្រឲ្យអ្នកផងចាប់ ថ្នាក់បានណាស់ ព្រោះវាជាមុខមាត់ទាំងសងខាងតែលើកនេះត្រូវគាត់លើកមកសួរត្រង់ ៗ គេដឹងថាគាត់កំពុងសំដៅលើបុស្បានារីដែលនាងនឹងគេទើបតែចាប់ផ្ដើម សាជាថ្មី។ សួរវិញរបៀបហួសចិត្ត៖
«ជំទាវម៉ាក់ដល់ថ្នាក់តាមដានរឿងឯកជនរបស់កូន?»
ស្ត្រីក្រពាត់ដៃឆ្លើយទាំងមុខស្មើ៖
«រវាងម្ដាយនិងកូន មានស្អីទៅហៅថា ជារឿងឯកជននោះប្រាថ្នា? ដំរីស្លាប់កូនគិតយកចង្អេរទៅបិទ? ស្ដាប់ណ៎ា! កូនណាក៏ដោយក្នុងផ្ទះនេះ ម៉ាក់ត្រូវការឲ្យម្នាក់ៗ រក្សាឈ្មោះបានល្អ!»
គេសើចខឹកៗបញ្ឈឺគាត់៖
«ចុះអីទៅហៅថាឈ្មោះល្អ? ស្នេហាប្រុសស្រីមានអីអាក្រក់? ក្រែងគេនាំគ្នាចេះមានសង្សារតាំងពីជំនាន់អ្នកម៉ាក់មកម្ល៉េះមែន អត់? ៣០ឆ្នាំមុននោះ គេចេះមានស្នេហាបាន ពេលនេះឆ្នាំ២០១៤ហើយជំទាវម៉ាក់....!»

ស្ត្រីអភិជនបើកភ្នែកធំៗ។ គាត់ភ្ញាក់ផ្អើលនឹងអាកប្បកិរិយាច្រឡោងខាមរបស់កូនប្រុសធំ មិនស្មើនឹងពាក្យដៀមដាមលើកឡើងពីអតីតកាល៣០ឆ្នាំមុនទេ។ គេចាកចេញចោលគាត់ក្នុងពេលគាត់ជ្រួញចិញ្ចើមឈរទ្រឹងរិះគិតពី ប្រតិកម្មដ៏កម្ររបស់គេ។
អ្នកប្រុសឡើងមកដល់មាត់ជណ្ដើរជាន់លើវាក់អើនឹងប្អូនស្រីភ្លោះ ដែលឈរទ្រឹងដោយទឹកមុខស្លូត។គេទម្លាក់ទឹកមុខពេលឃើញនាង ព្រោះយល់ថាខ្លួនកំពុងធ្វើអាកប្បកិរិយាអន់ថយមិនសមជាបុត្រាច្បង ត្រកូលគហបតី តែអ្វីៗជ្រុលអស់ទៅហើយ សម្ដីនិយាយហើយលេបវិញមិនបានទេ គេងាកគំហកដាក់នាងតិចៗ បំបាត់អាម៉ាស់ខ្លួនឯង៖
«ថ្មើរណេះហើយមិនដេកមិនពួន នៅឈរធ្វើអី?»
គេថាហើយឈានទៅរកបន្ទប់ខ្លួនឯងហើយធាក់ទ្វារបិទវិញគ្រាំង ផ្អើលអស់បាវព្រាវក្នុងផ្ទះដែលម្នាក់ៗរកកន្លែងពួន ខ្លាចមេឃបាក់សង្កត់។
សម្លឹងនាយពីក្រោយ អមរាសួរខ្លួនឯងក្នុងចិត្ត ៖
«បងប្រាថ្នា នៅសុខៗបាត់ពីមន្ទីរពេទ្យ តើគាត់ទៅជួបនរណាបានជាមកវិញមួម៉ៅយ៉ាងនេះកើត??ករណីលោកប៉ាឲ្យ គាត់ពិបាកចិត្តឬមួយករណីរបស់សក្ខណា? ចុះហេតុអ្វីសម្ដីគាត់

នៅជាន់ក្រោមដូចជាគាត់បានដឹងពីអតីតកាល អ្នកម៉ាក់ដែរ? ចុះគាត់ដឹងទេថាគាត់នឹងយើង តាមពិតជាកូនរបស់ ហួត ស៊ីវ?»
នាងទម្លាក់ទឹកមុខដោយធ្លាក់ទឹកចិត្ត។
នាងខ្លួនឯងក៏បានធឹកស្រាជោកជាំនៅពេលដឹងពីអតីតកាលនោះ ចុះទម្រាំបងប្រុសដែលធ្លាប់តែក្រអឺតក្រអោង តើគាត់ទទួលយកការពិតនេះរបៀបណា។ នាងលួចសម្លឹងទៅជាន់ខាងក្រោម ....នៅទីនោះស្ត្រីជាម្តាយថយទៅអង្គុយលើសាឡុងទាំងទឹកមុខហាក់គ្មានវិញ្ញាណក្នុងខ្លួន....អមរាដកដង្ហើមធំដើរមួយៗទៅរកបន្ទប់បង ប្រុស....នាងគិតបន្តិចទើបដាច់ចិត្តគោះទ្វារប៉ូកៗ....គ្មានចម្លើយ.....នាង ពង្រឹងស្មារតីហើយរុញទ្វារចូលទៅ....ឯរានហាលខាងមុខ បងប្រុសធំនាងកំពុងតែ ឈរស្រូបខ្យល់តែម្នាក់ឯ។ អាវគាត់ទក់ទីជាមួយក្រវ៉ាត់កដែលស្ទើររដោះស្ទើរចង។
«ឈ្លោះជាមួយជំទាវម៉ាកធ្វើអី?»
គេមិនងាកក្រោយ ក៏មិនតប។ អមរាឈោនបន្តទៅក្បែរបងប្រុសភ្លោះដែលសឹងថាអារម្មណ៍នាយនឹងនាងគឺ ដូចគ្នា។ ក្នុងពេលនេះគឺនាងគ្រាន់តែចង់ដឹងថាគេក៏កំពុងឈឺចាប់ព្រោះរឿង ហួត ស៊ីវ ចូលមកពាក់ព័ន្ធក្នុងជីវិតរបស់គេដែរឬយ៉ាងណា? តែនាងនៅស្ទាបស្ទង់នៅឡើយ។ ស្រីស្អាតផុតគេនៅផ្ទះ ប៉ែន ពេជ្រ និយាយមកបន្ថែម៖
«បងពិបាកចិត្ត ស្អុគស្អាញព្រោះប៉ាក៏ឈឺ សក្ខណាក៏បាត់ ហើយអ៊ំ ហួត ស៊ីវ ក៏....»
«ឯងឈប់រំលឹកពីឈ្មោះតាចាស់នោះអមរា.....»គេស្រែកកាត់រឹងសឹងធ្វើឲ្យអមរាភ្ញាក់ផ្អារក្រោយ។
ប្រាថ្នាងាកមកសន្សឹមៗ ហើយសម្លឹងនាងដោយពន្លឺភ្នែកមុតថ្លា....មើលយ៉ាងណា ក៏មើលមិនឃើញមនោសញ្ចេតនាអ្វីរវាងគេនឹងអគ្គទេសាភិបាលនោះក្រៅតែពី ភ្លើងគំនុំឡើយ។ នាងចងចិញ្ចើមឆ្ងល់ «ឬមួយគេបានដឹងតែពាក់កណ្តាលនៃការពិត? គេដឹងត្រឹមតែប្រវត្តិស្នេហាអ្នកម៉ាក់នឹងបុរសនោះ តែគេនៅមិនទាន់ដឹងថាពួកយើងជាកូនបុរសអ្នកមាននោះទេ?»
នាងវេភ្នែកចុះឡើងទាំងមិនស្រណុកចិត្ត ឯសម្តី ប៉ែន ពេជ្រប្រាថ្នា លាន់មកស្អុកៗ៖
«តានោះហើយដែលច្រណែនតាមធ្វើបាបប៉ាយើងរហូតមក! ឯងនៅហៅវាថាអ៊ំធ្វើអី????»
នាងធ្លាក់ថ្លើមក្តុកហើយថយក្រោយពីរបីជំហាន។ នាងច្បាស់ហើយថាគេមិនដឹងទេពីសមាសភាពខ្លួនឯង ដែលមានឈាមបុរសនោះពាក់កណ្តាលបានជាគេនិយាយវាចាអសុរោះអស់នេះចេញ មកកើត។ តើនាងគួរប្រាប់គេថាម៉េច បើត្រឹមដឹងរឿងពាក់កណ្តាលគេធ្លាក់ក្នុងស្ថាន

ភាពបែបនេះទៅហើយ។
«វាគ្រាន់បើបានមួយថ្ងៃ តែវាគង់តែបានទទួលវិញទេ!»
គេនិយាយទាំងសង្រ្កឹតធ្មេញ។ ជាលើកទីមួយដែលបងប្រុសបញ្ចេញអារម្មណ៍មកខ្លាំងយ៉ាងនេះ។ប៉ែន ពេជ្រប្រាជ្ញា ជាសុភាពបុរសអភិជនតាំងពីដើមមកអ្នកណាក៏ដឹង តែនាងមិនបានដឹងទេថាលេខាប៉េងជាកញ្ជ្រោងដ៏ពិសពុលគឺបុរសនោះមាន វិធីអាចធ្វើឲ្យគេកម្រើកទោសៈខ្លាំងយ៉ាងនេះបាន។នាងមិនដឹងទេថា បងប្រុសធំ មានគម្រោងធ្វើអ្វី ហ្គួត ស៊ីវ ដែលគេកំពុងខឹងថា បានញ៉ៃម្ដាយគេនឹងកកូរគ្រួសារគេ។ នាងបានត្រឹមនិយាយឃាត់តិចៗ៖
«បងឯងស្រវឹងហើយ! គេងទៅ! ចាំស្វាងចាំនិយាយគ្នាទៀត!»
ស្រីស្អាតចាកចេញទៅ ដោយងៀងភ្នែកទៅរករូបថតបងប្រុសដែលឈរកាន់រ៉ឺកែតពីរនាក់ហ្គួត ស៊ីវនៅតាំងលើកូនតុក្បែរដំណេកនៅឡើយ។ បុរសនេះជាមនុស្សដែលគេស្និទ្ធស្នាលគោរពស្រលាញ់ ចាប់តាំងពីគេមានអារម្មណ៍បាត់បង់ឪពុកដោយសារការលែងលះដ៏គួរឲ្យឈឺចាប់ ប៉ុន្ដែពេលនេះ គេដឹងពីអាថ៌កំបាំងរវាងម្ដាយគេនឹងបុរសនេះ ចង់មិនចង់គេរមែងគិតថាគាត់ជាជនទីបីដែលគួរឲ្យស្អប់ខ្ពើមចុះ ទម្រាំគេដឹងថា គេជាកូនឥតខាន់ស្លានៃចំណងស្នេហាគួរឲ្យអាម៉ាស់នោះទៀត?....

ជំពូក៨

មង្គលការកណ្ដាលព្រៃជ្រៅ.......

.....ទឹកសន្សើមត្រជាក់នាពេលទៀបភ្លឺ បបោសអង្អែលក្រមុំកំលោះអ្នករត់លួនទាំងទ្វេឲ្យលង់ជ្រៅទៅក្នុង ដំណេក។...កណ្ដាលភាពស្ងប់ស្ងាត់ជ្រងំឮតែសូរសព្ទសត្វល្អិតទ្រហឹង ស្រាប់តែរិទ្ធិបង្អើបបបូរមាត់និយាយង៉ុលៗ ទាំងភ្នែកបិទជិតឈឹង...
«ប៉ា???? លោកប៉ា....!???»
គេនិយាយមិនខ្លាំងក៏មិនខ្សោយ តែល្មមដាស់សក្ខណាឲ្យស៊ើងមើងចេញពីដំណេក។ ...នារីអភិជនក្រឡេកទៅរកបុរសដែលនៅលង់លក់ក្រោមលំអងសន្សើមពេលព្រហាម ត្រជាក់ដល់ឆ្អឹង។ គេឱបដៃ ធ្មេចភ្នែកទាំងទឹកមុខជ្រីវជ្រួញទំនងជាពិបាកចិត្តរឿងអ្វីមួយ ឬមួយគេបានយល់សុបិនអ្វីដែលមិនល្អពិតណាស់។
....នាងទម្លាក់ភ្នែកទៅឃើញរាងកាយគេមានតែអាវរៀលក្លៀកសមួយ ហើយអាវគេក្រៅគេគឺ

កំពុងនៅលើខ្លួននាង។ អាវកីឡារបស់គេត្បិតតែមិនអាចប្រៀបនឹង ភួយសម្លីនៅផ្ទះបានតែវាជាអំណះអំណាងនៃការយកចិត្តទុកដាក់របស់ គេចំពោះនាងគួរឲ្យទន់ចិត្ត។
បុរសនេះទុកនាងជារបស់ទន់ខ្សោយត្រូវថែរក្សា ហើយខ្លួនគេសុខចិត្តហាលសន្សើមមមើមមាយដូច្នេះ។ នាងរំកិលខ្លួនថ្នមៗតម្រង់ទៅគេព្រោះនេះជារនាប ដែលអាចបង្កសំឡេងឲ្យគេភ្ញាក់បាន។ គេទ្រេតផ្អែកខ្នងលង់លក់ទាំងអង្គុយនៅជ្រុងបន្ទប់ ....ធីតាយើងលើកអាវគ្របសងទៅលើប្រាណគេវិញ ....សាច់ដុំហាប់ណែននិងទឹកមុខពេញលក្ខណៈជាបុរសរបស់គេធ្វើឲ្យនាង ដកដង្ហើមញាប់ហើយអៀនប្រៀន។
នាងចង់ងាកមុខចេញ ព្រោះខ្មាសខ្លួនឯង ដែលមកលបមើលរាងកាយប្រុសកំលោះដូច្នេះ  តែមិនដឹងយ៉ាងម៉េចនាងនៅតែចង់បែរទៅមើលគេម្ដងទៀតសិន ទើបអស់ចិត្ត។ គឺបបូរមាត់គេដែលកម្រនិយាយស្ដីអ្វី តែហាក់មានមន្តម្យ៉ាងឲ្យនាងរំជើបរំជួលចិត្ត។ ឯកំភួនដៃគេ និងចង្កេះគេគ្មានត្រង់ណាដែលនាងមិនធ្លាប់ប៉ះពាល់ទេក្នុងគ្រារត់ លូនដីកម្សត់កម្រកាលពីម្សិល។ នាងដំបូងលោតឡើងលើខ្លួនគេដោយខ្លួនឯងបន្ទាប់មក គឺគេស្ម័គ្រចិត្តបញ្ជិះនាងលើខ្នងលើដីរាប់គីឡូ។ ពេលនាងទន់ខ្សោះកម្លាំងនាងក៏ទ្រោបគេងលើស្មាគេ ....តើនាងនៅអ្វីទៀតដែលរក្សាគម្លាតរវាងបេះដូងនាងទៅកាន់បេះដូងគេ បាន?
ស្រីតូចបង្ខំចិត្តខ្លួនឯងឲ្យបកមករកការពិតវិញ ហើយថយចេញយឺតៗពីកន្លែងគេ ស្រាប់តែប្រអប់ដៃគេដែលធំមាំ លូកមកចាប់កដៃនាងជាប់ ។
ស្រីតូចធ្វើភ្នែកក្រឡឹបក្រឡាប់ ព្រោះភ័យផងអៀនផង។ នាងមិនទាន់ហ៊ានងាកក្រោយទេ ព្រោះមិនដឹងថាគេចាប់ដៃនាងព្រោះមមើឬមួយគេដឹងខ្លួនពេលនាង សម្លឹងរាងកាយគេ។
បរិយាកាសស្ងាត់ស្ងៀម នារីដាច់ចិត្តបែរក្រោយយឺតៗដែលធ្វើឲ្យនាងភ្ញាក់ក្រញ៉ាង ព្រោះបុរសនោះកំពុងបើកភ្នែកទាំងគូសម្លឹងមកនាង។ កែវភ្នែកគេស្រទន់ហើយបបូរមាត់គេស្ទើរស្ទើ ស្ទើរញញឹមធ្វើឲ្យបេះដូងនាងលោតភឹបៗស្ទើរដាច់ដង្ហើម។
«គេដឹងថាយើងមើលគេ? ចំមែនហើយសក្ខណា!»
នាងឈ្ងោកមុខងាកមុខចេញ តែពីកន្ទុយភ្នែកនាងឃើញគេកម្រើកអង្គុយត្រង់ខ្លួន ឯដៃក៏នៅមិនលែងដៃនាង។
នាងធ្វើមុខមិនសម ព្រោះវាជាអារម្មណ៍រវាងប្រុសកំលោះនឹងស្រីក្រមុំ ដែលពិបាកនឹងពន្យល់។
«ចង់ធ្វើអី?»គេសួរនាងតិចៗ។

សំឡេងគេស្រាប់តែពីរោះដល់ថ្នាក់ឲ្យបេះដូងនាងថ្លាធ្ងង់ដូចមិនមែន កំពុងនឹកផ្ទះ។ នាងមិនឆ្លើយ តែនាងដឹងថាគេយល់ ដៃគេមួយទៀតលូកមកប៉ះប្រអប់ជើងនាង ហើយសំឡេងគេលាន់មកស្រាលៗបន្ត៖

«ដើរសាកឬនៅ?»

ស្រីតូចរវេភ្នែកសម្លឹងមកប្រអប់ជើងខ្លួនឯង។...ខ្លាញ់សត្វពិតជាពូកែ ដល់ម្លឹង? ប៉ុន្មានម៉ោងសោះអាចធ្វើឲ្យ បុរសនេះលែងអៀវនាងបានទៅហើយ?

នាងងក់ក្បាលតិចៗជាសញ្ញាថាលេងឈឺហើយ។ នាងមិនមើលគេតែ នាងដឹងថាគេកំពុងសម្លឹងមុខនាងបន្ត មិនដឹងធ្វើយ៉ាងណាក៏និយាយបន្លប់៖

«មិញនេះលោកមមើ!»

នាងនិយាយចប់ហើយគេក៏នៅតែគ្មានប្រតិកម្មអ្វីនាងងើបមុខសម្លឹងគេ ដែលស្ងប់ស្ងាត់គួរឲ្យគ្រឹត តែគេមិននិយាយមិនមែនថាមិនមើលមុខនាងទេគេនៅតែសម្លឹងមកនាងដោយ ត្រង់ៗគ្មានខ្លាចចិត្ត។ នារីជ្រួញចិញ្ចើម សួរផ្ទួង៖

«លោកឮខ្ញុំនិយាយអត់?»

អ្នកប្រុសទីពីរញញឹម សម្លឹងទៅវង់ភក្ត្រដែលគ្មានសេសសល់សូម្បីតែភាពកាចឆ្នាស។ ស្រីម្នាក់នេះប្រហែលជម្រុះចរិតអ្នកនាងតូចគ្មានហេតុផលរបស់នាង ទៅតាមដងរុក្ខវិថីកាលពីរាត្រីមិញអស់ហើយមើលទៅ។ គេញញឹមសួរវិញ ក្នុងសូរស័ព្ទតិចៗ៖

«ហើយចុះម៉េចទៀត?»

បុរសនេះនៅមិននៅប្តូរចរិត១៨០ដឺក្រេបន្ទាប់ពីគេគេងហើយភ្ញាក់ ឡើងមកវិញ តើគេកើតអី? នាងគិតហើយនៅតែជម្នះចិត្តអន់អៀននឹងពន្លឺភ្នែកគេ មិនកើតព្រោះមិនដឹងហេតុអ្វីគេមើលមកនាងយូរយ៉ាងនេះហើយនៅតែមិន ដកភ្នែកចេញ? នាងសួរវិញទាំងបូញមាត់៖

«មានម៉េច! លែងដៃទៅ!»

នាងនិយាយតិចៗ ហើយងាកចេញយឺតៗព្រោះមុខហាក់ស្ពឹកៗចុងដៃជើងរាងកាយហាក់ដំណើរ ការយឺតយ៉ាវដោយសារចាញ់ក្រោមឥទ្ធិពលពន្លឺភ្នែកគេ។ គេនៅតែមិនលែងដៃនាងហើយនិយាយមកពីក្រោយត្រចៀកស្រីតូច៖

«ចុះខ្លួនឯង មិនចេះមមើទេ?»

នាងបើកភ្នែកធំៗតែម្នាក់ឯង ឯបុរសសង្ហាក៏តាមមើលមកពីក្រោយខ្នងដដែល។ គេញញឹមតិចៗ ឯនាងគឺញាប់ញ័រ ....ត្រូវហើយដេកដល់ថ្នាក់មិនដឹងថាគេយកអាវមកដណ្តប់ឲ្យតាំងពី

ថ្មើរម៉ាន...ចុះតើយើងមានមមើដែរទេ? ហើយយើងមមើថាម៉េចបានជាគេ ក្រោកមកវិញធ្វើអ្វីប្លែកៗដាក់យើងរបៀបនេះ...?
នារីឈ្ងោកសម្លឹងខ្លួនឯង ហើយខំលើកដៃរៀបរយសំលៀកបំពាក់និងសក់ ធ្វើឲ្យនរៈដែលនៅពីក្រោយប៉ុន្មានចំអាមក្តុកក្តួលចិត្តអាណិតនាង។ ភាពជាអភិជនរបស់នាងត្រូវជំនួសមកវិញនូវកំអែលធូលីដីប្រឡាក់ ប្រលូស ហើយត្រូវចំណាយពេលអស់មួយរាត្រីនៅទីនេះ ក្នុងខ្ទមកម្សត់នេះ។
គេលែងកដៃនាងហើយរំកិលទៅជិតនាង។ ដៃអ្នកប្រុសទីពីរលើកដៃបបោសជម្រុះកម្ទេចផ្កាព្រៃដែលជាប់មក ជាមួយកេសាទន់រលើបវែងប្រះស្មារបស់នាង....ដង្ហើមគេក្បែរត្រចៀកនាងធ្វើឲ្យនាងផ្អាកចលនាហើយនៅសម្ងំស្ងៀមធ្វើភ្នែកក្រឡេបក្រឡាប់....

ហេតុអីកាយវិការគេព្រឹកនេះខុសគ្នាជាមួយស្ថានភាពគេកាលពីពេលមុនៗដាច់ស្រលះ? នាងហើបមាត់និយាយតិចៗក្នុងពេលដៃគេនៅតែប្រទ្បេងលើសក់នាង៖
«និយាយបានឬនៅ? ខ្ញុំមមើថាម៉េចខ្លះ?»
គេមិនមាត់គិតពីបន្តប្រើខ្សែភ្នែកស្រទន់សម្លឹងគ្រាប់សរសៃសក់ នាង។ ស្រីស្អាតបែរក្រោយរឹងប្រឈមមុខនឹងភ្នែកស្រទន់ទាំងគូរបស់គេ នាងរអ៊ូតិចៗ៖
«មេមត់ណាចូលខ្លួនលោកទៅ? ធ្វើភ្នែកដូចខ្មោយ!»
នាងសម្លក់គេកន្ទុយភ្នែកធ្វើឲ្យបុរសរឹតតែគ្នាន់ក្នាញ់ គេលោមកផ្តេកក្បាលលើស្មានាងធ្វើឲ្យស្រីតូចបើកភ្នែកធំៗ។ គេនេះរឹតតែយ៉ាប់ហើយ នៅមិននៅដូរចរិត ហើយដៃដល់ទៀត? ម៉េចគេហ៊ានប៉ះពាល់នាងហើយស្និទ្ធស្នាលនឹងនាងថ្នាក់នេះ ទោះយ៉ាងណាគេគួរកំណត់ព្រំដែនថាគេត្រឹមតែជាជំនួយការឪពុកនាង តែប៉ុណ្ណោះ។
«ខ្មោយឯណាព្រមមកបញ្ចិះអ្នកនាងតូចរត់កាត់ព្រៃភ្នំក្រំថ្ម ឆ្ងាយម្លឹងៗនោះ?»
«អញ្ជឹងលោកជាអីទៅ?»នាងនិយាយទាំងជំទាស់ក្រចកដៃខ្លួនឯងដោយងរង៉ក់។
សំទ្បេងអ្នកប្រុសទីពីរដែលធ្លាប់តែរឹងប៉ឹងបែរមកជាទន់ជ្រាយ លាន់សូរខ្សឹបក្បែរត្រចៀកនាង៖
«ជាស្តេចគ្រុឌ ដែលមានស្លាបធំៗ ហើយនឹងហើរនាំនាងចេញពីព្រៃនេះ!»
នាងស្តាប់ហើយកាន់តែអៀនផងរំភើបផងមិនដឹងធ្វើម៉េចមានតែច្រានគេចេញ ហើយក្រោកដើរតិចៗមកខាងក្រៅខ្ទម។

ខ្យល់ត្រជាក់បក់រំបប៉ះរង់ភក្ត្រក្រហមព្រឿងៗរបស់នាងអមជាមួយការ ទាក់ភ្នែកលើទេសភាពខាងក្រៅខ្ទមដែលហាក់បីដូចជាផ្ទាំងគំនូរ អច្ឆរិយ ក្រោមរស្មីអរុណោទ័យកណ្ដាលព្រៃជ្រៅ។ ពេលដែលចិន្ដាស្រីពៅឲ្យនៅភាន់ភាំងសម្លឹងមិនព្រិចភ្នែកស្ទូរជើង នរៈសង្ហាលាន់មកធូន់ៗពីក្រោយខ្នងធ្វើឲ្យបរិយាកាសទាំងឡាយ ទៅកោះដ៏ជារ៉ូមែនទិកនិងប្រកបដោយសេរីភាពមួយឆ្ងាយសែនឆ្ងាយពីឋាន មនុស្ស។

សម្រាប់យុវនារីយើង នាងញញឹមទទួលយកភាពស្រស់ស្រាយសម្រាប់បេះដូងខ្លួន តែមិនបានប៉ុន្មានផងស្នាម ញញឹមនាងរុះរោយទៅវិញ ព្រោះស្រមោលមនុស្សស្រីពីរបីនាក់បង្ហាញខ្លួនភ្លឹបភ្លែតក្រោយដើម ម៉ៃសាក់តូចជំទើរដែលដុះជាជួរៗ។

ពួកគេគឺពួកបុរសមាឌធំកាលពីយប់....? នាងបែរក្រោយមករកនរៈយើងយ៉ាងរហ័សតែមិនទាន់បាននិយាយអ្វីផង ពួកគេដើរស្រតម្រង់មក ដោយមានអ្នកបកប្រែនោះមកជាមួយដូចគ្នា....

«ឥឡូវយើងជឿហើយថាអ្នកទាំងពីរស្រលាញ់គ្នាមែន មិនមែនពួកមនុស្សពីរនាក់ដែលគេកំពុងតាមរកទេ!»

នាងឡិងឡង់ ឯងរង្វង់ដៃអ្នកប្រុស ទីពីរលូកមកក្រសោបចង្កេះស្រីតូចពីក្រោយភ្លែត។ សំឡេងគេលាន់មក ជ្រែកកាត់ភាពភាន់ភាំងរបស់នាង។

«អ៊ំនិយាយពីអ្វី?»

«កណ្ដាលអធ្រាត្រយប់មិញពួកកុលសម្ព័ន្ធទ្រីយ៉ាន នៅខាងកើតភ្នំនាំគ្នា៦នាក់ នាក់មករកប្រុសស្រីមួយគូដែលគេចរួចបាត់មក។ គេថាជាមនុស្សដែលគេមានកិច្ចការចាប់ចងពីស្រុកខ្មែរមក។ មេភូមិមិនទាន់និយាយប្រាប់រឿងអ្នកទាំងពីរទេ ខ្លាចថាមិនមែនអ្នកទាំងពីរបានជាឲ្យ ពួកខ្ញុំស៊ើបមើលថាតើអ្នកទាំងពីរនិយាយពិតឬកុហក! ខ្លាចថាអ្នកទាំងពីរមិនមែនពង្រត់គ្នាមក!»

នរៈរេភ្នែកដោយពិបាកចិត្ត ព្រោះគេដឹងថាពួកជនពាលស៊ីឈ្នួលចាប់មនុស្ស ពិតជាបានឆ្លងកាត់ភូមិនេះហើយរុករកពួកគេមែន។ ជាទម្លាប់គឺមនុស្សមនុស្សក្នុងព្រៃគេមិនខ្វល់ច្បាប់គុកច្រវាក់ អ្វីទេ បើមេភូមិនេះដឹងថាជានាយនិងនាងមែន គេមុខតែប្រគល់អ្នកទាំងពីរទៅឲ្យពួកវាបញ្ចប់បញ្ហាមិនខាន នេះជាត្រណមរបស់ពួកកុលសម្ព័ន្ធក្នុងការជ្រែកការងារគ្នាទៅវិញទៅ មក។

នេះក៏ល្អម្យ៉ាង ដែលគេមកស៊ើបមើលសិនថាជាមនុស្សតែមួយឬមិនមែន។ គេនិយាយប្រកែកភ្លាម៖
«ពួកខ្ញុំមិនដែលស្គាល់ពួកហ្នឹងទេ! ពីរនាក់ខ្ញុំគឺស្រលាញ់គ្នាចិត្តនឹងចិត្ត អ៊ំជួយពួកខ្ញុំផង!»
ស្រីស្អាតនៅទ្រឹង តែនាងដឹងថាចិត្តនាងកំពុងស្រងល់។ កាយវិការទន់ភ្លន់របស់គេមុននេះតាមពិតជាល្បិចបំភ័ន្តភ្នែកពួកនេះ សោះ។ ប្រហែលពេលនាងកម្រើកទៅជិតគឺគេបានដឹងខ្លួនបើកភ្នែកមកក៏មើលឃើញ មនុស្សទាំងនេះពួននៅខាងក្រៅគេក៏សម្តែងកាយវិការស្នេហាអស់នេះ ឡើងខុសពីចរិតដើមរបស់គេ។

ពេលស្រីស្អាតកំពុងបាក់ទឹកចិត្តនិងអស់សង្ឃឹម នាងខឹងសឹងថាទាញប្រលេះដៃគេចេញហើយច្រានគេឲ្យដួលច្រងាប់ច្រងិល ពីលើខ្ទម តែគេហាក់ដឹងវាមុន បានជាគេឱបនាងកាន់តែណែន។
សំឡេងបុរសចំណាស់នោះលាន់មកបន្ថែម៖
«តែអ្នកទាំងពីរមិនអាចនៅទីនេះយូរទេ!»
ស្រីស្អាតបើកភ្នែកធំៗ។ នាងដឹងថា បើត្រូវគេបង្ខំឲ្យចាកចេញពេលនេះទៅច្បាស់ជាជួបនឹងពួកនោះតាម ផ្លូវមិនខាន។ នាងគិតទាំងភ័យស្លេក តែវិទ្ធិលាន់មាត់សួរមួយៗ៖
«ជើងនាងនៅដើរមិនទាន់បានឆ្ងាយទេ អ៊ំអាណិតឲ្យពួកខ្ញុំលាក់ខ្លួនបានពីរបីថ្ងៃសិនទម្រាំដើរទៅទល់ដែនបាន!»
«ព្រោះអញ្ចឹងបានជាមេភូមិឲ្យមកប្រាប់ថា អ្នកទាំងពីរត្រូវទៅនៅក្នុងវាលសែនអារក្ខបីថ្ងៃសិនសម្គាល់ថាជា ប្តីប្រពន្ធ ទើបអាចគេអនុញ្ញាតឲ្យនៅក្នុងភូមិនេះបាន មិនអញ្ចឹងនឹងចង្រៃឧត្បាតនឹងកើតឡើងធ្វើស្រែចម្ការខូចអស់គ្មាន បានផលអ្វីហូបទេ!»
បុរសនិងនារីមើលមុខគ្នាព្រោះតែគិតមិនយល់ មិនដឹងគាត់ចង់មានន័យថាម៉េច? ដូចនេះបុរសចំណាស់ក៏ពន្យល់ទៀតថាដោយសារអ្នកទាំងពីរពង្រត់គ្នាមក មិនមែនជាប្តីប្រពន្ធនៅឡើយ ត្រូវតែធ្វើកិច្ចតាមទម្លាប់នៅទីនេះរៀបចំសែនព្រេនជាគូនឹងគ្នា នៅវាលសែនអារក្សបង្គ្រប់កិច្ចអាចស្នាក់នៅក្នុងភូមិបន្តបាន។

សក្ខណាប្រាកដជាទើសទាល់ណាស់ចំពោះលក្ខខណ្ឌនេះ ពិសេសនាងកំពុងខឹងនឹងវិទ្ធិជាខ្លាំង តែកាលៈទេសៈនេះបើពួកគេប្រកែកនឹងអ្នកស្រុកគឺមានតែដើរត្រលប់ទៅ រកពួកតាមប្រមាញ់នោះវិញ។

ប្រុសស្រីទាំងទ្វេត្រូវបានអ្នកភូមិមកនាំបំបែកពីគ្នាទៅភូតទឹកនឹងរៀបចំសំលៀកបំពាក់ទៅតាមប្រពៃណីរបស់ពួកគេ។
សក្ខណាត្រូវបែកពីអ្នកប្រុសសង្ហាទាំងចិត្តនាងនៅនឹកគេទោះខឹង ទោះជាគឺនាងមិនចង់នៅឆ្ងាយពីគេឡើយក្នុងកាលៈទេសៈនេះ។
នាងត្រូវបានស្រីៗនាំទៅភូតទឹកជ្រោះមួយកន្លែង ដែលមានទេសភាពស្រស់បំព្រង ហើយពួកគេញញឹមញញែមហាក់រីករាយណាស់តែនាងស្តាប់អ្វីមិនបានមួយ ម៉ាត់គឺមានតែញញឹមតប។ គេនាំនាងទៅដល់ខ្ទមមួយផ្សេងទៀតហើយឲ្យនាងចោមពុងជាមួយក្រណាត់ សំពត់ប្រភេទស្រដៀងនឹងសំពត់នារីឡាវដែលមានពណ៌ចម្រុះច្រើនអន្លើ ហើយស្រស់បំព្រង។
សក់តរុណីយើងចងលំអដោយផ្កាពណ៌ស្វាយស្រទន់មិនដឹងជាផ្កាអ្វីឲ្យប្រាកដ តែដុះជាហូរហែរអមផ្លូវលំក្នុងភូមិ។

បន្ទាប់មកគឺពាក់កម្រងផ្កាធំវែងជុំវិញកនិងកដៃកជើងទៀត។ ពេលតុបតែងរួចរាល់ស្រីៗទាំងនោះចេញទៅណាអស់ទុកឲ្យនាងនៅអង្គុយ ម្នាក់ឯងដោយមានបាយមួយចាននិងសាច់សត្វអាំងលាយអំបិលបុកមួយ ពំនូក។
នារីដឹងថាអ្នកស្រុកនេះចិត្តបានណាស់តែក្លិនពួកគេក៏ធ្វើឲ្យ នាងនៅរអើមនៅឡើយ។ ពេលពោះកូរគ្រូកៗ នាងនឹកដល់សម្តីនរៈយើងកាលពីយប់ «ខំញុំាអ្វីក៏ដោយឲ្យតែអាចញុំាបានដើម្បីមានកម្លាំងរកមធ្យោបាយ តទៅទៀត!»
នាងខឹងគេដែលធ្វើជាទន់ភ្លន់ជាមួយនាង នាងខឹងគេដែលមានល្បិច នៅជិតគេបើមានឱកាសនាងចង់ក្រញៀវគេឲ្យដាច់ដោចសាច់ឈាមអស់ តែពេលនៅម្នាក់ឯងនាងនឹកគេគ្រប់ដង្ហើមចេញចូល។
ធីតាលើកម្រាមចាប់គ្រាប់បាយមកដាក់បញ្ចូលមាត់ទាំងក្រៀមក្រំ។ គ្មានស្លាបព្រាទេជាសញ្ញាថាអ្នកភូមិនេះនៅប្រើដៃបរិភោគនៅឡើយ។ នឹកដល់ត្រង់នេះនាងនឹកដល់ដៃនាយ ដែលព្រឹកមិញបានអង្អែលសក់នាងថ្នមៗ។

សក្ខណាសម្លឹងសក់ខ្លួនឯងក្នុងកញ្ចក់ មិនដឹងយ៉ាងម៉េចនាងស្រាប់តែញញឹមទាំងមិនដឹងខ្លួន....
«តិចទៀតនេះ ឯងសែនព្រេនយកគេធ្វើប្តីពិតមែនទេសក្ខណា?»
នាងស្រាប់តែកម្រើកភាពរំភើបកាលពីព្រឹកឡើងមកវិញ។ នាងហាក់ភ្លេចអស់ទុក្ខ ព្រួយ ភ្លេច

អស់ការខ្ញើមរអើមហើយ ទម្រាំដកអារម្មណ៍បានមកវិញនាងបានហូបបាយអស់ជាច្រើនអន្លើ ដោយមិន ដឹងខ្លួនទៅហើយតែនាងមិនដឹងទេថា នៅឯណោះអ្នកប្រុសទីពីរកំពុងគិតយ៉ាងណា .?...គេរំភើបរំជើបរំជួលនឹង ការសែនអារក្សនេះ ដូចនាងដែរឬអត់?

....ថ្ងៃរះភ្លឺទែង តែអាកាសធាតុនៅតែត្រជាក់ល្ហឹម ប្រហែលជាដោយសារជំនួយពីសំណល់ទឹកសន្សើមលើរុក្ខជាតិតូចធំនោះហើយ មើលទៅ។ វិទ្ធិនៅក្នុងខ្ទមស្ងៀមស្ងាត់ រង់ចាំតែពេលវេលាចេញដំណើរទៅកាន់លានសែនអារក្ស ប៉ុន្តែក្នុងចិត្តនឹកមិនអស់មិនហើយពីការតាមមករបស់ពួកពាល។
ចង់មិនចង់ដែនដីនេះ គេស្គាល់យ៉ាងល្អិត វាសនាអ្នកនិងធីតាអភិជនមិនដឹងជានឹងត្រូវបានការពារដោយសហគមន៍ ក្នុងព្រៃនេះបានយូរប៉ុណ្ណានោះទេ។
គេឈ្ងោកសម្លឹងខ្លួនឯងដែលត្រូវបានបំពាក់ដោយកម្រងផ្កា លើដើមទ្រូងជំនួសឲ្យអាវ....តាមពិតរាល់ដងអ្នកក៏តែងតែចាប់អារម្មណ៍ ណាស់ដែរចំពោះទម្លាប់ផ្សេងៗរបស់ជនជាតិភាគតិចរស់នៅចុងកាត់មាត់ញក ប៉ុន្តែពេលនេះ....ស្ថានការណ៍បែបនេះអ្នកមានអារម្មណ៍មូលឯណានឹង ពិចារណាពីពួកគេ? អ្នកនឹកដល់ស្រីតូចដែលទើបតែបែកចេញទៅ ម្រាមដៃទន់ល្វតរបស់អ្នកនាងដែលមិនដែលស្គាល់កិច្ចនឿយលំបាកតាំង ពីកំណើត មុននេះស្ថិតក្នុងប្រអប់ដៃអ្នក អ្នកដឹងនាងគឺជាអាទិភាព ហើយសុវត្ថិភាពរបស់នាងជាការទទួលខុសត្រូវរបស់ខ្លួន។
«ពៅបញ្ញា! ជំនួយការរបស់ប៉ា....អីគឺបងវិទ្ធិរបស់ឯងនោះគេសង្ហាដល់ហើយ!...ហើយឯងដឹងអត់....គឺគេហ្នឹងណ៎ា....គេអស្ចារ្យណាស់ ....គេអៀវយើងរួច...គឺរត់កាត់ព្រៃ....គេដូច Superman អញ្ចឹង!»
អ្នកប្រុសទីពីរលេចស្នាមញញឹមនៅចុងបបូរមាត់និម្មិតតែនឹកឃើញដល់ ពាក្យពេចន៍ដែលនាងជ្រុលនិយាយចេញមកទាំងមមើមមាយ ពេលគេលើកអាវទៅគ្របឲ្យនាងបិទបាំងពីទឹកសន្សើមរាត្រី។
អ្នកក៏កាន់តែអស់សំណើចពេលនឹកហួសទៅដល់គ្រាមួយដែលនាងច្រឡំមកនៅលើគ្រែរបស់ខ្លួនហើយត្រូវមួយជើងប៉ើងទៅលើឥដ្ឋ។
«ស្រីដ៏គ្មានហេតុផលនោះកំពុងគិតអាម៉េចដែរហ្ន៎ ពេលត្រូវគេចាប់ឲ្យតែងខ្លួនរបៀបអស់នេះ?»
គេរវើ្មករកពំនូកបាយនិងសាច់ក្រៀម តែមិនបានស្រេកឃ្លានទេគឺមានតែគិតអំពីនាងថាតើ

នាងកំពុងផ្សាំ ខ្លួនបាននិងបរិយាកាសនេះ ហើយព្រមបរិភោគវាដែរឬមួយកំពុងតែកើត សៅហ្មងហើយបង្ហាញត្រង់ៗឲ្យ ពួកអ្នកស្រុកដឹង?
គេលូកដៃត្រង់ទៅរកអាហារ ស្រាប់តែទទួលអារម្មណ៍ថាអ្វីមួយលោតមកកន្ត្រាក់រឹបក្នុងបេះដូង បង្ខំឲ្យចង្វាក់ដង្ហើមអ្នកទៅជាញាប់រន្ថើនតែក្នុងមួយរំពេច។ ដូច្នេះចរន្តឈាមដែលរត់ច្របល់យ៉ាងគំហុកបានញ៉ាំងឲ្យម្រាមដៃអ្នក ប្រុសទៅជាញ័រទទ្រើក ហើយបន្តមកដល់ដើមដៃ ជង្គង់ និងដើមទ្រូង។
រិទ្ធិមិនដល់ថ្នាក់ទន់ដៃជើងដួសស្រឹបចុះដូចកាលពីនៅក្បែររបង រោងចក្រកាលពីម្សិលទេ ប៉ុន្តែអ្នកប្រុសដឹងថាស្ថានភាពពេលនេះ គឺត្រូវគ្នាណាស់នឹងការត្រូវមួយម្ជុលរបស់មនុស្សស្រីដែលមានចាក់ សាក់ទ្រូងហើយអង្គុយរង់ចាំគេនៅលើឡានបន្លំជាពៅបញ្ញា។
គេទន់ជើងហើយទប់ខ្លួនដោយអែបស្មាទៅនឹងជញ្ជាំងខ្មមាត់ស្រែកមិន រួច ហើយរាងកាយទាំងមូលស្ទើរតែគាំងមិនអាចបញ្ជាបានគ្រប់ផ្នែក។ ទោះជាយ៉ាងណាក៏ដោយ ស្មារតីគេនៅតែល្អ គេសួរខ្លួនឯងទាំងតក់ស្លុតៈ
«ជាតិថ្នាំម្សិលមិញរើឡើងច្បាស់ណាស់! តើវាចាក់ថ្នាំអ្វីឲ្យយើង? មិនត្រឹមតែជាថ្នាំសន្លប់ តែអាចមានឥទ្ធិពលរើមកក្រោយពីម្ភៃបួនម៉ោង? ឬមួយជាគ្រឿងញៀនបង្ការក្រែងយើងរត់រួច? ពួកជនពាលធ្វើយ៉ាងនេះ ដើម្បីឲ្យអ្នកដែលរត់រួចទៅក្នុងព្រៃចាំបាច់ត្រូវវិលទៅរកពួកវា វិញ?»
អ្នកប្រុសទីពីររបស់ ហួត ស៊ីវ ទន់ជើងរមៀលទៅលើដី បញ្ចប់ការត្រិះរិះរបស់គេជំនួសមកវិញនូវភាពកន្ត្រាក់ញាប់ញ័រលើ គ្រប់សរសៃឈាម។
គេបិទភ្នែកខំប្រមូលស្មារតីឲ្យរឹងមាំតតាំងនិងភាពកក្រើករំពើក ក្នុងសង្វាក់ដង្ហើមនិមួយៗ ជាមួយការព្រមានខ្លួនឯង «ខេមរិទ្ធិ! ខេមរិទ្ធិ! ប៉ាឯងកំពុងមានគ្រោះថ្នាក់ការងារជាច្រើននៅរង់ចាំឯង ឯងមិនអាចបិទភ្នែកទេ ឯងមិនអាចស្លាប់បានទេ!»

បាតដៃគេរកកលនឹងកាច់សាជាថ្មី តែគេខំប្រឹងជម្នះតស៊ូរក្សាលំនឹងឆ្អឹងម្រាមមកវិញ ដែលការជម្នះនេះបានបង្កើតជាកម្លាំងប្រឆាំងដេញតាមសរសៃឈាមត្រលប់ ទៅបេះដូងវិញ ធ្វើឲ្យនរៈយើងចុកពើតស្ទើរគាំងចង្វាក់ដង្ហើមម្តងៗ។
....ការជម្នះនឹងតាំងស្មារតីបានធ្វើឲ្យអារម្មណ៍អ្នកកាន់តែ ភ្លឺស្វាងជាងមុន ទោះរាងកាយនៅមិនទាន់បញ្ជាបានវិញក្តី តែសេចក្តីសង្ឃឹមបានជំរុញឲ្យគេធ្វើសមាធិ ផ្ចង់ទៅរកចំណុចគាំងទាំងឡាយក្នុងរាងកាយហើយចាប់បន្ធូរដង្ហើម សម្រួលវាម្តងមួយអន្លើៗ.....

.... ពេលវេលាកន្លងទៅ បួនប្រាំនាទីដែលគេសំងំដេកដួលលើរនាបតែម្នាក់ឯង គេចាប់ស្រាលដៃជើងមកវិញ ហើយសន្សឹមៗ ញើសសើមស្អិតបានប្រជែងគ្នាសស្រាក់មកផ្សើមរាងកាយអ្នកពីក្បាលដល់ ចុងជើង។ មិនយូរប៉ុន្មាន គេសាកល្បងបញ្ជាម្រាមដៃ ហើយនិងផ្នែកផ្សេងៗ ទៀតរហូតដល់អាចក្រឡាប់ខ្លួនហើយច្រតដៃក្រោកយឺតៗ។
....រិទ្ធិលើកដៃជូតញើសយឺតៗចេញពីផ្ទៃមុខ ឯចិត្តគេកំពុងវេទនាជាមួយចំណោទបញ្ហាថ្មីសន្លាងនេះ....សូម្បីតែមិន មានជំងឺតម្កាត់អ្វីបៀតបៀនផង គេក៏នៅតែមិនទាន់មានពន្លឺក្នុងការចាកចេញដោយសុវត្ថិភាពពីទីនេះ  ចុះបើពេលនេះជាតិថ្នាំដ៏មហន្តរាយនៅតែបន្តយាយីរាងកាយគេនៅឡើយ តើគេនឹងដោះស្រាយអ្វីៗទាំងនេះបានដោយរបៀបណា?

....បុរសៗមាឌធំវិលមកវិញ....ពួកគេដើរមកជាជួរៗជាមួយវត្ថុមួយ ចំនួនដូចជាល្អីគ្រាប់ធញ្ញជាតិ ផ្លែឈើនិងឪទឹនស្រា។ រិទ្ធិដឹងថា អ្នកដល់ពេលត្រូវទៅហើយទើបសម្រួលអាកប្បកិរិយាធ្វើដូចជាគ្មានរឿង អ្វីកើតឡើងហើយចុះពីខ្ទមសំដៅទៅរកពួកគេ។
អ្នកទាំងនោះញញឹមស្វាគមន៍នាយតែគ្មានអ្នកណាម្នាក់អាចសន្ទនាភាសាខ្មែរជាមួយនាយឡើយ។
នរៈយើងដែលពាក់កម្រងផ្កាតែម្នាក់ឯងយ៉ាងលេចធ្លោកណ្ដាលចំណោម មនុស្សរស់ក្នុងព្រៃភ្នំទាំងឡាយ ត្រូវបានគេដង្ហែទៅកាន់វាលរាបមួយចម្ងាយប្រមាណជាបីរយម៉ែត្រពី ទីតាំងដើម។
នៅទីនោះអ្នកឃើញមនុស្សក្មេងចាស់ប្រុសស្រីជាច្រើនសិបនាក់ បានទៅដល់មុនជាស្រេចហើយពួកគេអង្គុយផ្ទាល់ទៅលើរង់ចាំមើលមក ខ្លួនដោយអន្ទះសា។ នៅចំកណ្ដាលលានមានកូនគ្រែឫស្សីតូចមួយ ដែលមានមេភូមិអង្គុយពែននៅលើនោះជាស្រេចជាមួយបុរសអ្នកបកប្រែដែល ឈរពីក្រោយដោយកាន់ភ្លុកមួយគូចងភ្ជាប់គ្នាមានសណ្ឋានដូចជា មកុដ។ បុរសមាឌធំម្នាក់មកនាំអ្នកប្រុសទីពីរ ឲ្យទៅអង្គុយចំពីមុខគ្រែនោះ គឺនៅក្រោមជើងមេភូមិ ព្រោះអង្គុយផ្ទាល់ទៅនឹងដីហើយបែរមុខទៅរកបុរសមានអំណាចម្នាក់ នោះ។

ក្នុងចិត្តជំនួយការរិទ្ធិពេលនេះគឺបារម្ភតែម្យ៉ាងគត់ក្រែងថា ក្នុងចំណោមពលរដ្ឋដែលមកអបអរសាទរទាំងនេះក៏មានពួកអ្នកស៊ើបការណ៍ របស់ពួកជនពាលទល់ដែនមកបង្កប់ស៊ើបមើល។ ម្ល៉ោះហើយ អ្នកមិនសូវហ៊ានងើបមុខត្រង់ៗឲ្យក្រុមមនុស្សបានពិនិត្យទេ ពិសេសបានលេសត្រូវបែររក មេភូមិទៀត គេរឹតតែមិនខ្វល់នឹងពលរដ្ឋទាំងនោះតែម្ដង។

មេភូមិសម្លឹងមុខនាយដោយពេញចិត្ត ហើយលូកដៃទៅទាញស្មែងពីដៃបុរសអ្នកបកប្រែ យកមកពាក់លើក្បាលខ្លួនឯងធ្វើឲ្យទឹកមុខគាត់កាន់តែមានអំណាច។ គាត់លូកយកក្រឡអ្វីមួយពីក្នុងអាវមកបើកចេញហើយប្រើម្រាមដៃបៀក សារធាតុរាវម្យ៉ាងមានពណ៌ក្រហមងៅ ហើយធ្វើជាសញ្ញាឲ្យរិទ្ធិខិតចូលមកជិត។
ពេលគេងើបមុខមើលដោយងឿងឆ្ងល់ បុរសនោះប៉ាតជាតិពណ៌ក្រហមត្រង់ខ្នង់ច្រមុះនរៈយើង ជះក្លិនអ្វីម្យ៉ាង ដូចជាលោហិត។ រិទ្ធិង៉េមង៉ាមព្រោះងឿងឆ្ងល់ស្រាប់តែបុរសចេះខ្មែរប្រញាប់ពន្យល់ ភ្លាមៈ
«នេះជាឈាមសត្វក្របី ដែលទើបតែសម្លាប់មកសែនអារក្ស! លោកមេភូមិបានផ្តល់មង្គលនេះដល់ក្មួយឯង ហើយភាពសក្តិសិទ្ធិទាំងឡាយនឹងនៅជាមួយក្មួយឯង!»
គេនៅស្ងៀមរកពាក្យនឹងស្តីមិនចេញមួយម៉ាត់ព្រោះហួសចិត្ត ថាសម័យកាលនេះទៅហើយនៅតែមានរបៀបរបបបែបនេះទៀត។ ស្រាប់តែបុរសមេភូមិនិយាយតអ្វីៗឮប៉ុន្មានឃ្លាមកកាន់អ្នកធ្វើ ឲ្យអ្នកប្រុសទីបីកាន់តែឡឹងឡង់ព្រោះមិនយល់សេចក្តី។ បុរសចំណាស់ប្រញាប់ប្រញាល់បានឱកាសក៏បកប្រែសម្តីភ្លាមដែរថាៈ
«គាត់សួរថា ក្មួយព្រមទទួលគាត់ជាឪពុកទេ?»
សំណួរនេះធ្វើឲ្យអ្នកប្រុសកាន់តែស្លន់ស្លោព្រោះនៅសុខៗពួកគេ រវល់ទាំងភូមិដោយសារនាយមានទាំងចំណាយពេលកាប់សត្វក្របីទៀត ពេលនេះមកសួរនាំរឿងកូននិងឪពុក អ្នកកាន់តែភាន់ភាំង។ដោយសារនាយមានទម្លាប់ជាមនុស្សគិតមុនគូ មិនងាយនិយាយមិនងាយមាត់ប៉ប្លូចនោះភាពស្ងៀមស្ងាត់របស់នាយធ្វើឲ្យ ពួកអ្នកស្រុកកាន់តែមានមន្ទិល។ ស្រាប់តែបុរសអ្នកចេះខ្មែរ និយាយបន្ថែមមកភ្លាមៈ
«ព្រមទៅ! មានតែកូនគាត់ផ្ទាល់ទេទើបឪពុកអាចរៀបការឲ្យបាន!»
រិទ្ធិដំបូងនៅទីទើរ តែមកឃើញទឹកមុខបុរសនោះតឿនពេកអ្នកក៏មើលឃើញពីភាពចាំបាច់ដែល សម្តែងចេញលើទឹកមុខរបស់តាចេះខ្មែរនោះស្រាប់ គេងក់ក្បាលយឺតៗ ហើយអ្នកភូមិក៏នាំគ្នាហ៊ោក្រេវ។

«តើនេះជាឱកាសឲ្យយើងកាន់តែមានខ្នងបង្អែកឬមួយបន្ថែមភាពស្មុគស្មាញឲ្យខ្លួនឯង?» គេដណ្តឹងសួរក្នុងចិត្តស្ងាត់ៗ ស្របពេលមនុស្សម្នាកាន់តែហ៊ោកញ្ជ្រៀវជាងមុន។ គាត់មិនចង់ខ្វល់នឹងអ្នកស្រុកអស់នោះទេ ព្រោះចិត្តកំពុងវឹកវរពេញបន្ទុកហើយព្រោះនៅសុខៗត្រូវមកធ្វើ

ពិធី អ្វីមិនដឹងហើយត្រឹមត្រូវងក់ក្បាលទទួលយកមនុស្សមិនដែលស្គាល់ គ្នាម្នាក់និយាយគ្នា ស្ដាប់មិនបានមកធ្វើជាឪពុក ហើយជាតិថ្នាំនៅក្នុងខ្លួនក៏មិនដឹងនឹងរើឡើងមកវិញពេលណា ទៀត ប៉ុន្តែដោយសារសូរសម្លេងហ៊ោកាន់តែខ្លាំងទៅៗ គាត់ក៏ងើបមុខសម្លឹងទៅទិសដៅនៃ សូរសំឡេងដឹងអី គេរកតែរវេភ្នែកចេញមកវិញក៏ មិនរួចព្រោះនារីស្អាតៗស្លៀកពាក់ស្រស់ៗ មួយក្រុមធំបានបង្ហាញ ខ្លួន ហើយសន្សឹមៗ ក្រមុំសក្ខណាដ៏ស្រស់ផូរផង់បង្ហាញខ្លួន ដោយ អៀនប្រៀនក្នុងចំណោមពួកគេ។

ស្រីស្អាតចោមពុងជាមួយសំពត់ពណ៌ចម្រុះច្រើនអន្លើហើយលំអដោយ បុប្ផាព្រៃច្រើនពណ៌ ស្រស់បំព្រងបង្អួតសាច់សរលោងខ្ចីល្វក់ដូច បណ្ដូលចេក។
សក់នាងវែងអន្លាយក្រាលទម្លាក់អមស្មាទាំងសងរំយោលជាមួយទងផ្កា ដាស់ចិត្តអ្នកប្រុសឲ្យ នឹកដល់ភាពទន់ល្មើយរបស់កេសីស្រីតូចដែល អ្នកទើបបានអង្អែលថ្មមកាលពីព្រឹក។ នាង ពិតជាស្អាតណាស់បើធៀបនឹងពៅបញ្ញា ព្រោះថានាងសជ្រះជាងផង ទឹកមុខក្អិកក្អក់ មិននឹង នដូចបងស្រីនាងទេ សំខាន់ពេលនេះនាងគេចពីភ្នែកអ្នកដោយថ្ពាល់ទាំងគូអៀនចេញសញ្ញា ក្រហមព្រឿងៗ ធ្វើឲ្យបេះដូងកំលោះ លោតញាប់ព្រោះត្រូវទាក់ទាញ។

ស្រីៗនាំទេពធីតាតូចមកពីភ្នំពេញមកដាក់ក្បែរអ្នកប្រុស ហើយស្នែងចាប់ផ្ដើមផ្លុំឡើងមកពីទី ណាមិនដឹង ចំណែកអ្នកភូមិនាំគ្នាសូត្រសុំសិរីសួស្តីនិងភោគផលកសិកម្ម។ បុរសសង្ហាដៀង ភ្នែកមករកនារីដែលនៅក្បែរកាយបង្កើយ។ គេប្លែកភ្នែកនឹងរបៀបតុបតែងព្រមទាំងចរិតអៀន អន់របស់នាង។
អ្នកលបមើលផែនថ្ពាល់ម៉ត់រលោងនិងបបូរមាត់ដែលស្ទើរញញឹមស្ទើរស្មើ បូកផ្សំជាមួយភាព ស្ងប់ស្ងាត់របស់នាង។ អ្នកប្រុសទីពីរដណ្ដឹងសួរក្នុងចិត្ត៖
«តាមថាស្រីម្នាក់នេះកាចគ្មានទំនង នឹងពូកែខាងរករឿងគ្មានដឹងទិសតំបន់ទេ ចុះម៉េចក៏ពេល នេះត្រូវគេចាប់ឲ្យមកសែនជាប្ដីប្រពន្ធនិងបុរស ម្នាក់ដែលមិនសមប្រកបគ្នាសូម្បីតែឋានៈ គ្រួសារហេតុអ្វីក៏នាងមិន មានសញ្ញាថា ប្រកែកតវ៉ាឬមួយហ្នឹង រញ៉ាំរញ៉ូវអ្វីសោះ?»។
តែទោះបីជាស្រីតូចឯណោះនាងគិតពីឱនមើលទងស្មៅក្បែរជើង ក៏មិនមែននាងមិនដឹងថាអ្នក ប្រុសកំពុងសម្លឹងមកនាងមិនដកភ្នែកនោះ ទេ គឺនាងធ្វើពើជាមិនខ្វល់ តែនាងកាន់តែធ្វើដូច្នេះ គេក៏កាន់តែយល់ចិត្តនាង។ នាងកាន់តែអៀន គេហាក់ចង់តែញញឹមទទ្វេឡើង។
មេភូមិចាប់និយាយអ្វីមួយបីម៉ាត់ព្ទៗពញ្ញាក់អារម្មណ៍រិទ្ធិមកវិញ ហើយទើបគាត់បិទភ្នែកស្មិង

ស្មាធ៏លើកដៃទាំងសងទល់ទៅលើវេហា ចំណែកបុរសចេះខ្មែរក៏ចេះតែនិយាយពន្យល់ហូរហែថា៖

«ផឹកស្រារួចកាលណាអ្នកទាំងពីរជាប្ដីប្រពន្ធនឹងគ្នា អ្នកទាំងពីរអាចរស់នៅភូមិនេះយូរប៉ុណ្ណាក៏បានដែរ ព្រោះជាកូននិងកូនប្រសាររបស់មេភូមិ ហើយគាត់នឹងការពារអ្នកទាំងពីរ។ តែត្រូវប្រឹងប្រែងធ្វើតាមទម្លាប់របស់យើងដើម្បីឲ្យអ្នកភូមិបាន សុខគ្រប់ៗគ្នា!»

រិទ្ធិដកភ្នែកដែលតាមសម្លឹងស្រីតូចដល់ថ្នាក់នាងអៀនជ្រប់មុខ ហើយងាកមកសម្លឹងមនុស្សម្នាជុំវិញខ្លួន។ គេនឹកឃើញដល់ពេល ដែលជាតិថ្នាំរើធ្វើទុក្ខកាលពីមុននេះ គេចាប់ពិបាកចិត្តសាជាថ្មី។ អ្វីដែលអ្នកប្រុសគិតដល់មុនគេនោះគឺថា បើទីនេះគ្មានមធ្យោបាយទាក់ទងទៅភ្នំពេញវិញ ហើយចេះតែអូសបន្លាយបែបនេះរហូតទៅ តើអ្នកលាក់លៀមនឹងអ្នកភូមិពីសមាសភាពខ្លួននិងនារីនេះបានយូរ ប៉ុណ្ណា?

ដែលជាអាទិភាពគឺអ្នកចង់ឲ្យនាងបានវិលត្រលប់ទៅវិញកាន់តែឆាប់ កាន់តែល្អ ប៉ុន្តែចំពោះមុខសូម្បីតែមធ្យោបាយតែបន្តិចក៏គ្មាន។ ប្រុសស្រីទាំងទ្វេ នៅអង្គុយស្ងៀមស្ងាត់រង់ចាំស្ដាប់ការសូត្រធម៌និងហ៊ោក្រេវៗរបស់ ពួកគេជិតកន្លះម៉ោងទើបបានអ្នកប្រុសលីឪទឹនស្រាថ្មីសន្លាងមួយមក ដល់ ដោយមានបំពង់ឫស្សីតូចៗបីដើមសម្រាប់បឺតផង។

បុរសជាមេភូមិឱនបឺតស្រានោះមុន បន្ទាប់មកក៏ធ្វើដៃឲ្យអ្នកស្រុកលើបំពងពីរទៀតបញ្ចុកទៅប្រុសស្រីទាំងទ្វេ។

ក្រពះទទេស្អាតប៉ះត្រូវស្រាបិតនេះមិនដឹងថាទប់ទល់បានរបៀបណាទេ តែគេក៏មិនអាចបដិសេធ ដែរ មានតែព្រមទទួលបំពង់នោះមកបៀមក្នុងមាត់ ហើយក្រឡេកភ្នែកទៅរកភាគីខាងស្រីដែលនាងហាក់នៅរុញរា។

កែវភ្នែកអ្នកប្រុសប៉ះក្រសែភ្នែកនាងដែលទើបតែសម្លឹងមកជាដំបូង ក្នុងគ្រាប្រារព្ធពិធីដ៏គួរឲ្យអៀនប្រៀននេះ។ ពន្លឺភ្នែកអ្នកស្រទន់ហាក់ចង់សួរនាងថា នាងគិតយ៉ាងណាប្រសិនបើនេះជាការពិតហើយប្រសិនបើនាងត្រូវរៀបការ យកគេជាប្ដីនៅកណ្ដាលទ្រូងព្រៃនេះ នាងអាចលះបង់ភាពជាអ្នកនាងធំហើយទម្លាប់ជាមួយភាពគគ្រិចស្មោកគ្រោក អស់នេះដែរ?

អ្នកប្រុសប្រហែលកាន់តែបានចិត្តព្រោះត្រឹមពន្លឺភ្នែកមិននិយាយ ចេញ តែនាងហាក់ទទួលអារម្មណ៍ថាបានឮសំណួរគ្មានសូរសម្លេងនោះស្រេចទៅ ហើយ។ សេចក្ដីស្នេហាសម្ងាត់មួយនិងការលះបង់របស់ស្រីម្នាក់បានបញ្ចេញតាម ពន្លឺភ្នែកនាងដែលសម្លឹងតបមកនរៈយើង

បន្ទាប់មកនាងឱនសន្សឹមៗទៅបៀមឧបករណ៍គ្រេបភេសជ្ជៈនោះដូចគ្នា។
បេះដូងកូនប្រុសទីពីររបស់អគ្គទេសាភិបាលហាក់ស្គាល់ជាលើកដំបូងនូវ អារម្មណ៍ជាមោទនភាពរបស់បុរសម្នាក់ក្នុងពេលដែលគេយល់ថាមានស្រី ម្នាក់នៅចំពោះមុខគេស្អាតអើយស្អាតដូចទេពធីតាតូច ហើយកំពុងធ្វើអ្វីគ្រប់យ៉ាងព្រោះតែនាងចង់នៅក្បែរគេ។
សម្ដីនាងដែលមមើមមាយកាលពីយប់មិញលាន់មកជាច្រើនដងក្នុងអារម្មណ៍ អ្នក

«បងរិទ្ធិរបស់ឯងនោះគេសង្ហាដល់ហើយ!...ហើយឯងដឹងអត់....គឺគេ ហ្នឹងណ៎ា....គេអស្ចារ្យណាស់....គេអៀវយើងរួច...គឺរត់កាត់ព្រៃ....គេដូច Superman អញ្ចឹង!»
គេញញឹមហើយបឺតស្រានោះមិនដឹងខ្លួន មិនខ្វល់ថាក្រពះទទេ ឬស្ថិតក្នុងបរិយាកាសរបៀបណាហើយសុរានោះខុសប្លែកពីស្រាបារាំង កម្រិតណាឡើយ។